ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់លក់

# កម្រងវិញ្ញាសា

# វិទ្យាសាស្ត្រ

## ៩




facebook.com/moeys.gov.kh elearning.moeys.gov.kh youtube.com/moeys


គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាស
លេខ ១១៥០ អយក.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីប្រើប្រាស់តាមសាលារៀន។

# កម្រងវិញ្ញាសា

# វិទ្យាសាស្ត្រ

(សម្រាប់ត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ)

## ថ្នាក់ទី ៩


បោះពុម្ពផ្សាយដោយ

គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

អគារ ១៩៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

**គណៈកម្មការនិពន្ធ** លោក ស៊ុយ ប៊ុនធឿន លោក ចាន់ ខេង
លោក សុក វុធ្នី លោកស្រី ឃឹម ឃីហ៊ុប

**វិចិត្រករ** លោក សេង វិសាល

**អ្នករៀបរៀង** លោក ស៊ឹម ចាន់ធី

**អ្នករចនាទំព័រ** លោក ហៃ វីរៈ

**អ្នកពិនិត្យអក្ខរាវិរុទ្ធ** លោកស្រី ខ្វាន់ ដារ៉ានី លោក អ៊ុំ បុប្ផា

**គណៈកម្មការពិនិត្យ** លោក សូ គន្ធី លោក សួន សុជាតិ
លោក សៀក ពុទ្ធារី លោក ជួន វណ្ណា

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ១១៥០ អយក.ប្រក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីប្រើប្រាស់ជាឯកសារជំនួយនៅតាមសាលារៀនចំណោះទូទៅ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៧

ISBN : 9-789-924-505-09-9

# អារម្ភកថា

សៀវភៅកម្រងវិញ្ញាសា **វិទ្យាសាស្ត្រ** សម្រាប់ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនេះ អ្នកនិពន្ធយើងខ្ញុំបានរៀបចំចងក្រងឡើងស្របតាមស្តង់ដា នៃវិញ្ញាសាប្រឡងថ្នាក់ជាតិ ដែលណែនាំដោយក្រសួងអប់រំ យុវជន និងកីឡា ។ សៀវភៅនេះយើងបានចែកចេញជាបួនផ្នែកគឺ **វិញ្ញាសារូបវិទ្យា វិញ្ញាសាគីមីវិទ្យា វិញ្ញាសាជីវវិទ្យា និងវិញ្ញាសាផែនដីនិងបរិស្ថានវិទ្យា** ។ ក្នុងវិញ្ញាសានីមួយៗ យើងមានកំណត់រយៈពេល និងពិន្ទុតាមមុខវិជ្ជានៃវិញ្ញាសា ។

យើងរៀបចំរបៀបនេះ គឺចង់ឱ្យសិស្សានុសិស្ស និងអ្នកសិក្សាទាំងអស់អាចធ្វើការវាស់ស្ទង់ពីកម្រិតយល់ដឹងដែលខ្លួនបានសិក្សាកន្លងមក ក៏ដូចជាការត្រៀមលក្ខណៈក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិផងដែរ ។ ក៏ប៉ុន្តែពុំមានន័យថា សៀវភៅនេះជួយបង្កលក្ខណៈដល់អ្នកសិក្សាសម្រាប់ធ្វើជាឯកសារចម្លងក្នុងការប្រឡងនោះឡើយ ។

ចុងបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធិពរដល់សិស្សានុសិស្ស ព្រមទាំងអ្នកសិក្សាគ្រប់ៗគ្នាទទួលបានជោគជ័យក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ ហើយយើងខ្ញុំរង់ចាំទទួលការរិះគន់កែលម្អពីសំណាក់សាស្ត្រាចារ្យ ដែលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយភាតរភាព ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ


ទំព័រ

## I : (រូបវិទ្យា)

1. វិញ្ញាសាទី ១ ..................... 1
2. វិញ្ញាសាទី ២ ..................... 7
3. វិញ្ញាសាទី ៣ ..................... 11
4. វិញ្ញាសាទី ៤ ..................... 17
5. វិញ្ញាសាទី ៥ ..................... 22
6. វិញ្ញាសាទី ៦ ..................... 27
7. វិញ្ញាសាទី ៧ ..................... 33
8. វិញ្ញាសាទី ៨ ..................... 37
9. វិញ្ញាសាទី ៩ ..................... 42
10. វិញ្ញាសាទី ១០ ..................... 47

## II : (គីមីវិទ្យា)

1. វិញ្ញាសាទី ១ ..................... 51
2. វិញ្ញាសាទី ២ ..................... 56
3. វិញ្ញាសាទី ៣ ..................... 60
4. វិញ្ញាសាទី ៤ ..................... 65
5. វិញ្ញាសាទី ៥ ..................... 70
6. វិញ្ញាសាទី ៦ ..................... 75
7. វិញ្ញាសាទី ៧ ..................... 79
8. វិញ្ញាសាទី ៨ ..................... 84
9. វិញ្ញាសាទី ៩ ..................... 89

ទំព័រ

## III : (ជីវវិទ្យា)

1. វិញ្ញាសាទី ១ ..................... 93
2. វិញ្ញាសាទី ២ ..................... 97
3. វិញ្ញាសាទី ៣ ..................... 101
4. វិញ្ញាសាទី ៤ ..................... 105
5. វិញ្ញាសាទី ៥ ..................... 109
6. វិញ្ញាសាទី ៦ ..................... 113
7. វិញ្ញាសាទី ៧ ..................... 117
8. វិញ្ញាសាទី ៨ ..................... 121
9. វិញ្ញាសាទី ៩ ..................... 125
10. វិញ្ញាសាទី ១០ ..................... 129

## IV : (ផែនដីវិទ្យា)

1. វិញ្ញាសាទី ១ ..................... 133
2. វិញ្ញាសាទី ២ ..................... 137
3. វិញ្ញាសាទី ៣ ..................... 142
4. វិញ្ញាសាទី ៤ ..................... 147
5. វិញ្ញាសាទី ៥ ..................... 152
6. វិញ្ញាសាទី ៦ ..................... 158
7. វិញ្ញាសាទី ៧ ..................... 163
8. វិញ្ញាសាទី ៨ ..................... 168

# វិញ្ញាសាទី ១ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីសៀគ្វីអគ្គិសនីងាយមួយ ។ តើឧបករណ៍ (V) នេះសម្រាប់វាស់អ្វី ?




ក. □ វាស់អាំងតង់ស៊ីតេចរន្តឆ្លងកាត់អំពូល

ខ. □ វាស់បរិមាណថាមពលស្តុកក្នុងបាតេរី

គ. □ វាស់ផលសងប៉ូតង់ស្យែលរវាងគោលនៃបាតេរី

ឃ. □ វាស់អានុភាពស៊ីដោយអំពូល ។

2. ខ្សែចម្លងត្រង់ពីរដាក់ស្របគ្នាឆ្លងកាត់ដោយចរន្តដែលមានអាំងតង់ស៊ីតេដូចគ្នានិងមានទិសដៅស្របគ្នា ។ តើដ្យាក្រាមមួយណាបង្ហាញពីកម្លាំង F មានអំពើលើខ្សែចម្លងក្នុងដែនម៉ាញ៉េទិចឱ្យដោយផលនៃចរន្តបានត្រឹមត្រូវ ?

ក. □ 


ខ. □ 


គ. □ 


ឃ. □ 

។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ឃ្នាស់ដែលកម្លាំងទប់ស្ថិតនៅចន្លោះកម្លាំងចលករ ($F_E$) និងចំណុចទម្រ ហៅថា ............................................ ។

ខ. កាំពន្លឺដែលស្របនឹងអ័ក្សអុបទិចចេញពីឡង់ទីងាកចូលកាត់ត្រង់ចំណុចមួយឋិតនៅលើអ័ក្សអុបទិចហៅថា ................. ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាដ្យាក្រាមម៉ូម៉ង់នៃកម្លាំង | ផ្នែក B ជាតម្លៃនៃម៉ូម៉ង់ | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1.  | ក. $M = -10N \cdot W$ | 1. → |
| 2.  | ខ. $M = -6N \cdot W$ | 2. → |
| 3.  | គ. $M = 6N \cdot W$ | 3. → |
| | ឃ. $M = 10N \cdot W$ | 4. → |

## III. លំហាត់

1. បុរសម្នាក់ចង់គាស់រំលើងដុំថ្មដ៏ធំមួយដោយប្រើឃ្នាស់ដូចបង្ហាញក្នុងរូប ។ ដើម្បីធ្វើឱ្យដុំថ្មហើបឡើង គាត់ត្រូវបញ្ចេញកម្លាំង 200N ។ ដុំថ្មហើបបានកម្ពស់ 0.2m ។ គណនា ៖




ក. ទម្ងន់នៃដុំថ្ម

ខ. បំលាស់ទីនៃចុងដងឃ្នាស់ត្រង់កន្លែងដៃបុរសនោះបញ្ចេញកម្លាំង

គ. កម្មន្តទប់នៃដុំថ្ម

ឃ. កម្មន្តចលករធ្វើដោយបុរសនោះ បើគេដឹងថាក្នុងការអនុវត្តទិន្នផលនៃឃ្នាស់បានត្រឹមតែ 90 % ។

2. រូបនេះបង្ហាញពីត្រង់ស្វូបន្ថយតង់ស្យុងមួយ បានភ្ជាប់ទៅនឹងប្រភពចរន្តឆ្លាស់ដែលមានតង់ស្យុងផ្តល់ 250V ។ ពេលគេភ្ជាប់រេស៊ីស្តរមានរេស៊ីស្តង់ 5Ω រវាងគោលទី 1 និងគោលទី 2 នៃតង់ស្យុងចេញ នោះអាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរស្មើនឹង 0.5A តែពេលគេភ្ជាប់រេស៊ីស្តរដែលមានរេស៊ីស្តង់ដូចរេស៊ីស្តរមុនរវាងគោលទី 2 និងគោលទី 3 នោះអាំងតង់ស៊ីតេចរន្តឆ្លងកាត់ស្មើនឹង 1A ។ គេសន្មតថាទិន្នផលនៃត្រង់ស្វូ គឺ 100 % ។ គណនា ៖




ក. ផលសងប៉ូតង់ស្យែលរវាងគោលទី 1 និងទី 2

ខ. ផលសងប៉ូតង់ស្យែលរវាងគោលទី 2 និងទី 3

គ. ចំនួនស្ពៀនៅរបុំមធ្យមរវាងគោលទី 1 និងទី 2

ឃ. ចំនួនស្ពៀនៅរបុំមធ្យមរវាងគោលទី 2 និងទី 3

ង. ផលសងប៉ូតង់ស្យែលរវាងគោលទី 1 និងទី 3

ច. អាំងតង់ស៊ីតេចរន្តឆ្លងកាត់របុំបឋម ។

# កំណែវិញ្ញាសាទី ១

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ វាស់ផលសងប៉ូតង់ស្យែលរវាងគោលនៃបាតេរី

2. ខ. ☑ 

 ។

3. ក. ឃ្នាស់ទំនប់កណ្ដាល

   ខ. កំណុំមេ ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

1 → ខ

2 → គ

3 → ឃ ។

## III. កំណែ

1. ក. ទម្ងន់នៃដុំថ្ម

តាមគោលការណ៍ម៉ូម៉ង់ $M_R = M_E$

តែ $\left.\begin{aligned} M_R &= F_R \times d_R \\ M_E &= F_E \times d_E \end{aligned}\right\} F_R \times d_R = F_E \times d_E$

ដូចនេះ $F_R = \frac{F_E \times d_E}{d_R}$ ដោយ $F_E = 200N, \quad d_E = 3m, \quad d_R = 1m$

$$\Rightarrow F_R = \frac{200N \times 3m}{1m} = 600N$$ ។

ខ. បំលាស់ទីនៃចុងដងឃ្នាស់

តាមគោលការណ៍រក្សាកម្មន្ត $W_R = W_E$

តែ $W_R = F_R \times d_R$

$W_E = F_E \times d_E$

$\Rightarrow F_R \times d_R = F_E \times d_E$

ដោយ $F_R = 600N$ , $d_R = 0.2m$ , $F_E = 200N$

$d_E = \frac{F_R \times d_R}{F_E} = \frac{600N \times 0.2m}{200N} = 0.6m$ ។

គ. កម្មន្តទប់នៃដុំថ្ម

តាមរូបមន្ត $W_R = F_R \times d_R$

$W_R = 600N \times 0.2m = 120J$

$W_R = 120J$ ។

ឃ. កម្មន្តចលករក្នុងការអនុវត្ត

- កម្មន្តចលករក្នុង100 %

$W_E = F_E \times d_E = 200N \times 0.6m = 120J$

- កម្មន្តចលករក្នុងការអនុវត្ត

$Rd = \frac{W'_E}{W_R} \Rightarrow W'_E = Rd\,\% \times W_R$

$W'_E = \frac{120J \times 90}{100} = 108J$ ។

2. ក. ផលសងប៉ូតង់ស្យែលរវាងគោលទី 1 និងទី 2

តាមរូបមន្ត $V_{1,2} = R \times I_{1,2}$ ដោយ $R = 5\Omega$ , $I_{1,2} = 0.5A$

ដូចនេះ $V_{1,2} = 5\Omega \times 0.5A = 2.5V$ ។

ខ. ផលសងប៉ូតង់ស្យែលរវាងគោលទី 2 និងទី 3

តាមរូបមន្ត $V_{2,3} = R \times I_{2,3}$ ដោយ $R = 5\Omega$ , $I_{2,3} = 1A$

ដូចនេះ $V_{2,3} = 5\Omega \times 1A = 5V$ ។

គ. ចំនួនស្ពៀនៅរបុំមធ្យមរវាងគោលទី 1 និងទី 2

តាមរូបមន្ត $\frac{V_P}{V_{1,2}} = \frac{N_P}{N_{1,2}} \Rightarrow N_{1,2} = \frac{N_P \times V_{1,2}}{V_P}$

$$N_P = 1500 \text{ជុំ}$$

ដោយ $V_P = 250V$

$V_{1,2} = 2.5V$

ដូចនេះ $N_{1,2} = \frac{1500 \text{ ជុំ} \times 2.5V}{250V} = 15\text{ជុំ}$ ។

ឃ. ចំនួនស្ពៀនៅរបុំមធ្យមរវាងគោលទី 2 និងទី 3

ដូចគ្នាសម្រាយបញ្ជាក់ខាងលើដែរ

$\frac{V_P}{V_{2,3}} = \frac{N_P}{N_{2,3}} \Rightarrow N_{2,3} = \frac{N_P \times V_{2,3}}{V_P}$ ដោយ $V_{2,3} = 5V$

ដូចនេះ $N_{2,3} = \frac{1500 \text{ ជុំ} \times 5V}{250V} = 30 \text{ ជុំ}$ ។

ង. ផលសងប៉ូតង់ស្យែលរវាងគោលទី 1 និងទី 3

- ចំនួនស្ពៀនៅរបុំមធ្យមរវាងគោលទី 1 និងទី 3

$$N_{1,3} = N_{1,2} + N_{2,b} = 15\text{ជុំ} + 30 \text{ ជុំ} = 45\text{ជុំ}$$

តាមរូបមន្ត $\frac{V_P}{V_{1,3}} = \frac{N_P}{N_{1,3}} \Rightarrow V_{1,3} = \frac{V_P \times N_{1,3}}{N_P}$

ដូចនេះ $V_{1,3} = \frac{250V \times 45\text{ជុំ}}{1500 \text{ ជុំ}} = 7.5V$ ។

ច. អាំងតង់ស៊ីតេចរន្តឆ្លងកាត់របុំបឋម

$$\frac{V_P}{V_S} = \frac{I_S}{I_P} \Rightarrow I_P = \frac{I_S \times V_S}{V_P}$$

ដោយ $V_S = V_{1,2} = 7.5V$ និង

$$I_S = I_{1,2} + I_{2,3} = 0.5A + 1A = 1.5A$$

$$I_P = \frac{7.5V \times 1.5A}{250V} = 0.045A$$

ដូចនេះ $I_P = 45 \times 10^{-3}A$ ។

# វិញ្ញាសាទី ២ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមខាងក្រោមមួយណាដែលបង្ហាញពីការបូកកម្លាំង 4N និង 3N ឱ្យបានត្រឹមត្រូវ ?

ក. ☐



ខ. ☐



គ. ☐



ឃ. ☐


។

2. ដ្យាក្រាមខាងក្រោមបង្ហាញពីការពិសោធមួយដើម្បីវាស់ចម្ងាយកំណុំនៃឡង់ទី ។ តើប្រវែងណាមួយដែលជាចម្ងាយកំណុំនៃឡង់ទី ?

ក. ☐ P

ខ. ☐ Q

គ. ☐ R

ឃ. ☐ P + Q ។




3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. បើអ្នកយកអេក្រង់ដាក់ក្រោយកញ្ចក់ប្លង់ អ្នកមិនអាចទទួលបានរូបភាពលើអេក្រង់ទេ ។ ដូចនេះរូបភាពឱ្យដោយកញ្ចក់ប្លង់ហៅថា ...... ។

ខ. ឡង់ទីមួយដែលមានគែមក្រាស់ជាងផ្នែកផ្ចិតហៅថា ................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាប្រព័ន្ធរ៉ក | ផ្នែក B ជាផលមេកានិចនៃរ៉កស្មើនឹង | ផ្នែក C ជាចម្លើយ |
|---|---|---|
|  | ក. MA = 1<br>ខ. MA = 2<br>គ. MA = 3<br>ឃ. MA = 4 | 1. →<br>2. →<br>3. → |

## III. លំហាត់




1. ដ្យាក្រាមខាងស្តាំដែលបង្ហាញពីបន្ទាត់មួយមានលំនឹងត្រង់ទីប្រជុំទម្ងន់របស់វា ។ គណនា ៖

   ក. ទម្ងន់នៃបន្ទុក X

   ខ. ទម្ងន់នៃបន្ទុក Y ។

2. ចង្កៀងរង្គុំមួយមានសញ្ញាកំណត់សម្គាល់ 60W និង 240V ។ គណនា ៖

   ក. អាំងតង់ស៊ីតេចរន្ត I ដែលឆ្លងកាត់ចង្កៀង

   ខ. រ៉េស៊ីស្តង់នៃប្រឆេះចង្កៀង

   គ. ថាមពលដែលបង្កើតដោយចង្កៀង ។

3. កូនរទេះមួយបានចាប់ផ្តើមរុញឡើងលើតាមផ្លូវជម្រាលមួយដូចបង្ហាញក្នុងរូប ។ គណនា ៖




   ក. កម្មន្តបំពេញដោយបន្ទុកឬកម្មន្តទប់

   ខ. កម្មន្តបំពេញដោយកម្លាំងចលករឬកម្មន្តចលករ

   គ. ផលមេកានិចនៃប្លង់ទេរ

   ឃ. ទិន្នផលនៃម៉ាស៊ីនគិតជាភាគរយ ។

# កំណែវិញ្ញាសាទី ២

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑




។

2. ខ. ☑ Q ។

3. ក. រូបភាពមិនពិត

ខ. ឡង់ទីផត ឬឡង់ទីពង្រីក ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ខ　　$2 \rightarrow$ គ　　$3 \rightarrow$ ឃ ។

## III. កំណែ

1. ក. ទម្ងន់នៃបន្ទុក X

តាមគោលការណ៍លំនឹងនៃឃ្នាស់

$$X \times 20\text{cm} = 4\text{N} \times 25\text{cm}$$

$$\Rightarrow X = \frac{4\text{N} \times 25\text{cm}}{20\text{cm}} = 5\text{N}$$ ។

ខ. បន្ទុក Y

តាមគោលការណ៍លំនឹងនៃឃ្នាស់

$$Y \times 25\text{cm} = (1\text{N} \times 20\text{cm}) + (2\text{N} \times 40\text{cm})$$

$$\Rightarrow Y = \frac{20\text{N}\cdot\text{cm} + 80\text{N}\cdot\text{cm}}{25\text{cm}} = 4\text{N}$$ ។

2. ក. អាំងតង់ស៊ីតេចរន្ត I

តាមរូបមន្ត $P = V \times I \Rightarrow I = \frac{P}{V}$ ដោយ $P = 60\text{W}$ , $V = 240\text{V}$

ដូចនេះ $I = \frac{60\text{W}}{240\text{V}} = 0.25\text{A}$ ។

ខ. រេស៊ីស្តង់នៃប្រឆេះចង្កៀង

តាមរូបមន្ត $P = V \times I$ តែ $I = \frac{V}{R} \Rightarrow P = V \times \frac{V}{R} = \frac{V^2}{R^2} \Rightarrow R = \frac{V^2}{P}$

ដូចនេះ $R = \frac{(240V)^2}{60W} = \frac{57600}{60} = 960\Omega$ ។

គ. ថាមពលដែលបង្កើតដោយចង្កៀងក្នុងរយៈពេល 1h

តាមរូបមន្ត $E = P \times t$ តែ $t = 1h = 3600s$

ដូចនេះ $E = 60W \times 3600s = 216000J$ ។

3. ក. កម្មន្តបំពេញដោយបន្ទុក ឬកម្មន្តទប់

តាមរូបមន្ត $W_R = F_R \times d$ តែ $d = h = 2m$ , $F_R = 300N$

ដូចនេះ $W_R = 200N \times 2m = 600J$ ។

ខ. កម្មន្តបំពេញដោយកម្លាំងចលករ ឬកម្មន្តចលករ

តាមរូបមន្ត $W_E = F_E \times d$ តែ $d' = 4m$ , $F_E = 200N$

ដូចនេះ $W_E = 200N \times 4m = 800J$ ។

គ. ផលមេកានិចនៃប្លង់ទេរ

តាមរូបមន្ត $MA = \frac{F_R}{F_E}$ ឬ $MA = \frac{L}{h}$

តែ $L = 4cm$ , $h = 2cm$

ដូចនេះ $MA = \frac{4m}{2m} = 2$

បើធ្វើតាមរូបមន្ត $MA = \frac{F_R}{F_e}$ នោះ $MA = 1.5$ ត្រូវបញ្ជាក់ថាការខាតបង់កម្លាំងនេះដោយសារការកកិតរវាងកង់រទេះនិងផ្លូវថ្នល់ ។

ឃ. ទិន្នផលនៃម៉ាស៊ីនគិតជាភាគរយ

តាមរូបមន្ត $Rd\% = \frac{W_R}{W_E} \times 100$ ដោយ $W_R = 600J$ , $W_E = 800J$

ដូចនេះ $Rd\% = \frac{600}{800} \times 100 = 75\%$ ។

# វិញ្ញាសាទី ៣ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. បណ្តាទំហំខាងក្រោម តើទំហំមួយណាជាផលគុណរវាងកម្លាំងនិងបំលាស់ទីតាមទិសដៅនៃកម្លាំងនោះ ?

ក. ☐ សំទុះ　　ខ. ☐ អនុភាព

គ. ☐ ម៉ូម៉ង់　　ឃ. ☐ កម្មន្ត ។

2. រូបនេះបង្ហាញពីសៀគ្វីមួយដែលមានកុងតាក់ចំហទាំងអស់ តើកុងតាក់ទាំងអស់ត្រូវស្ថិតនៅក្នុងស្ថានភាពមួយណា ដើម្បីបានរេស៊ីស្តង់សរុបមួយស្មើនឹង 6Ω រវាងគោល X និង Y ?

| | $S_1$ | $S_2$ | $S_3$ |
|---|---|---|---|
| ក. ☐ | បិទ | បិទ | បិទ |
| ខ. ☐ | បិទ | បិទ | ចំហ |
| គ. ☐ | ចំហ | បិទ | បិទ |
| ឃ. ☐ | ចំហ | ចំហ | បិទ ។ |




3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ឧបករណ៍ដែលមានដែកសុទ្ធរុំដោយស្ពៀជាខ្សែចម្លងដែលមានចរន្តឆ្លងកាត់ហៅថា .......................... ។

ខ. ទំហំមួយកំណត់ដោយផលគុណរវាងកម្លាំងនិងប្រវែងដៃឃ្នាស់ហៅថា ................ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A រូបតាងឱ្យអង្គធាតុ | ផ្នែក B ប្រភេទនៃលំនឹង | ផ្នែក C |
|---|---|---|
| 1.  | ក. លំនឹងស៊ុប | 1. → |
| 2.  | ខ. លំនឹងគ្រប់ទិស | 2. → |
| 3.  | គ. លំនឹងដេក | 3. → |
| | ឃ. លំនឹងមិនស៊ុប | |

## III. លំហាត់

1. ដ្យាក្រាមនេះបង្ហាញពីរេស៊ីស្តរពីរតជាស៊េរី ។ ផលសងប៉ូតង់ស្យែលរវាងចំណុច A និង C គឺ 9V ។ គណនា ៖




ក. រេស៊ីស្តង់សមមូលរវាងចំណុច A និង C

ខ. អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរ

គ. ផលសងប៉ូតង់ស្យែលរវាងគោលទាំងពីរនៃរេស៊ីស្តរដែលមានរេស៊ីស្តង់ 1000Ω ។

2. រូបខាងក្រោមនេះជាប្រព័ន្ធរ៉ក ។ សម្រាប់ប្រព័ន្ធរ៉កនីមួយៗគណនា ៖




ក. កម្មន្តទប់នៃបន្ទុកក្នុងការលើកបន្ទុកឡើងលើកម្ពស់ 1m

ខ. កម្មន្តចលករនៃកម្លាំង

គ. ទិន្នផលនៃប្រព័ន្ធរ៉កគិតជាភាគរយ ។

3. ដ្យាក្រាមនេះបង្ហាញពីទម្រង់ងាយនៃការសង្កត់របស់ប្រាំងអ៊ីដ្រូលិចនៃរថយន្ត ។




ក. ប្រសិនបើកម្លាំង 50N សង្កត់ទៅលើពីស្តុងតូច គណនាសម្ពាធដែលមានអំពើទៅលើអង្គធាតុរាវ (ប្រេង) នៃពីស្តុងតូច X

ខ. តើសម្ពាធនៃប្រេងដែលមានអំពើទៅលើពីស្តុងធំ Y ស្មើនឹងប៉ុន្មាន ?

គ. កម្លាំង $F_Y$ ដែលបញ្ចេញដោយពីស្តុងធំ

ឃ. បើពីស្តុងតូចផ្លាស់ទីចុះក្រោមបានចម្ងាយ 5cm តើពីស្តុងធំផ្លាស់ទីបានប៉ុន្មាន ?

# កំណែវិញ្ញាសាទី ៣

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑ កម្មន្ត ។

2. ក. ☑ $S_1$ បិទ  $S_2$ បិទ  $S_3$ បិទ ។

3. ក. អេឡិចត្រូមេដែក

   ខ. ម៉ូម៉ង់នៃកម្លាំង ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ឃ    $2 \rightarrow$ ក    $3 \rightarrow$ ខ ។

## III. កំណែ

1. ក. រេស៊ីស្តង់សមមូលរវាងចំណុច A និងចំណុច C :

   ដោយ $R_A$ និង $R_C$ តជាស៊េរី

   ដូចនេះ $R_{AC} = R_A + R_C = 2000\Omega + 1000\Omega = 3000\Omega$ ។

   ខ. អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្ទរ :

   តាមរូបមន្ត : $V = R \times I \Rightarrow I = \frac{V}{R} = \frac{9V}{3000\Omega} = 3 \times 10^{-3}A$ ។

   គ. ផលសងប៉ូតង់ស្យែលរវាងគោលនៃ $R_C$

   ដោយ $R_A$ និង $R_C$ តជាស៊េរី ដូចនេះ $I = I_A = I_C = 3 \times 10^{-3}A$

   $\Rightarrow V = R_C \times I = 1000 \times 3 \times 10^{-3} = 3V$ ។

2. - សម្រាប់ប្រព័ន្ធរ៉កទី 1

   ក. កម្មន្តទប់នៃបន្ទុក

   $W_R = F_R \times d$ ដោយ $F_R = 20N$ , $d = h = 1m$

   ដូចនេះ $W_R = 20N \times 1m = 20N \cdot m$ ឬ $20J$ ។

ខ. កម្មន្តចលករនៃកម្លាំង

$W_E = F_E \times d$

ដោយ $F_E = 10N$ , $d = 3 \times h$ តែ $h = 1m$ $d = 3m$ (ព្រោះប្រព័ន្ធរ៉កនេះប្រើរ៉ក 3) $W_R = 10N \times 3m = 30N \cdot m$ ឬ $30J$ ។

គ. ទិន្នផលគិតជាភាគរយ

តាមរូបមន្ត $Rd = \frac{W_R}{W_E}$ ដោយ $W_R = 20J$ , $W_E = 30J$

ដូចនេះ $Rd = \frac{20J}{30J} = \frac{2}{3} = 0.67 = 67\%$ ។

- សម្រាប់ប្រព័ន្ធរ៉កទី 2

ក. កម្មន្តទប់នៃបន្ទុក

$$W_R = F_R \times d \begin{cases} F_R = 600N \\ d = 1m \end{cases} \Rightarrow W_R = 600N \times 1m = 600N \cdot m$$

ឬ $W_R = 600J$ ។

ខ. កម្មន្តចលករនៃកម្លាំង

$$W_E = F_E \times d \begin{cases} F_E = 200N \\ d = 4 \times h = 4 \times 1m = 4m \end{cases}$$

$\Rightarrow W_E = 200N \times 4m = 800N \cdot m$ ឬ $800J$ ។

គ. ទិន្នផលគិតជាភាគរយ

$$Rd = \frac{W_R}{W_E} \text{ ដោយ } \left.\begin{matrix} W_R = 600J \\ W_E = 800J \end{matrix}\right\} Rd = \frac{600J}{800J} = \frac{3}{4} = 0.75$$

ដូចនេះ $Rd = 75\%$ ។

3. ក. សម្ពាធនៃប្រេងត្រង់ X

$P_X = \frac{F_X}{A_X}$ ដោយ $F_X = 50N$ , $A_X = 2cm^2$

$\Rightarrow P_X = \frac{50N}{2cm^2} = 25N/cm^2$ ។

ខ. សម្ពាធនៃប្រេងត្រង់ Y

សម្ពាធនៃអង្គធាតុរាវមានតម្លៃស្មើគ្នានៅគ្រប់ចំណុចទាំងអស់

ដូចនេះ $P_X = P_Y = 25N/cm^2$ ។

គ. កម្លាំង $F_Y$ ដែលបញ្ចេញដោយពីស្តុងធំ

តាមគោលការណ៍អ៊ីដ្រូលិច :

$\frac{F_X}{A_X} = \frac{F_Y}{A_Y}$ ឬ $F_Y = P_Y \times A_Y$ ដោយ $P_Y = 25N/cm^2$

$A_Y = 100cm^2 = 100 \times 10^{-4}m^2$

$F_Y = 25N/cm^2 \times 100cm^2 = 2500N$ ។

ឃ. បំលាស់ទីនៃពីស្តុងធំ

តាមគោលការណ៍រក្សាកម្មន្ត

$$\left.\begin{aligned} W_E &= W_R \\ W_E &= F_X \times d_X \\ W_R &= F_Y \times d_Y \end{aligned}\right\} \Rightarrow d_Y = \frac{F_X \times d_X}{F_Y}$$

$$d_Y = \frac{50N \times 5cm}{2500N} = 0.1cm$$ ឬស្មើនឹង 1mm ។

# វិញ្ញាសាទី ៤ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីសៀគ្វីអគ្គិសនីមួយ ។ តាមរូបតើវ៉ុលម៉ែត V ចង្អុលតម្លៃមួយណា ?




ក. ☐ 1V

ខ. ☐ 1.5V

គ. ☐ 2V

ឃ. ☐ 3V ។

2. រូបនេះបង្ហាញពីប្លង់ទេរមួយ ។ តើបណ្ដាទំហំខាងក្រោមមួយណាជាផលមេកានិចនៃប្លង់ទេរនេះ ?




ក. ☐ MA = 1m

ខ. ☐ MA = 2m

គ. ☐ MA = 3m

ឃ. ☐ MA = 4m ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. សំណុំកាំពន្លឺដែលស្ថិតក្នុងកោណកំណត់ដោយប្រភពហៅថា ........ .................... ។

ខ. ត្រង់ស្វូដំឡើងតង់ស្យុងឆ្លាស់ពីទាបទៅខ្ពស់ហៅថា ................. ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាវត្ថុ | ផ្នែក B ជាប្រភេទនៃអង្គធាតុហៅថា | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. កែវថ្លា | ក. អង្គធាតុឃ្មឹក | 1. → |
| 2. ប៉ាសឺទ្បែនស្តើង | ខ. អង្គធាតុរាវ | 2. → |
| 3. កញ្ចក់ឆ្លុះមុខ | គ. អង្គធាតុស្រអាប់ | 3. → |
| | ឃ. អង្គធាតុថ្លា | |

## III. លំហាត់

1. រូបនេះបង្ហាញពីសៀគ្វីអគ្គិសនីមួយដែលមានទែមីស្ទរនិងរេស៊ីស្តរតជាស៊េរី ។ ទែមីស្ទរមានរេស៊ីស្តង់ 200Ω ។ គណនា ៖




ក. អាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់រេស៊ីស្តរនិងទែមីស្ទរ

ខ. ផលសងប៉ូតង់ស្យែលរវាងចុងសងខាងនៃរេស៊ីស្តរដែលមានរេស៊ីស្តង់ 1000Ω

គ. សីតុណ្ហភាពទែមីស្ទរថយចុះនោះផលសងប៉ូតង់ស្យែលរវាងគោលនៃរេស៊ីស្តរដែលមានរេស៊ីស្តង់ 1000Ω ស្មើនឹង 4V ។ គណនាតម្លៃថ្មីនៃរេស៊ីស្តង់របស់ទែមីស្ទរ ។

2. ចូរកំណត់ម៉ូម៉ង់នៃកម្លាំង 10N ធៀបនឹងអ័ក្សរង្វិលត្រង់ចំណុច 0 ដែលអ័ក្សរង្វិលកែងនឹងប្លង់នៃក្រដាសក្នុងស្ថានភាពនីមួយៗ ដូចបង្ហាញក្នុងរូប ។ គេកំណត់ម៉ូម៉ង់វិជ្ជមានមានទិសដៅច្រាសនិងទិសដៅរង្វិលនៃទ្រនិចនាឡិកា ។ ម៉ូម៉ង់អវិជ្ជមានមានទិសដៅតាមទិសដៅរង្វិលនៃទ្រនិចនាឡិកា ។



# កំណែវិញ្ញាសាទី ៤

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ 1.5V ។

2. គ. ☑ MA = 3m ។

3. ក. បាច់ពន្លឺ

   ខ. ស្នូករ៉ុលទ័រ ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ឃ $2 \rightarrow$ គ $3 \rightarrow$ ក ។

## III. កំណែ

1. ក. អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរនិងទែមីស្ទរ

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរ

តាមរូបមន្ត $I = \frac{V}{R}$ តែ $R = R_{ទែមីស្ទ} + R_{រេស៊ី} = 200\Omega + 1000\Omega$

$V = 12V$

$\Rightarrow I = \frac{12V}{1200\Omega} = 0.01A$ ។

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ទែមីស្ទរដោយទែមីស្ទរនិងរេស៊ីស្តរតជាស៊េរី ដូចនេះចរន្តដែលឆ្លងកាត់ទែមីស្ទរស្មើនឹងចរន្តដែលឆ្លងកាត់រេស៊ីស្តរ គឺ $I = 0.01A$ ។

ខ. ផលសងប៉ូតង់ស្យែលរវាងចុងសងខាងនៃរេស៊ីស្តរដែលមានរេស៊ីស្តង់ $1000\Omega$

តាមរូបមន្ត $V_R = I \times R$ ដោយ $I = 0.01A$ , $R = 1000\Omega$

$\Rightarrow V_R = 0.01A \times 1000\Omega = 10V$ ។

គ. តម្លៃថ្មីនៃរេស៊ីស្តររបស់វ៉ុលមីស្តែ

- តង់ស្យុងរវាងគោលទាំងពីរនៃវ៉ុលមីស្តែ

$V_{វ៉ុលមី} = V_{ស} - V_{R}$ ដោយ $V_{ស} = 12V$ , $V_{R} = 4V$

$V_{វ៉ុលមី} = 12V - 4V = 8V$ ។

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរ

$I = \frac{V_R}{R_V}$ ដោយ $V_R = 4V$ , $R = 1000\Omega$

$\Rightarrow I = \frac{4V}{1000\Omega} = 0.004A$ ដោយវ៉ុលមីស្តែនិងរេស៊ីស្តរតជាស៊េរីដូចនេះ

$I_{វ៉ុលមី} = 0.004A$ ដែរ ។

តាមរូបមន្ត

$V_{វ៉ុលមី} = I_{វ៉ុលមី} \times R_{វ៉ុលមី} \Rightarrow R_{វ៉ុលមី} = \frac{V_{វ៉ុលមី}}{I_{វ៉ុលមី}}$

$R_{វ៉ុលមី} = \frac{8V}{0.004A} = 2000\Omega$ ។

2. ក. ម៉ូម៉ង់នៃកម្លាំង 10N (រូបក) ធៀបនឹងអ័ក្សរង្វិល 0

តាមរូបមន្ត

$M = F \times d$ ដោយ $F = 10N$ , $d = 4m$

$\Rightarrow M = 10N \times 4m = 40N \cdot m$ (ម៉ូម៉ង់វិជ្ជមាន) ។

ខ. ម៉ូម៉ង់នៃកម្លាំង 10N (រូបខ) ធៀបនឹងអ័ក្សរង្វិល 0

$M = F \times d$ ដោយ $F = 10N$ , $d = 8m$

$\Rightarrow M = 10N \times 8m = 80N \cdot m$ (ម៉ូម៉ង់អវិជ្ជមាន) ។

គ. ម៉ូម៉ង់នៃកម្លាំង 10N (រូបគ) ធៀបនឹងអ័ក្សរង្វិល 0

សំណួរនេះអាចដោះស្រាយបានពីររបៀប :

- **របៀបទី** 1

យើងគូសបន្លាយនៃទិចទ័រតាងកម្លាំង 10N រួចទម្លាក់ចំណោលពីចំណុច 0 ទៅលើបន្លាយនៃវិចទ័រ យើងបាន :




$$BO = OA \times \sin 30° = 4m \times \frac{1}{2} = 2m$$

តែ OB ជាប្រវែងដៃឃ្នាស់នៃកម្លាំង 10N

$M = F \times d$ តែ $d = OB = 2m$

$\Rightarrow M = 10N \times 2m = 20N \cdot m$ (ម៉ូម៉ង់វិជ្ជមាន) ។

- **របៀបទី** 2

យើងបំបែកកម្លាំង 10N ជាកម្លាំងផ្គុំកែងពីរគឺ :

$10N\cos 30°$ និង $10N \times \sin 30°$

- ម៉ូម៉ង់ត្រង់ 0 នៃកម្លាំងផ្គុំកែង

$M_1 = F_1 \times d_1$ ដោយ $F_1 = 10\sin 30° = 10N \times \frac{1}{2} = 5N$ , $d = 4m$

$M_1 = 5N \times 4m = 20N \cdot m$ ។

- ម៉ូម៉ង់ត្រង់ 0 នៃកម្លាំងផ្គុំស្រប គឺស្មើសូន្យ

ដូចនេះ $M = M_1 = 20N \cdot m$ ។

# វិញ្ញាសាទី ១ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីកាំពន្លឺដាលពីមជ្ឈដ្ឋានខ្យល់ឆ្លងកាត់មជ្ឈដ្ឋានកែវ ។ តើដ្យាក្រាមមួយណាដែលបង្ហាញពីគន្លងនៃកាំពន្លឺដាល***មិនបាន***ត្រឹមត្រូវ ?

ក. ☐ 

ខ. ☐ 

គ. ☐ 

ឃ. ☐  ។

2. ម៉ូម៉ង់នៃកម្លាំងមួយដែលកំណត់ដោយ :

ក. ☐ ផលចែករវាងកម្លាំងចាប់ នឹងប្រវែងដៃឃ្នាស់

ខ. ☐ ផលគុណរវាងកម្លាំងចាប់ នឹងប្រវែងដៃឃ្នាស់

គ. ☐ ផលសងរវាងកម្លាំងចាប់ នឹងប្រវែងដៃឃ្នាស់

ឃ. ☐ ផលបូករវាងកម្លាំងចាប់ នឹងប្រវែងដៃឃ្នាស់ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. បាតុភូតដែលធ្វើឱ្យកើតមានកម្លាំងអគ្គិសនីចលករនៅក្នុងសៀគ្វីដោយសារបម្រែបម្រួលដែនម៉ាញេទិចហៅថា................... ។

ខ. សូលេណូអ៊ីតមានប៉ូលពីរ ដើម្បីកំណត់ប៉ូលរបស់វាគេត្រូវប្រើវិធី ............ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជានិមិត្តសញ្ញានៃឧបករណ៍អគ្គិសនី | ផ្នែក B ជាឈ្មោះនៃឧបករណ៍អគ្គិសនី | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. <br>2. <br>3.  | ក. កុងទ័រអគ្គិសនី<br>ខ. កាល់វ៉ាណូម៉ែត<br>គ. អំពែម៉ែត<br>ឃ. វ៉ុលម៉ែត | 1. →<br>2. →<br>3. → |

## III. លំហាត់

1. កង់មុខនៃរថយន្តមួយផ្លាស់ទីក្នុងល្បឿនថេរ ។ កម្លាំងទាំងអស់ដែលមានអំពើលើរថយន្តបានបង្ហាញដោយរូបខាងក្រោម ។ Q ជាកម្លាំង (កកិត+ ទប់នៃខ្យល់) ដែលមានអំពើលើរថយន្តកំពុងផ្លាស់ទី ។ P ជាកម្លាំងជំណោលឡើងលើសរុបមកលើកង់មុខទាំងពីរនៃរថយន្ត ។

ក. ចូរពន្យល់ :

1. P = 4000N
2. Q = 400N




ខ. គណនាម៉ាសនៃរថយន្ត

គ. គណនាសំទុះនៃរថយន្ត ។

2. ព័ត៌មានមួយស្ដីអំពីម៉ាស៊ីនកាត់ស្មៅពីរម៉ាកគឺ X និង Y ដូចបង្ហាញក្នុងតារាងខាងក្រោម ៖

| បរិយាយ | ម៉ាស៊ីនម៉ាក X | ម៉ាស៊ីនម៉ាក Y |
|---|---|---|
| តម្លៃម៉ាស៊ីន | 60 ដុល្លារ | 65 ដុល្លារ |
| អានុភាពម៉ាស៊ីន | 500W | 1000W |
| រយៈពេលកាត់ | 30 នាទី | 20 នាទី |
| ការណែនាំប្រើប្រាស់ភុយស៊ីប | 3A | 13A |
| អង្កត់ផ្ចិតមុខកាត់ | 30cm | 50cm |
| តង់ស្យុងផ្ដល់ | 240V | 240V |

តម្លៃប្រើប្រាស់ថាមពលអគ្គិសនី 800៛/kwh ។

ក. គណនាតម្លៃប្រើប្រាស់ថាមពលអគ្គិសនីរបស់ម៉ាស៊ីននីមួយៗ

ខ. ចូរពន្យល់ ហេតុអ្វីបានជាការណែនាំប្រើប្រាស់ភុយស៊ីបនៃម៉ាស៊ីនទាំងពីរខុសគ្នា

គ. ចូរឱ្យហេតុផល ហេតុអ្វីបានជាអតិថិជននឹងជ្រើសរើសទិញម៉ាស៊ីនម៉ាក Y ជាងម៉ាក X ។

# កំណែវិញ្ញាសាទី ៥

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑  ។

2. ខ. ☑ ផលគុណរវាងកម្លាំងចាប់នឹងប្រវែងដៃឃ្នាស់ ។

3. ក. អាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

   ខ. គេប្រើវិធានកណ្ដាប់ដៃស្ដាំ ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

$1 \rightarrow$ គ $\quad 2 \rightarrow$ ឃ $\quad 3 \rightarrow$ ខ ។

## III. កំណែ

1. ក. $P = 4000N$ ព្រោះទម្ងន់សរុបនៃរថយន្ត $R = 10000N$ ត្រូវបានបំបែកជាកម្លាំងស្របពីរគឺ $P$ និង $P'$ ដែល $P' = 6000N$

   តាមរូបមន្ត $R = P + P' \Rightarrow P = R - P' = 10000N - 6000N = 4000N$

   ខ. ម៉ាសនៃរថយន្ត

   តាមរូបមន្ត $R = m \times g$ ដោយ $g = 10m/s^2$

   $$\Rightarrow m = \frac{R}{g} = \frac{10000N}{10m/s^2} = 1000kg \text{ ។}$$

   គ. សំទុះនៃរថយន្ត

   តាង $F'$ ជាកម្លាំងផ្គួបពេលកម្លាំង $F$ កើនឡើង 2 ដង

   បើកម្លាំង $F$ កើនឡើង 2 ដងនោះ $F \times 2 = 400N \times 2 = 800N$

   $\vec{F'} = \vec{F} + \vec{Q}$ ឬ $F' = F - Q$ (ទិសដូចគ្នាទិសដៅផ្ទុយគ្នា)

   $F' = 800N - 400N = 400N$

តាមរូបមន្ត $F' = m \times a \Rightarrow a = \frac{F'}{m} = \frac{400N}{1000kg} = 0.4m/s^2$ ។

2. ក. តម្លៃប្រើប្រាស់ថាមពលអគ្គិសនីនៃម៉ាស៊ីននីមួយៗ

- ថាមពលអគ្គិសនីស៊ីដោយម៉ាស៊ីនម៉ាក X គិតជា kwh

$E_x = P_x \times t_x$ ដោយ $P_x = 500w = 0.5kW$ , $t_x = 30mn = 0.5h$

$E_x = 0.5kw \times 0.5h = 0.25kwh$

តម្លៃប្រើប្រាស់ $0.25kwh \times 800^{៛}/kwh = 200^{៛}$ ។

- ថាមពលអគ្គិសនីស៊ីដោយម៉ាស៊ីនម៉ាក Y គិតជា kwh

$E_y = P_y \times t_y$

ដោយ $P_y = 1000W = 1kW$ , $t_y = 20mn = 0.33h = \frac{1}{3}h$

$E_y = 1kW \times 1/3h = \frac{1}{3}kWh$

តម្លៃប្រើប្រាស់ $\frac{1}{3}kWh \times 800^{៛}/kWh = 266^{៛}$ ។

ខ. ម៉ាស៊ីនទាំងពីរប្រើប្រាស់ភុយស៊ីបខុសគ្នាព្រោះ

- ចរន្តឆ្លងកាត់ម៉ាស៊ីនម៉ាក X : $I_x = \frac{P_x}{V} = \frac{500W}{240V} = 2A$

- ចរន្តឆ្លងកាត់ម៉ាស៊ីនម៉ាក Y : $I_y = \frac{P_y}{V} = \frac{1000W}{240V} = 4.16A$

ហេតុដូចនេះបានជាម៉ាស៊ីនម៉ាក X ត្រូវប្រើភុយស៊ីប 3A ហើយម៉ាស៊ីនម៉ាក Y ត្រូវប្រើភុយស៊ីប 13A ។

គ. បានជាអតិថិជនជ្រើសរើសទិញម៉ាស៊ីនម៉ាក Y ព្រោះ

- មានទទឹងមុខកាត់ធំងាយស្រួលកាត់បានលឿន

- អានុភាព អាំងតង់ស៊ីតេចរន្តធំ ងាយស្រួលក្នុងការប្រើប្រាស់ ចំណេញពេលវេលា ។

# វិញ្ញាសាទី ៦ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីបង្គុំរេស៊ីស្ទរ ដែលមានរេស៊ីស្តង់ឯកលក្ខណ៍ ។
តើដ្យាក្រាមមួយណាដែលរេស៊ីស្តង់សមមូលរបស់វាមានតម្លៃទាបជាងគេ ?

ក. ☐ 

ខ. ☐ 

គ. ☐ 

ឃ. ☐  ។

2. ត្រង់ស្វូមួយជាស៊ូវ៉ុលទ័រ កាលណាផលធៀប :

ក. ☐ $\frac{N_s}{N_P} < 1$

ខ. ☐ $\frac{N_s}{N_P} = 1$

គ. ☐ $\frac{N_s}{N_P} = 0$

ឃ. ☐ $\frac{N_s}{N_P} > 1$ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ចរន្តអគ្គិសនីអាចបង្កើតដែនម៉ាញេទិចមួយហៅថា................... ។

ខ. ម៉ូដែលបង្កើតឡើងដោយកាំចាំងប៉ះជាមួយនិងខ្សែកែងហៅថា....... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាគំនូសបំព្រួញត្រង់ស្វូ | ផ្នែក B ជាផលធៀបចំនួនស្ពៀដែលមានតម្លៃ | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1.   | ក. $\frac{N_S}{N_P} = 1$ | 1. → |
| 2.   | ខ. $\frac{N_S}{N_P} = 0$ | 2. → |
| 3.   | គ. $\frac{N_S}{N_P} < 1$ | 3. → |
| | ឃ. $\frac{N_S}{N_P} > 1$ | |

## III. លំហាត់

1. ម៉ូទ័រចរន្តជាប់តូចមួយបញ្ចេញអានុភាពក្នុងការលើកបន្ទុកមួយដែលមានម៉ាស 0.75kg តាមខ្សែឈរក្នុងចម្ងាយ 1.2m ។ រយៈពេលលើកគឺ 18s ។ តង់ស្យុងរវាងគោលទាំងពីរនៃម៉ូទ័រនិងចរន្តដែលឆ្លងកាត់វាមានតម្លៃថេរ គឺ 6V និង 0.30A ។ គេកំណត់ថាកម្លាំងទំនាញមកលើម៉ាស 1kg គឺស្មើ 10N ។ គណនា ៖

ក. អានុភាពនៃបន្ទុក

ខ. កម្មន្តក្នុងការលើកបន្ទុក

គ. អានុភាពបញ្ចេញដោយម៉ូទ័រ ។

2. សៀគ្វីមួយមានគ្រឿងកម្តៅ H ដែលមានរេស៊ីស្តង់ 4Ω តភ្ជាប់ជាស៊េរីជាមួយនឹងបាតេរី 12V មួយ កុងតាក់ និងរេអូស្តា $R_2$ ដែលមានរេស៊ីស្តង់ប្រហែលចន្លោះពី 0 ទៅ 20Ω (មើលរូប) ។

- គណនាតម្លៃអតិបរមានិងអប្បបរមានៃ :

ក. អាំងតង់ស៊ីតេចរន្តក្នុងសៀគ្វី

ខ. តង់ស្យុងរវាងគោលទាំងពីរនៃគ្រឿងកម្តៅ H

គ. អានុភាពស៊ីដោយគ្រឿងកម្តៅ H ។

- គូសដ្យាក្រាមនៃសៀគ្វីដែលបានបង្ហាញពីការបញ្ចូលបន្ថែមនូវអំពែម៉ែតមួយនិងវ៉ុលម៉ែតមួយ ដើម្បីវាស់អាំងតង់ស៊ីតេចរន្ត ចូលនិងតង់ស្យុងរវាងគោលនៃគ្រឿងកម្តៅ ។



# កំណែវិញ្ញាសាទី ៦

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑  ។

2. ក. ☑ $\frac{N_s}{N_P} < 1$ ។

3. ក. ដែនម៉ាញេទិចនៃចរន្តអគ្គិសនី

   ខ. ម៉ូចំណាំងប៉ះ ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

$1 \rightarrow$ គ $\quad$ $2 \rightarrow$ ឃ $\quad$ $3 \rightarrow$ ក ។

## III. កំណែ

1. ក. អានុភាពនៃបន្ទុក

តាមរូបមន្ត $W_R = F_R \times d$ ដោយ $F_R = 0.75kg \times 10N = 7.5N$

$$d = 1.2m$$

$\Rightarrow W_R = 7.5N \times 1.2m = 9N \cdot m$ ឬ $9J$

អានុភាពនៃបន្ទុក $P = \frac{W_R}{t} = \frac{9N \cdot m \text{ រឺ } J}{18s} = 0.5W$ ។

ខ. កម្មន្តក្នុងការលើកបន្ទុក គឺកម្មន្តបំពេញដោយម៉ូទ័រ ឬកម្មន្តអគ្គិសនី

$W = VIT$ ដែល $V = 6V$ , $I = 0.30A$ , $t = 18s$

$W = 6V \times 0.30A \times 18s = 32.4J$ ។

គ. អានុភាពបញ្ចេញដោយម៉ូទ័រ

តាមរូបមន្ត $P = VI = 6V \times 0.30A = 1.8W$

ឬ $P = \frac{W}{t} = \frac{32.4J}{18s} = 1.8W$ ។

2. គណនាតម្លៃអតិបរមានិងអប្បបរមានៃ

ក. អាំងតង់ស៊ីតេចរន្តក្នុងសៀគ្វី

តាមរូបមន្ត $I = \frac{V}{R}$ តែ $R = R_4 + R_2$ ដោយ $R_4 = 4\Omega$

$R_2 = 0 \rightarrow 20\Omega$

ករណី I អតិបរមាកាលណា $R_2 = 0$

$\Rightarrow I_{max} = \frac{V}{R}$ តែ $R = 4\Omega + 0 = 4\Omega$ , $V = 12V$

$\Rightarrow I_{max} = \frac{12V}{4\Omega} = 3A$

ករណី I អប្បបរមាកាលណា $R_2 = 20\Omega$

$\Rightarrow I_{min} = \frac{V}{R}$ តែ $R = 4\Omega + 20 = 24\Omega$

$\Rightarrow I_{min} = \frac{12V}{24\Omega} = 0.5A$ ។

ខ. តង់ស្យុងរវាងគោលទាំងពីរនៃគ្រឿងកម្តៅ

ករណីអតិបរមា

$V_{max} = I_{max} \times R_4 = 3A \times 4\Omega = 12V$

ករណីអប្បបរមា

$V_{min} = I_{min} \times R_4 = 0.5A \times 4\Omega = 2V$ ។

គ. អានុភាពស៊ីដោយគ្រឿងកម្ដៅ H

ករណីអតិបរមា

$$P_{max} = V_{max} \times I_{max} = 12V \times 3A = 36W$$

ករណីអប្បបរមា

$$P_{min} = V_{min} \times I_{min} = 2V \times 0.5A = 1W$$ ។

- គូសដ្យាក្រាមនៃសៀគ្វី



# វិញ្ញាសាទី ៧ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីសៀគ្វីមួយដែលមានរេស៊ីស្តរ 4 ឯកលក្ខណ៍តជាស៊េរីជាមួយបាតេរី 12V ។

តើតម្លៃមួយណាដែលជាការចង្អុលនៃទ្រនិចវ៉ុលម៉ែត $V_1$ និង $V_2$ ?

ក. ☐ $V_1 = 1V$ , $V_2 = 2V$

ខ. ☐ $V_1 = 2V$ , $V_2 = 4V$

គ. ☐ $V_1 = 3V$ , $V_2 = 6V$

ឃ. ☐ $V_1 = 4V$ , $V_2 = 8V$ ។




2. ក្នុងប្រយោគខាងក្រោមនេះ តើមួយណា***ពោលខុស***អំពីទំហំនៃរូបភាពដែលបង្កើតដោយកញ្ចក់ប្លង់ ?

ក. ☐ រូបភាពអាចខ្ពស់ជាងកញ្ចក់ប្លង់

ខ. ☐ កម្ពស់រូបភាពអាស្រ័យនឹងចម្ងាយវត្ថុ

គ. ☐ ទទឹងរូបភាពប៉ុនគ្នានឹងទទឹងវត្ថុ

ឃ. ☐ កម្ពស់របស់រូបភាពអាស្រ័យនឹងកម្ពស់របស់វត្ថុ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ឧបករណ៍អេឡិចត្រូម៉ាញេទិចដែលបំលែងពីថាមពលមេកានិចទៅជាថាមពលអគ្គិសនីហៅថា.................. ។

ខ. កម្លាំងប៉ះដែលបន្ថយល្បឿននៃចលនាហៅថា........................ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាមាត្រដ្ឋានសែលស្យុស | ផ្នែក B ជាសីតុណ្ហភាពនៃ | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. $-273^{\circ}C$ | ក. ចំណុចរលាយ | 1. → |
| 2. $0^{\circ}C$ | ខ. ចំណុចកំណក | 2. → |
| 3. $100^{\circ}C$ | គ. សូន្យដាច់ខាត | 3. → |
| | ឃ. ចំណុចចំហាយ | |

## III. លំហាត់

1. សិស្សម្នាក់ធ្វើពិសោធន៍ដូចខាងក្រោម ដើម្បីបង្ហាញផលរង្វិលនៃកម្លាំង ។

ក. ប្រសិនបើកូនទម្ងន់ W ត្រូវបានដាក់ត្រង់ចំណុចមួយចម្ងាយ 15cm ដូចបង្ហាញក្នុងរូប ។ គណនាម៉ូម៉ង់នៃកម្លាំង (ក្នុងករណីនេះកម្លាំង = W ហើយយកដៃជាអ័ក្សរង្វិលនៃបន្ទាត់មិនគិត) ។




ខ. បន្ទាប់មកគាត់ប្តូរទីតាំងកូនទម្ងន់ W ទៅចំណុច 5cm និងរកឱ្យឃើញថា ហេតុអ្វីបានជាកូនទម្ងន់ហាក់ដូចជាមានទម្ងន់ធ្ងន់ជាងមុន ?

2. អំពូលអគ្គិសនី 23V មួយត្រូវការចរន្ត 2A គឺផ្តល់ពីត្រង់សូមួយដែលភ្ជាប់ទៅនឹងប្រភពមានតង់ស្យុង 230V ។

ក. តើត្រង់សូនោះមានចំនួនស្ពៀប៉ុន្មាននៅរបុំនីមួយៗ ?

ខ. គណនាអានុភាពស៊ីដោយអំពូល ។

គ. គណនាអាំងតង់ស៊ីតេចរន្តឆ្លងកាត់របុំបឋម ។

ឃ. គណនាអានុភាពផ្តល់ដោយប្រភព ។

ង. តាមលទ្ធផលនៃសំណួរ ខ និង ឃ តើអ្នកសន្និដ្ឋានដូចម្តេច ?

# កំណែវិញ្ញាសាទី ៧

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ $V_1 = 4V$ , $V_2 = 8V$ ។
2. ក. ☑ រូបភាពអាចខ្ពស់ជាងកញ្ចក់ប្លង់ ។
3. ក. ជនិតាអគ្គិសនី

   ខ. កម្លាំងកកិត ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

1 → គ    2 → ខ    3 → ឃ ។

## III. កំណែ

1. ក. ម៉ូម៉ង់នៃកម្លាំងនៅត្រង់ចំណុច 15cm ប្រវែងដៃឃ្នាស់

   $d = 40 - 15cm = 25cm$

   $= 0.25m$

   ម៉ូម៉ង់នៃ W នៅលើអ័ក្សរង្វិល (ដៃ)

   $M = W \times d = 5N \times 0.25m = 1.25N \cdot m$ ។

   ខ. ម៉ូម៉ង់នៃកម្លាំងនៅត្រង់ចំណុច 5cm ប្រវែងដៃឃ្នាស់

   $d = 40 - 5cm = 35cm$

   $= 0.35m$

   ម៉ូម៉ង់នៃ W នៅលើអ័ក្សរង្វិល (ដៃ)

   $M = W \times d = 5N \times 0.35m = 1.75N \cdot m$ ។

   ម៉ូម៉ង់នៃ W នៅពេលកូនទម្ងន់នៅចំណុច 5cm ធំជាងម៉ូម៉ង់នៃW នៅចំណុច 15cm មានន័យថាផលរង្វិលត្រង់ចំណុច 5cm ខ្លាំងជាង ។

2. ក. ចំនួនស្ពៀនៅរបុំនីមួយៗ

តាមរូបមន្ត $\frac{V_s}{V_p} = \frac{N_s}{N_p}$ ដោយ $V_s = 23V$ , $V_p = 230V$

$\Rightarrow \frac{N_s}{N_p} = \frac{23V}{230V} = \frac{1}{10}$ ដោយផលធៀបនេះស្មើ $\frac{1}{10}$

មានន័យថាបើ $N_s = 10$ ស្ពៀ នោះ $N_p = 1$ ស្ពៀ ដូចនេះ ធំជាង $N_s 10$ ដង ។

ខ. អានុភាពស៊ីដោយអំពូល

តាមរូបមន្ត $P_s = V_s \times I_s$ ដោយ $V_s = 23V$ , $I_s = 2A$

$P_s = 23V \times 2A = 46W$ ។

គ. អាំងតង់ស៊ីតេចរន្តឆ្លងកាត់របុំបឋម

តាមរូបមន្ត $\frac{V_s}{V_p} = \frac{I_p}{I_s} \Rightarrow I_p = \frac{V_s \times I_s}{V_p}$ ដោយ $V_s = 25V$, $V_p = 230V$, $I_s = 2A$

$\Rightarrow I_p = \frac{23V \times 2A}{230V} = 0.2A$ ។

ឃ. អានុភាពផ្តល់ដោយប្រភព

តាមរូបមន្ត $P_p = V_p \times I_p$

$\Rightarrow P_p = 230V \times 0.2A = 46W$ ។

ង. សន្និដ្ឋាន

ដោយ $P_s = P_p = 46W$

នោះមានន័យថាទិន្នផលនៃត្រង់ស្វូ គឺ $100\%$ ។

# វិញ្ញាសាទី ៨ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. កម្លាំងពីរមានអំពើរលើអង្គធាតុមួយដែលមានម៉ាស M ដូចបង្ហាញក្នុងរូប ។ តើរូបមួយណាដែលបង្ហាញពីកម្លាំងទាំងពីរមានអំពើលើអង្គធាតុ ហើយធ្វើឱ្យអង្គធាតុមានសំទុះកើនឡើង ?

ក. ☐ 


ខ. ☐ 


គ. ☐ 


ឃ. ☐  ។


2. បណ្តាបង្គុំរេស៊ីស្តរខាងក្រោម ។ តើបង្គុំមួយណាដែលមានរេស៊ីស្តង់សមមូលមានតម្លៃតូចជាងគេ ?

ក. ☐ 


ខ. ☐ 


គ. ☐ 


ឃ. ☐  ។


3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អ័ក្សនឹងមួយដែលឃ្នាស់អាចចល័តជុំវិញហៅថា.................. ។

ខ. កាលណាធ្វើបម្រែបម្រួលអាំងឌុចស្យុងម៉ាញេទិចក្នុងរបុំខ្សែចម្លង គេឃើញមានចរន្តអគ្គិសនីកើតឡើង ចរន្តនោះហៅថា........................ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាគំនូសបំព្រួញនៃបាច់ពន្លឺ | ផ្នែក B ជាបាតុភូតនៃ | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. <br>2. <br>3.  | ក. ដំណាលត្រង់នៃពន្លឺ<br>ខ. ចំណាំងផ្លាតនៃពន្លឺ<br>គ. បន្សាយនៃពន្លឺ<br>ឃ. ចំណាំងបែរនៃពន្លឺ | 1. →<br>2. →<br>3. → |

## III. លំហាត់ (ប្រឡងជ្រើសរើសសិស្សពូកែ)

1. ល្បឿននៃពន្លឺដាលក្នុងខ្យល់ស្មើនឹង $3\times10^{8}\,ms^{-1}$ ។ គណនា ៖

ក. ល្បឿនពន្លឺដាលឆ្លងកាត់កែវ បើសន្ទស្សន៍នៃចំណាំងបែរស្មើនឹង 1.5 ។

ខ. គណនាជំហាននៃពន្លឺដាលក្នុងខ្យល់និងក្នុងកែវ បើគេដឹងថាប្រេកង់នៃពន្លឺស្មើនឹង $6\times10^{14}Hz$ ។

2. គេឱ្យកម្លាំង $F = 40N$ មួយដូចបង្ហាញក្នុងរូប ។ ចូរកំណត់ម៉ូម៉ង់នៃកម្លាំង F នោះធៀបនឹងអ័ក្សរង្វិលដែលកែងនឹងប្លង់នៃក្រដាស ហើយកាត់តាមចំណុច ៖

ក. A

ខ. B

គ. C ។



# កំណែវិញ្ញាសាទី ៨

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑ $\xrightarrow{15N} \boxed{M} \xrightarrow{15N}$ ។

2. ឃ. ☑ 

។

3. ក. អ័ក្សទម្រ

ខ. ចរន្តអាំងឌុចស្យុង ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ខ　　$2 \rightarrow$ គ　　$3 \rightarrow$ ឃ ។

## III. កំណែ

1. ក. ល្បឿនពន្លឺដាលឆ្លងកាត់កែវ

តាមរូបមន្ត $n = \frac{c}{v} \Rightarrow v_{\text{កែវ}} = \frac{c}{n}$ ដោយ $n = 1.5$

$c = 3 \times 10^8 m/s$

$\Rightarrow v_{\text{កែវ}} = \frac{3 \times 10^8 m/s}{1.5} = 2 \times 10^8 m/s$ ។

ខ. ជំហានពន្លឺដាលក្នុងខ្យល់និងក្នុងកែវ

- ករណីក្នុងខ្យល់

$c = f \times \lambda \Rightarrow \lambda = \frac{c}{f}$ ដោយ $c = 3 \times 10^8 m/s$

$f = 6 \times 10^{14} Hz$

$\Rightarrow \lambda = \frac{3 \times 10^8 m/s}{6 \times 10^{14} Hz} = 5 \times 10^{-7} m$ ។

- ករណីក្នុងកែវ

(1). $n = \frac{\lambda_{ខ្យល់}}{\lambda_{កែវ}} \Rightarrow \lambda_{កែវ} = \frac{\lambda_{ខ្យល់}}{n}$ ដោយ $n = 1.5$

$\lambda_{ខ្យល់} = 5 \times 10^{-7}m$

$\Rightarrow \lambda_{កែវ} = \frac{5 \times 10^{-7}m}{1.5} = 3.3 \times 10^{-7}m$ ។

(2). $v_{កែវ} = f \times \lambda_{កែវ} \Rightarrow \lambda_{កែវ} = \frac{v_{កែវ}}{f}$ ដោយ $v_{កែវ} = 2 \times 10^{8}m/s$

$f = 6 \times 10^{14}Hz$

$\Rightarrow \lambda_{កែវ} = \frac{2 \times 10^{8}m/s}{6 \times 10^{14}Hz} = 3.3 \times 10^{-7}m$ ។

2. ក. ម៉ូម៉ង់នៃកម្លាំង F ធៀបនឹងអ័ក្សរង្វិលត្រង់ A

យើងអាចបំបែកកម្លាំង $F = 40N$ ជាកម្លាំងផ្គុំកែងពីរ គឺ $F_1$ និង $F_2$

ដែល $F_1 = F\cos 30°$ , $F_2 = F\sin 30°$

$F_1 = 40N \times \frac{\sqrt{3}}{2} = 40 \times 0.86 = 34.6N$




- $M_1 = F_1 \times d$ ដោយ $d = AD = 2m$

$\Rightarrow M_1 = 34.6N \times 2m = 69.28N \cdot m$

- $M_2 = F_2 \times d$ ដោយ $d = 0$ (ដៃឃ្នាស់នៃកម្លាំងត្រួតនឹងអ័ក្សរង្វិល)

$\Rightarrow M_2 = 0$

ដូចនេះ $M_A = M_1 + M_2 = 69.28N \cdot m + 0 = 69.28N \cdot m$

ហើយ $M_A$ មានទិសដៅតាមទិសដៅរង្វិលនៃទ្រនិចនាឡិកា ។

ខ. ម៉ូម៉ង់នៃកម្លាំង F ធៀបនឹងអ័ក្សរង្វិលត្រង់ B

តាមរូបមន្តយើងបាន $\tan 30° = \frac{AD}{AO}$

$\Rightarrow AO = \frac{AD}{\tan 30°}$ តែ $\tan 30° = \frac{1}{\sqrt{3}}$

$AD = 2m$



$$\Rightarrow AO = \frac{2}{\frac{1}{\sqrt{3}}} = 2\times\sqrt{3} = 3.464$$

ដូចនេះ $AO = 2m \times 1.732 = 3.464m$

$$OB = AB - AO = 6m - 3.464m = 2.535m$$

តាម $\cos 60°$ យើងបាន

$\cos 60° = \frac{BH}{OB} \Rightarrow BH = OB \times \cos 60°$ តែ $\cos 60° = \frac{1}{2}$

$\Rightarrow BH = 2.535m \times 0.5 = 1.267m$

$M_B = F \times BH = 40N \times 1.267m = 50.71N \cdot m$

ម៉ូម៉ង់នៃ F ធៀបនឹងអ័ក្សរង្វិលត្រង់ B មានទិសដៅច្រាសនឹងទិសដៅរង្វិលនៃទ្រនិចនាឡិកា ។

គ. ម៉ូម៉ង់នៃកម្លាំង F ធៀបនឹងអ័ក្សរង្វិលត្រង់ C

យើងបន្លាយកម្លាំង F រួចទម្លាក់ចំណោលកែងពីចំណុច C ទៅលើ F យើងបាន :

$CH = CD \times \sin 30°$ តែ $\sin 30° = \frac{1}{2}$

$$CD = 6m$$




ដូចនេះ $CH = 6m \times \frac{1}{2} = 3m$

$M_c = F \times d$ តែ $d = CH = 3m$

ដូចនេះ $M_c = 40N \times 3m = 120N \cdot m$

ម៉ូម៉ង់នៃ F ធៀបនឹងអ័ក្សរង្វិលត្រង់ C មានទិសដៅច្រាសនឹងទិសដៅរង្វិលនៃទ្រនិចនាឡិកា ។

# វិញ្ញាសាទី ៩ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើបណ្ដាទំហំខាងក្រោម ទំហំមួយណាដែល**មិនមែន**ជាទំហំស្កាលែ ?

ក. ☐ ម៉ាស

ខ. ☐ ថាមពល

គ. ☐ អានុភាព

ឃ. ☐ កម្លាំង ។

2. តើគេត្រូវប្រើឧបករណ៍អ្វី ដើម្បីវាស់ថាមពលអគ្គិសនីស៊ីដោយគ្រឿងទទួល ?

ក. ☐ ឪសង់ទ័រអគ្គិសនី

ខ. ☐ កុងទ័រអគ្គិសនី

គ. ☐ ម៉ូទ័រអគ្គិសនី

ឃ. ☐ អាល់ទែណាទ័រអគ្គិសនី ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. គ្រប់ដែក ឬដែកថែបដែលស្ថិតក្នុងដែនម៉ាញេទិចតែងតែរងនូវកម្លាំងមួយ កម្លាំងនោះហៅថា.................. ។

ខ. ថាមពលដែលអាស្រ័យនឹងទីតាំងដែលវត្ថុស្ថិតនៅធៀបនឹងផ្ទៃផែនដីហៅថា........................ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាមាត្រដ្ឋានកែលវិន | ផ្នែក B ជាមាត្រដ្ឋានសែលស្យុសត្រូវនឹង | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. O K<br>2. 273K<br>3. 1K | ក. -272°C<br>ខ. –273°C<br>គ. 1°C<br>ឃ. 0°C | 1. →<br>2. →<br>3. → |

## III. លំហាត់

1. ជាងជួសជុលម្នាក់ប្រើរ៉កមួយ ដើម្បីលើកម៉ាស៊ីនចេញពីរថយន្ត។ ម៉ាស៊ីននោះមានទម្ងន់ 500N និងត្រូវលើកកម្ពស់ 2m ។ ជាងនោះបានប្រើកម្លាំង 200N ទៅលើខ្សែរ៉កដែលទាញចុះក្រោមចម្ងាយ 10m ។ គណនា :

ក. កម្មន្តបំពេញដោយម៉ាស៊ីនក្នុងការលើកវា

ខ. កម្មន្តបញ្ចេញដោយជាង

គ. ទិន្នផលនៃរ៉ក ។

2. រូបនេះបង្ហាញពីសៀគ្វីមួយមានបង្គុំរេស៊ីស្តរដែលមានរេស៊ីស្តង់ $R_1 = 0.1\Omega$ ; $R_2 = 1\Omega$ , $R_3 = 10\Omega$ ; $R_4 = 100\Omega$ ។ គណនារេស៊ីស្តង់សមមូលនៃសៀគ្វីនិងអាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តរនីមួយៗ កាលណាគេភ្ជាប់សៀគ្វីនេះទៅនឹងតង់ស្យុង 5V រវាងចំណុច :

ក. a និង b

ខ. a និង c

គ. a និង d ។



# កំណែវិញ្ញាសាទី ៩

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ កម្លាំង ។
2. ខ. ☑ កុងទ័រអគ្គិសនី ។
3. ក. ☑ កម្លាំងម៉ាញេទិច

   ខ. ☑ ថាមពលប៉ូតង់ស្យែល ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

$1 \rightarrow$ ខ　　$2 \rightarrow$ ឃ　　$3 \rightarrow$ ក ។

## III. កំណែ

1. ក. កម្មន្តបំពេញដោយម៉ាស៊ីន ឬកម្មន្តទប់

   តាមរូបមន្ត $W_R = F_R \times d$ ដោយ $F_R = 500N$ , $d = 2m$

   $\Rightarrow 500N \times 2m = 1000N \cdot m$ ឬ $1000J$ ។

   ខ. កម្មន្តបំពេញដោយជាង ឬកម្មន្តចលករ

   $W_E = F_E \times d$ ដោយ $F_E = 200N$ , $d = 10m$

   $W_E = 200N \times 10m = 2000N \cdot m$ ឬ $2000J$ ។

   គ. ទិន្នផលនៃរ៉ក

   តាមរូបមន្ត $e\% = \dfrac{W_R}{W_E} = \dfrac{1000J}{2000J} = 0.5 = 50\%$ ។

2. ក. កាលណាគេភ្ជាប់តង់ស្យុងទៅនឹងចំណុច a និង b រេស៊ីស្តរ

$R_2$ , $R_3$ , $R_4$ តជាស៊េរី : $R_{2,3,4} = R_2 + R_3 + R_4$

$= 1\Omega + 10\Omega + 100\Omega = 111\Omega$

$R_1$ និង $R_{2,3,4}$ តជាខ្នែង

$$\frac{1}{R} = \frac{1}{R_1} + \frac{1}{R_{2,3,4}} \Rightarrow R = \frac{R_1 \times R_{2,3,4}}{R_1 + R_{2,3,4}}$$

$$R = \frac{0.1\Omega \times 111\Omega}{0.1\Omega + 111\Omega} = 0.09\Omega$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_1$

$$I_1 = \frac{V}{R_1} = \frac{5v}{0.1\Omega} = 50A$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_{2,3,4}$

$$I_2 = \frac{V}{R_{2,3,4}} = \frac{5v}{111\Omega} = 0.04A$$ ។

ខ. កាលណាគេភ្ជាប់តង់ស្យុងទៅនឹងចំណុច a និង c នៃសៀគ្វីនោះ រេស៊ីស្តរ $R_1$ និង $R_2$ តជាស៊េរី ហើយ $R_3$ និង $R_4$ តជាស៊េរីដែរ :

$R_{1,2} = R_1 + R_2 = 0.1\Omega + 1\Omega = 1.1\Omega$

$R_{3,4} = R_3 + R_4 = 10\Omega + 100\Omega = 110\Omega$

$R_{1,2}$ និង $R_{3,4}$ តជាខ្នែង :

$$R = \frac{R_{1,2} \times R_{3,4}}{R_{1,2} + R_{3,4}} = \frac{1.1\Omega \times 110\Omega}{1.1\Omega + 110\Omega} = \frac{121\Omega}{111.1} = 1.08\Omega$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_{1,2}$

$$I_1 = \frac{V}{R_{1,2}} = \frac{5V}{1.1\Omega} = 4.54A$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_{3,4}$

$$I_2 = \frac{V}{R_{3,4}} = \frac{5V}{110\Omega} = 0.04A$$ ។

គ. កាលណាគេភ្ជាប់តង់ស្យុង 5V ទៅនឹងចំណុច a និង d នៃសៀគ្វីនោះ

រេស៊ីស្តរ $R_1$ , $R_2$ , $R_3$ តជាស៊េរី

$$R_{1,2,3} = R_1 + R_2 + R_3 = 0.1\Omega + 1\Omega + 10\Omega = 11.1\Omega$$

រេស៊ីស្តរ $R_{1,2,3}$ និង $R_4$ តជាខ្នែង

$$R = \frac{R_{1,2,3} \times R_4}{R_{1,2,3} + R_4} = \frac{11.1\Omega \times 100\Omega}{11.1\Omega + 100\Omega} = \frac{1110}{111.1} = 9.99\Omega$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_{1,2,3}$

$$I_1 = \frac{V}{R_{1,2,3}} = \frac{5V}{11.1\Omega} = 0.45A$$

- អាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_4$

$$I_2 = \frac{V}{R_4} = \frac{5V}{110\Omega} = 0.05A$$ ។

# វិញ្ញាសាទី ១០ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដ្យាក្រាមនេះបង្ហាញពីកម្លាំងផ្គុំកែងពីរដែលមានអាំងតង់ស៊ីតេ 9N និង 12N ។ តើបណ្ដាដ្យាក្រាមខាងក្រោមមួយណាដែលជាកម្លាំងផ្គួបនៃកម្លាំង ផ្គុំកែងខាងលើ ?




ក. ☐ 


ខ. ☐ 


គ. ☐ 


ឃ. ☐ 

។

2. ក្មេងស្រីម្នាក់ទម្ងន់ 400N រត់ឡើងលើតាមកាំជណ្ដើរ ប្រើរយៈពេល 4s ដូចបង្ហាញក្នុងរូប ។ តើទំហំខាងក្រោមនេះ មួយណាជាល្បឿនមធ្យមរបស់ក្មេងស្រីនោះ ?




ក. ☐ 0.75m/s

ខ. ☐ 0.8m/s

គ. ☐ 1.25m/s

ឃ. ☐ 1.33m/s ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ចម្ងាយពីចំណុចទម្រទៅទិសនៃកម្លាំងចលករហៅថា.................. ។

ខ. បើអ្នកឆ្លុះកញ្ចក់ (កញ្ចក់ប្លង់) រួចអ្នកលើកដៃស្ដាំ នោះអ្នកនឹងឃើញរូបភាពអ្នកលើកដៃឆ្វេង ។ កញ្ចក់បានប្ដូររូបភាពពីឆ្វេងទៅស្ដាំ គេហៅរូបភាពនេះថា.................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A ជាល្បឿនដំណាលនៃពន្លឺ | ផ្នែក B ជាអង្គធាតុថ្លាដូចជា | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. $225 \times 10^6 m/s$ | ក. ខ្យល់ | 1. $\rightarrow$ |
| 2. $200 \times 10^6 m/s$ | ខ. ពេជ្រ | 2. $\rightarrow$ |
| 3. $120 \times 10^6 m/s$ | គ. ទឹក | 3. $\rightarrow$ |
| | ឃ. កែវ | |

## III. លំហាត់

1. គេមានសៀគ្វីមួយដូចរូប ដែលមានរេស៊ីស្តង់ 6Ω និង 3Ω តជាខ្នែង និងរេស៊ីស្តង់ 8Ω មួយទៀតតជាស៊េរីជាមួយនឹងបង្គុំជាខ្នែងនៃរេស៊ីស្តង់ពីមុន ។ គេដឹងថាចរន្ត 2A បានឆ្លងកាត់រេស៊ីស្តរដែលមានរេស៊ីស្តង់ 3Ω ។ គណនា :




ក. រេស៊ីស្តង់សមមូលនៃសៀគ្វី

ខ. តង់ស្យុងរវាងគោលទាំងពីរនៃសៀគ្វី

គ. អាំងតង់ស៊ីតេចរន្តដែលឆ្លងកាត់រេស៊ីស្តង់ 8Ω ។

2. គណនាម៉ូម៉ង់នៃកម្លាំង លើអ័ក្សរង្វិលធៀបដែលមានទិសដៅកែងនឹងប្លង់នៃក្របជាសកាត់តាមចំណុច :




ក. A ខ. B

គ. D ឃ. O ដែល O ជាទីប្រជុំទម្ងន់នៃចតុកោណកែង ABCD (មើលរូប) ។

# កំណែវិញ្ញាសាទី ១០

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ $\nearrow$ 15N ។

2. គ. ☑ $1.25\text{m/s}$ ។

3. ក. ដៃឃ្នាស់ចលករ

   ខ. រូបភាពច្រាសខាង ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ គ    $2 \rightarrow$ ឃ    $3 \rightarrow$ ខ ។

## III. កំណែ

1. ក. រេស៊ីស្តង់សមមូលនៃសៀគ្វី

   ដោយ $R_1$ និង $R_2$ តជាខ្នែងដូចនេះ

   $R_{1,2} = \dfrac{R_1 \times R_2}{R_1 + R_2}$ តែ $R_1 = 6\Omega$ , $R_2 = 3\Omega$

   យើងបាន $R_{1,2} = \dfrac{6 \times 3}{6 + 3} = 2\Omega$

   តែ $R_{1,2}$ និង $R_3$ តជាស៊េរី ដូចនេះរេស៊ីស្តង់សមមូលនៃសៀគ្វី

   $R = R_{1,2} + R_3$ ដោយ $R_{1,2} = 2\Omega$ , $R_3 = 8\Omega$

   ដូចនេះ $R = 2\Omega + 8\Omega = 10\Omega$ ។

   ខ. តង់ស្យុងនៃគោលទាំងពីរនៃសៀគ្វី

   តាមរូបមន្ត :

   $V = I \times R$ ដោយ $I = 2\text{A}$ , $R = 10\Omega$

   $\Rightarrow V = 2\text{A} \times 10\Omega = 20\text{V}$ ។

គ. អាំងតង់ស៊ីតេចរន្តឆ្លងកាត់រេស៊ីស្តង់ $3\Omega$

ដោយ $R_1$ និង $R_2$ តជាខ្នែង ដូចនេះតង់ស្យុងរវាងគោលទាំងពីរនៃ $R_1$ និង $R_2$ ស្មើគ្នា យើងអនុវត្តតាមរូបមន្ត :

$V = I \times R_{1,2} = 2A \times 2\Omega \Rightarrow V = 4V$

ដូចនេះអាំងតង់ស៊ីតេចរន្តឆ្លងកាត់ $R_2 = 3\Omega$ អនុវត្តតាមរូបមន្ត

$I = \frac{V}{R} = \frac{4V}{3\Omega} = 1.33A$ ។

2\. ក. ម៉ូម៉ង់នៃកម្លាំង 20N ធៀបនឹងអ័ក្សរង្វិលត្រង់ A

តាមរូបមន្ត : $M_A = F \times d_A$ ដោយ $d_A = 0$ (ដៃឃ្នាស់ត្រួតស៊ីនឹងអ័ក្សរង្វិល) $\Rightarrow M_A = 20N \times 0 = 0$ ។

ខ. ម៉ូម៉ង់នៃកម្លាំង 20N ធៀបនឹងអ័ក្សរង្វិលត្រង់ B

តាមរូបមន្ត :

$M_B = F \times d_B$ ដោយ $F = 20N$ , $d_B = 6m$

$\Rightarrow M_B = 20N \times 6m = 120N \cdot m$ ។

គ. ម៉ូម៉ង់នៃកម្លាំង 20N ធៀបនឹងអ័ក្សរង្វិលត្រង់ D

តាមរូបមន្ត :

$M_D = F \times d_D$ ដោយ $d_D = 0$ (ព្រោះដៃឃ្នាស់ត្រួតស៊ីនឹងអ័ក្សរង្វិល)

ដូចនេះ $M_D = 20N \times 0 = 0$ ។

ឃ. ម៉ូម៉ង់នៃកម្លាំង 20N ធៀបនឹងអ័ក្សរង្វិលត្រង់ 0

តាមសម្មតិកម្ម 0 ទីប្រជុំទម្ងន់នៃចតុកោណកែង ដូចនេះវាជាចំណុចកណ្តាលនៃចតុកោណកែង ។

$M_0 = F \times d_0$ ដោយ $d_0 = \frac{1}{2}AB = 3m$

$M_0 = 20N \times 3m = 60N \cdot m$ ។

# វិញ្ញាសាទី ១ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើធាតុគីមីក្នុងតារាងខួបមានចំនួនប៉ុន្មាន ?

   ក. ☐ 106 ធាតុ    ខ. ☐ 109 ធាតុ

   គ. ☐ 110 ធាតុ    ឃ. ☐ 111 ធាតុ ។

2. តើទឹកកំបោរថ្លាប្រើសម្រាប់ធ្វើអត្តសញ្ញាណឧស្ម័នណាមួយក្នុងចំណោមឧស្ម័នខាងក្រោម ?

   ក. ☐ ឧស្ម័នអុកស៊ីសែន    ខ. ☐ ឧស្ម័នអ៊ីដ្រូសែន

   គ. ☐ ឧស្ម័នកាបូនឌីអុកស៊ីត    ឃ. ☐ ឧស្ម័នក្លរ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

   ក. ប្រតិកម្មលោហៈអាល់កាឡាំងជាមួយទឹកជាប្រតិកម្មប្រព្រឹត្តទៅយ៉ាង... ។

   ខ. ពពួកអាឡូសែនទាំងអស់ជាសារធាតុ................ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ធាតុនៅក្នុងក្រុមទី 1<br>2. ធាតុនៅក្នុងក្រុមទី 17<br>3. ធាតុនៅក្នុងក្រុមទី 18 | ក. ជាធាតុដែលសកម្មតិចជាងគេបំផុតនៅក្នុងតារាងខួប<br>ខ. ជាក្រុមលោហៈឆ្លង<br>គ. ទន់អាចកាត់ ឬចិតនឹងកាំបិតបាន<br>ឃ. មានប្រតិកម្មជាមួយលោហៈភាគច្រើនបង្កើតជាអំបិល | 1. →<br>2. →<br>3. → |

## III. ចូរសរសេរនិងថ្លឹងសមីការខាងក្រោម

1. $Na_{(s)} + H_2O_{(l)} \rightarrow$
2. $K_{(s)} + H_2O_{(l)} \rightarrow$
3. $O_{2(g)} + H_{2(g)} \rightarrow$
4. $CO_{2(g)} + H_2O_{(l)} \rightarrow$
5. $SO_{3(g)} + H_2O_{(l)} \rightarrow$

## IV. លំហាត់

1. គេយកកាបូន 34g ឱ្យមានចំហេះសព្វជាមួយអុកស៊ីសែន ។ គណនា ៖
   ក. ម៉ាសអុកស៊ីសែនដែលចាំបាច់សម្រាប់ចំហេះកាបូន ។
   ខ. ម៉ាសនិងមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលកើតក្រោយប្រតិកម្ម ។ (នៅលក្ខខណ្ឌធម្មតាឧស្ម័នកាបូនឌីអុកស៊ីត 44g មានមាឌ 22.4L ។
   (C = 12 , O = 16 )
2. ក. បើគេដាក់បំណែកកាល់ស្យូមទៅក្នុងទឹក តើគេសង្កេតឃើញមានអ្វីកើតឡើង ?
   ខ. ចូរសរសេរសមីការតាងប្រតិកម្មនឹងប្រាប់ឈ្មោះអង្គធាតុកកើតក្រោយប្រតិកម្ម ។
   គ. គណនាមាឌឧស្ម័នដែលកកើត ? បើគេប្រើកាល់ស្យូម 0.4g ឱ្យធ្វើប្រតិកម្ម ។ ( Ca = 40 , $H_2$=2g មានមាឌ = 22.4L )

# កំណែវិញ្ញាសាទី ១

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ 109 ធាតុ ។
2. គ. ☑ ឧស្ម័នកាបូនឌីអុកស៊ីត ។
3. ក. ខ្លាំងក្លា

   ខ. ពុល ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ គ    $2 \rightarrow$ ក    $3 \rightarrow$ ខ ។

## III. ចម្លើយសមីការ

1. $2Na_{(s)} + 2H_2O_{(l)} \rightarrow 2NaOH_{(aq)} + H_{2(g)}\nearrow$
2. $2K_{(s)} + 2H_2O_{(l)} \rightarrow 2KOH_{(aq)} + H_{2(g)}\nearrow$
3. $O_{2(g)} + 2H_{2(g)} \rightarrow 2H_2O_{(l)}$
4. $CO_{2(g)} + H_2O_{(l)} \rightarrow H_2CO_{3(aq)}$
5. $SO_{3(g)} + H_2O_{(l)} \rightarrow H_2SO_{4(aq)}$

## IV. ចម្លើយលំហាត់

1. ក. ម៉ាសអុកស៊ីសែនចាំបាច់សម្រាប់ចំហេះកាបូន

   សមីការប្រតិកម្ម $C_{(s)} + O_{2(g)} \rightarrow CO_{2(g)}$

   34g

   តាមសមីការ ៖

   បើគេប្រើកាបូន $C = 12g$ គេត្រូវការអុកស៊ីសែន $O_2 = 32g$

   បើគេប្រើកាបូន 34g គេត្រូវការអុកស៊ីសែន $O_2 = m_g$ ?

តាមសមាមាត្រកំណត់

$\frac{12}{34} = \frac{32}{m} \Rightarrow m = \frac{32 \times 34}{12} = 90.66g$

ដូច្នេះម៉ាស $O_2$ ចាំបាច់សម្រាប់ចំហេះ $m_{(o_2)} = 90.66g$ ។

ខ. ម៉ាសនិងមាឌឧស្ម័ន $CO_2$ ដែលកកើតក្រោយប្រតិកម្ម :

ម៉ាស $CO_2$

តាមសមីការ :

គេប្រើ $C = 12g$ ទទួលបានឧស្ម័ន $CO_2 = 44g$

បើគេប្រើ $C = 34g$ គេទទួលបានឧស្ម័ន $CO_2 = m_g$ ?

យើងបាន $\frac{12}{34} = \frac{44}{m} \Rightarrow m = \frac{34 \times 44}{12} = 124.66g$

រកមាឌ $CO_2$ :

ដោយដឹងថា $CO_2$ : 44g មានមាឌ 22.4L

ដូច្នេះបើ $CO_2$ : 126.66g មានមាឌ $V_{(CO_2)} = ?$

យើងបាន $\frac{44}{124.66} = \frac{22.4}{V_{(CO_2)}} \Rightarrow V_{(CO_2)} = \frac{124.66 \times 22.4}{44}$

$V_{(CO_2)} = 63.46L$ ។

2. ក. បើគេដាក់បំណែកកាល់ស្យូមទៅក្នុងទឹក គេសង្កេតឃើញមានឧស្ម័នអ៊ីដ្រូសែនភាយឡើង ។

ខ. សរសេរសមីការតាងប្រតិកម្មនិងប្រាប់ឈ្មោះអង្គធាតុកកើត

សមីការប្រតិកម្ម :

$Ca_{(s)} + 2H_2O_{(l)} \rightarrow Ca(OH)_{2(aq)} + H_{2(g)} \nearrow$

អង្គធាតុកកើតក្រោយប្រតិកម្ម :

$Ca(OH)_2$ កាល់ស្យូមអ៊ីដ្រុកស៊ីត និងឧស្ម័នអ៊ីដ្រូសែន $(H_2)$ ។

គ. គណនាមាឌឧស្ម័នដែលកកើត ៖

បើគេប្រើកាល់ស្យូម $0.4g$

រកមាឌឧស្ម័នអ៊ីដ្រូសែន ៖

តាមសមីការ ៖

$$Ca_{(s)} + 2H_2O_{(l)} \rightarrow Ca(OH)_{2(aq)} + H_{2(g)}\nearrow$$

$40g$ $\qquad\qquad\qquad\qquad$ $2g$

បើគេប្រើ $Ca$ ៖ $40g$ គេទទួលបាន $H_2 = 2g$

$Ca$ ៖ $0.4g$ គេទទួលបាន $H_2 = m_g$ ?

យើងបាន $\frac{40}{0.4} = \frac{2}{m} \Rightarrow m = \frac{0.4 \times 2}{40} = 0.02g$

រកមាឌអ៊ីដ្រូសែន ៖

តាមបម្រាប់យើងដឹងថា $H_2 = 2g$ មានមាឌ $22.4L$

តែបើ $H_2 = 0.02g$ មានមាឌ $V_{(H_2)} = ?$

យើងបាន $\frac{2}{0.02} = \frac{22.4}{V} \Rightarrow V = \frac{22.4 \times 0.02}{2}$

$V_{(H_2)} = 0.224L$ ។

## វិញ្ញាសាទី ២ (រយៈពេល 45 នាទី 35 ពិន្ទុ)

### I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើសារធាតុខាងក្រោមនេះ ណាមួយដែលជាអំបិល ?

ក. ☐ Fe ខ. ☐ $CO_2$

គ. ☐ $ZnCl_2$ ឃ. ☐ $Mg(OH)_2$ ។

2. តើគេប្រើទឹកកំបោរថ្លាសម្រាប់ផ្ទៀងអត្តសញ្ញាណសារធាតុណាមួយ ?

ក. ☐ $H_2$ ខ. ☐ $Cl_2$

គ. ☐ $N_2$ ឃ. ☐ $CO_2$ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អុកស៊ីតជាសមាសធាតុ ......... ដែលក្នុងនោះមានធាតុមួយជា ....... ។

ខ. អាស៊ីតជាសារធាតុដែលមាន .......... ក្នុងម៉ូលេគុលវា ហើយមានអំពើជាមួយ ....... ឱ្យផលជាអំបិលនិងទឹក ។

### II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ប្រាក់ស៊ុលផាត | ក. $MgSO_4$ | 1. → |
| 2. សូដ្យូមអាសេតាត | ខ. $Fe(OH)_2$ | 2. → |
| 3. ម៉ាញេស្យូមស៊ុលផាត | គ. $Mg(NO_3)_2$ | 3. → |
| 4. ដែក II អ៊ីដ្រុកស៊ីត | ឃ. $CH_3COONa$ | 4. → |
| | ង. $Ag_2SO_4$ | |

## III. លំហាត់

1. ផើងមួយមានផ្ទុកសូលុយស្យុងអាស៊ីតក្លរីឌ្រិច ដែលនៅក្នុងនោះមានអាស៊ីតសុទ្ធចំនួន 25g ។ គេបន្សាបសូលុយស្យុងអាស៊ីតនេះដោយចាក់សូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ។ ចូលគណនា :

   ក. ម៉ាសសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតដែលត្រូវប្រើ ។

   ខ. រកម៉ាសអំបិលដែលកកើត

   (គេឱ្យ : H = 1 , O = 16 , Na = 23 , Cl = 35.5 )

2. គេដាក់កាបូន 24g ឱ្យមានចំហេះសព្វជាមួយអុកស៊ីសែន ។ គណនា :

   ក. ម៉ាសអុកស៊ីសែនចាំបាច់សម្រាប់ចំហេះកាបូន ។

   ខ. ម៉ាស និងមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលទទួលបានក្រោយប្រតិកម្ម(គេដឹងថា នៅលក្ខខណ្ឌធម្មតាឧស្ម័នកាបូនឌីអុកស៊ីត 44g មានមាឌស្មើ 22.4L , C = 12 , O = 16 ) ។

# កំណែវិញ្ញាសាទី ២

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ $ZnCl_2$ ។

2. ឃ. ☑ $CO_2$ ។

3. ក. ទ្វេធាតុ , អុកស៊ីសែន ។

   ខ. អ៊ីដ្រូសែន , បាស ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ង $2 \rightarrow$ ឃ $3 \rightarrow$ ក $4 \rightarrow$ ខ ។

## III. ចម្លើយលំហាត់

1. សមីការតាងប្រតិកម្ម

$$HCl + NaOH \rightarrow NaCl + H_2O$$

36.5g 40g 58.5g

25g $m_{NaOH}$ ? $m_{NaCl}$ ?

ក. គណនាម៉ាសសូដ្យូមអ៊ីដ្រុកស៊ីត

តាមសមីការ : HCl 36.5g ត្រូវការ NaOH 40g

បើ HCl 25g ត្រូវការ NaOH $= m_g$ ?

តាមសមីការ : $m_{NaOH} = \frac{40 \times 25}{36.5} = 27.39g$

ដូច្នេះ $m_{NaOH} = 27.39g$ ។

ខ. រកម៉ាសអំបិលដែលកើតក្រោយប្រតិកម្ម

តាមសមីការ :

យើងប្រើ 36.5g HCl គេទទួលបាន NaCl 58.5g

បើ 25g HCl គេទទួលបាន $m_{NaCl} = ?$

$$\Rightarrow m_{NaCl} = \frac{25 \times 58.5}{36.5} = 40.07g$$

ដូច្នេះ $m_{NaCl} = 40.07g$ ។

2. សមីការតាងប្រតិកម្ម

$C + O_2 \rightarrow CO_2$

12g 32g 44g

24g $m_{O_2} = ?$ $m_{CO_2} = ?$

ក. គណនាម៉ាសអុកស៊ីសែនត្រូវការចាំបាច់សម្រាប់ចំហេះកាបូន

តាមសមីការ :

ចំហេះកាបូន 12g ត្រូវការ $O_2$ ចំនួន 32g

បើចំហេះកាបូន 24g ត្រូវការ $m_{O_2} = ?$

$$m_{O_2} = \frac{32 \times 24}{12} = 64g$$

ដូច្នេះ $m_{O_2} = 64g$ ។

ខ. គណនាម៉ាសកាបូនឌីអុកស៊ីតកកើតក្រោយប្រតិកម្ម

តាមសមីការ :

ចំហេះកាបូន 12g ឱ្យកាបូនឌីអុកស៊ីត 44g

បើចំហេះកាបូន 24g ឱ្យកាបូនឌីអុកស៊ីត $m_{CO_2} = ?$

$$\Rightarrow m_{CO_2} = \frac{24 \times 44}{12} = 88g$$

ដូច្នេះ $m_{CO_2} = 88g$ ។

គណនាមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលទទួលបានក្រោយប្រតិកម្ម

ដោយកាបូនឌីអុកស៊ីត 44g មានមាឌ 22.4L

បើកាបូនឌីអុកស៊ីត 88g មានមាឌ $V_{CO_2} = ?$

$$\Rightarrow V_{CO_2} = \frac{88 \times 22.4}{44} = 44.8L$$

ដូច្នេះ $V_{CO_2} = 44.8L$ ។

# វិញ្ញាសាទី ៣ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើធាតុគីមីណាមួយដែលជាលោហៈអាល់កាឡាំង ?

ក. ☐ Na ខ. ☐ Mg គ. ☐ Cl ឃ. ☐ He ។

2. តើពេជ្រនិងក្រាហ្វិកជាអ្វីនៃកាបូន ?

ក. ☐ សមាសធាតុ ខ. ☐ សណ្ឋានវិសមរូប

គ. ☐ អ៊ីសូតូប ឃ. ☐ អ៊ីសូមែ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. កាលណាគេចាក់អំបិលសម្លក្នុងទឹកវានឹងរលាយ គេទទួលបាន …… ហៅថាទឹកអំបិល ។

ខ. ក្លួយកូស + …… → កាបូនឌីអុកស៊ីត + …… + ថាមពល ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. សូលុយស្យុងអាស៊ីតមានកម្រិត | ក. តម្លៃ pH ស្មើ 7 | 1. → |
| 2. សូលុយស្យុងបាសមានកម្រិត | ខ. តម្លៃ pH តូចជាង 7 | 2. → |
| 3. សូលុយស្យុងណឺតមានកម្រិត | គ. តម្លៃ pH ធំជាង 7 | 3. → |
| | ឃ. តម្លៃ pH តូចជាងនិងស្មើ 7 | |

## III. ចូរសរសេរនិងថ្លឹងសមីការខាងក្រោម

1. $Na + H_2CO_3 \rightarrow \ldots\ldots + \ldots\ldots$
2. $MgSO_4 + NaOH \rightarrow \ldots\ldots + \ldots\ldots$
3. $KOH + HCl \rightarrow \ldots\ldots + \ldots\ldots$
4. $Al(NO_3)_3 + K_3PO_4 \rightarrow \ldots\ldots + \ldots\ldots$ ។

## IV. លំហាត់

1. គេដាក់ផូស្វ័រ 12.5g ឱ្យមានប្រតិកម្មជាមួយអុកស៊ីសែន ។ គណនា ៖

   ក. រកម៉ាសអុកស៊ីសែនចាំបាច់ប្រើក្នុងចំហេះនេះ

   ខ. រកម៉ាសអានីឌ្រីតផូស្វ័រិចដែលកកើត ។

   គេឱ្យ (O = 16 , P = 31 )

2. គេចាក់អាស៊ីតក្លរីឌ្រិចទៅក្នុងកែវមួយដែលមានស័ង្កសី 5.6g ។ គណនា ៖

   ក. រកម៉ាសនិងមាឌអ៊ីដ្រូសែនដែលភាយ

   ខ. គណនាម៉ាសអាស៊ីតដែលប្រើក្នុងប្រតិកម្មនេះ បើគេដឹងថាអ៊ីដ្រូសែន 2g មានមាឌ 22.4L ។

   (គេឱ្យ ៖ Zn = 63.5 , H = 1 , Cl = 35.5 )

# កំណែវិញ្ញាសាទី ៣

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑ Na ។

2. ខ. ☑ សណ្ឋានវិសមរូប ។

3. ក. សូលុយស្យុង ។

   ខ. អុកស៊ីសែន , ទឹក ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ខ $\quad 2 \rightarrow$ គ $\quad 3 \rightarrow$ ក ។

## III. ចម្លើយសមីការ

1. $2Na_{(s)} + H_2CO_{3(aq)} \rightarrow Na_2CO_{3(aq)} + H_{2(g)}$

2. $MgSO_{4(s)} + 2NaOH_{(aq)} \rightarrow Mg(OH)_{2(s)} + Na_2SO_{4(aq)}$

3. $KOH_{(aq)} + HCl_{(aq)} \rightarrow KCl_{(aq)} + H_2O_{(l)}$

4. $Al(NO_3)_{3(aq)} + K_3PO_{4(aq)} \rightarrow AlPO_{4(s)} + 3KNO_{3(aq)}$ ។

## IV. ចម្លើយលំហាត់

1. ក. រកម៉ាសអុកស៊ីសែនចាំបាច់ប្រើក្នុងចំហេះនេះ

   សមីការប្រតិកម្ម : $4P_{(s)} + 5O_{2(g)} \rightarrow 2P_2O_{5(g)}$

   តាមសមីការ : $P = 124g$ ត្រូវការអុកស៊ីសែន $O_2 = 160g$

   បើ $P = 12.5g$ ត្រូវការ $m_{o_2} = g$ ?

   តាមសមាមាត្រកំណត់ $\frac{124}{12.5} = \frac{160}{m_{O_2}} \Rightarrow m_{(O_2)} = \frac{12.5 \times 160}{124}$

   $= 16.12g$

   ដូច្នេះម៉ាសអុកស៊ីសែនចាំបាច់ត្រូវប្រើគឺ $m_{(O_2)} = 16.12g$ ។

ខ. រកម៉ាសអានីឌ្រីតផូស្វ័រិចដែលកកើត

តាមសមីការ $P = 31 \times 4 = 124g$ គេទទួលបាន

$P_2O_5 = 2(31 \times 2 + 16 \times 5) = 284g$

បើ $P = 12.5g$ គេទទួលបាន $P_2O_5 = m_g$ ?

តាមសមាមាត្រកំណត់

យើងបាន $\frac{124}{12.5} = \frac{284}{m_{(P_2O_5)}} \Rightarrow m_{(P_2O_5)} = \frac{12.5 \times 284}{124}$

$= 28.62g$

ដូច្នេះម៉ាស $P_2O_5$ គឺ $m_{(P_2O_5)} = 28.62g$ ។

2. ក. រកម៉ាសនិងមាឌអ៊ីដ្រូសែនដែលភាយ

សមីការតាងប្រតិកម្ម : $Zn_{(s)} + 2HCl_{(aq)} \rightarrow ZnCl_{2(aq)} + H_{2(g)}$

- រកម៉ាសអ៊ីដ្រូសែនភាយ :

តាមសមីការ :

បើគេប្រើ $Zn = 63.5g$ គេទទួលបាន $H_2 = 2g$

តែបើគេប្រើ $Zn = 5.6g$ គេទទួលបាន $m_{(H_2)} = ?$

តាមសមាមាត្រកំណត់

យើងបាន $\frac{63.5}{5.6} = \frac{2}{m_{(H_2)}} \Rightarrow m_{(H_2)} = \frac{5.6 \times 2}{63.5} = 0.176g$

ដូច្នេះ $m_{(H_2)} = 0.176g$ ។

- រកមាឌអ៊ីដ្រូសែនភាយ :

តាមបម្រាប់ $H_2 = 2g$ មានមាឌ 22.4L

បើ $H_2 = 0.176g$ មានមាឌ $V_{(H_2)} = ?$

តាមសមាមាត្រកំណត់

យើងបាន $\frac{2}{0.176} = \frac{22.4}{V_{(H_2)}} \Rightarrow V_{(H_2)} = \frac{0.176 \times 22.4}{2}$

$= 1.97L$

ដូច្នេះមាឌអ៊ីដ្រូសែនដែលភាយគឺ $V_{(H_2)} = 1.97L$ ។

ខ. រកម៉ាសអាស៊ីតដែលប្រើនៅក្នុងប្រតិកម្មនេះ

តាមសមីការ :

បើគេប្រើ $Zn = 63.5g$ គេត្រូវប្រើអាស៊ីត $HCl = 73g$

តែបើគេប្រើ $Zn = 5.6g$ គេត្រូវការអាស៊ីត $HCl = m_g$ ?

តាមសមាមាត្រកំណត់

យើងបាន $\frac{63.5}{5.6} = \frac{73}{m_{(HCl)}} \Rightarrow m_{(HCl)} = \frac{5.6 \times 73}{63.5}$

$= 6.437g$

ដូច្នេះម៉ាសអាស៊ីត $m_{(HCl)} = 6.437g$ ។

# វិញ្ញាសាទី ៤ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើគេត្រូវដាក់សមាសធាតុអ្វីនៅក្នុងថ្នាំដុសធ្មេញដើម្បីបង្ការធ្មេញពុក ?

ក. ☐ ម៉ាញេស្យូម ខ. ☐ ភ្លុយអរ

គ. ☐ កាបូន ឃ. ☐ កាល់ស្យូម ។

2. ក្នុងចំណោមសមាសធាតុខាងក្រោម តើសមាសធាតុណាមួយជាបាស ?

ក. ☐ ទឹកខ្មេះ ខ. ☐ ទឹកត្នោត

គ. ☐ ទឹកក្រូច ឃ. ☐ ទឹកកំបោរ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អំបិលជាសមាសធាតុដែលម៉ូលេគុលវាផ្សំដោយអាតូមលោហៈនិង.... ។

ខ. នៅក្នុងជើងអគ្គិសនីវិភាគអាណូតគឺជា........ដែលតភ្ជាប់ទៅនឹងប៉ូលវិជ្ជមាន (+) នៃជនិតា ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. រេដុករ | ក. ជាធាតុដែលបោះបង់អុកស៊ីសែន | 1. → |
| 2. កាតាលីករ | ខ. ជាធាតុចូលរួមប្រតិកម្ម | 2. → |
| 3. អង្គធាតុប្រតិករ | គ. ជាធាតុដែលចាប់យកអុកស៊ីសែន | 3. → |
| | ឃ. ជាធាតុបង្កើនល្បឿនប្រតិកម្ម | |

## III. ចូរសរសេរនិងថ្លឹងសមីការខាងក្រោម

1.
$$\begin{array}{ccccc} CaCO_3 & \xrightarrow{(1)} & CaO & \xrightarrow{(2)} & Ca(OH)_2 \\ & & \downarrow{\scriptstyle (4)} & & \downarrow{\scriptstyle (3)} \\ & & CaCl_2 & & Ca(NO_3)_2 \end{array}$$

## IV. លំហាត់

1. ក. គេចាក់សូលុយស្យុងអាស៊ីតក្លរីឌ្រិច ដែលមានអាស៊ីតសុទ្ធ 12g ទៅលើអាលុយមីញ៉ូមសុទ្ធ ។ តើគេទទួលបានឧស្ម័នអ៊ីដ្រូសែនប៉ុន្មានក្រាម ?

   ខ. គេយកអ៊ីដ្រូសែនដែលទទួលបាននេះឱ្យមានប្រតិកម្មជាមួយដែកអុកស៊ីតម៉ាញេទិច ។ គណនាម៉ាសដែកសុទ្ធដែលទទួលបានពីប្រតិកម្មនេះ ?

   (គេឱ្យ : H = 1 , Cl = 35.5 , Fe = 56 )

2. គេចាក់សូដ្យូមស៊ុលផាតចំនួន 500ml នៅកំហាប់ 0.3M ចូលក្នុងសូលុយស្យុងបារ្យ៉ូមក្លរួដែលបរិមាណលើសគេទទួលបានកករក្រោយប្រតិកម្ម ។ គណនា :

   ក. ចូរសរសេរនិងថ្លឹងសមីការតាងប្រតិកម្ម ។

   ខ. គណនាម៉ាសសូដ្យូមស៊ុលផាតសុទ្ធនិងចំនួនម៉ូលរបស់បារ្យ៉ូមក្លរួដែលចូលរួមក្នុងប្រតិកម្ម ។

   គ. គណនាម៉ាសកករដែលកកើតក្រោយប្រតិកម្ម ។

   (គេឱ្យ : Na = 23 , O = 16 , S = 32 , Ba = 137 , Cl = 35.5 )

# កំណែវិញ្ញាសាទី ៤

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ ភ្លុយអរ ។

2. ឃ. ☑ ទឹកកំបោរ ។

3. ក. រ៉ាឌីកាល់អាស៊ីត ។

   ខ. អេឡិចត្រុត ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ គ　　$2 \rightarrow$ ឃ　　$3 \rightarrow$ ខ ។

## III. ចម្លើយសមីការ

1. - $CaCO_{3(s)} \xrightarrow{t^0} CaO_{(s)} + CO_{2(g)}\nearrow$
   - $CaO_{(s)} + H_2O_{(l)} \rightarrow Ca(OH)_{2(aq)}$
   - $Ca(OH)_{2(aq)} + 2NaNO_{3(aq)} \rightarrow Ca(NO_3)_{2(aq)} + 2NaOH_{(aq)}$
   - $CaO_{(s)} + 2NaCl_{(aq)} \rightarrow CaCl_{2(aq)} + Na_2O_{(s)}$ ។

## IV. ចម្លើយលំហាត់

1. ក. គណនាម៉ាសឧស្ម័នអ៊ីដ្រូសែនទទួលបាន

   សមីការប្រតិកម្ម

   $6HCl_{(aq)} + 2Al_{(s)} \rightarrow 2AlCl_{3(aq)} + 3H_{2(g)}\nearrow$

   តាមសមីការ :

   បើគេប្រើ HCl 219g គេទទួលបាន $H_2 = 6g$

   តែបើគេប្រើ HCl 12g គេទទួលបាន $H_2 = m_g$ ?

តាមសមាមាត្រកំណត់

គេបាន $\frac{219}{12} = \frac{6}{m_{H_2}} \Rightarrow m_{(H_2)} = \frac{12 \times 6}{219} = 0.32g$

ដូច្នេះ : $m_{(H_2)} = 0.32g$ ។

ខ. គណនាម៉ាសដែកទទួលបាន

តាមសមីការតាងប្រតិកម្ម

$4H_{2(g)} + Fe_3O_{4(s)} \rightarrow 3Fe_{(s)} + 4H_2O_{(l)}$

តាមសមីការ :

បើគេប្រើ $H_2 = 8g$ គេទទួលបាន $Fe = 168g$

តែបើគេប្រើ $H_2 = 0.32g$ គេទទួលបានដែក $Fe = m_g$ ?

យើងបាន $\frac{8}{0.32} = 168 \Rightarrow m_{Fe} = \frac{0.32 \times 168}{8} = 6.72g$

ដូច្នេះ : $m_{Fe} = 6.72g$ ។

2. ក. សមីការតាងប្រតិកម្ម

$Na_2SO_{4(aq)} + BaCl_{2(aq)} \rightarrow 2NaCl_{(aq)} + BaSO_{4(s)}$ ។

ខ. គណនាម៉ាសសូដ្យូមស៊ុលផាតសុទ្ធចូលរួមប្រតិកម្ម

ចំនួនម៉ូល $Na_2SO_4$

តាមបម្រាប់យើងដឹងថា $Na_2SO_4 = 1000ml$ មានកំហាប់ 0.3 ម៉ូល

បើ $Na_2SO_4 = 500ml$ មានកំហាប់ $Cn = ?$

តាមសមាមាត្រកំណត់

យើងបាន $\frac{1000}{500} = \frac{0.30}{C_n} \Rightarrow Cn_{Na_2SO_4} = \frac{500 \times 0.30}{1000}$

$= 0.15mol$

ដូច្នេះ $C_{nNa_2SO_4} = 0.15mol$

ម៉ាស $Na_2SO_4$ សុទ្ធ

$Na_2SO_4 = (23 \times 2) + 32 + (16 \times 4) = 142g$

$m_{Na_2SO_4} = 0.15 \times 142g = 21.3g$

ដូច្នេះ $m_{Na_2SO_4} = 21.3g$

ចំនួនម៉ូល $BaCl_2$ ចូលរួមប្រតិកម្ម

តាមសមីការ :

$n_{Na_2SO_4} = n_{BaCl_2} = 0.15mol$

ដូច្នេះ $n_{BaCl_2} = 0.15mol$ ។

គ. ម៉ាសកករដែលកកើតក្រោយប្រតិកម្ម

$BaSO_4 = 137 + 32 + 64 = 233g$

$m_{BaSO_4} = 0.15 \times 233g = 34.95g$

ដូច្នេះ $m_{BaSO_4} = 34.95g$ ។

# វិញ្ញាសាទី ៥ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើគេចែកអុកស៊ីតជាប៉ុន្មានប្រភេទ ?

ក. ☐ មួយប្រភេទ　　ខ. ☐ ពីរប្រភេទ

គ. ☐ បីប្រភេទ　　ឃ. ☐ បួនប្រភេទ ។

2. តើកសិករបន្សាបជាតិអាស៊ីតពីដីដោយប្រើសមាសធាតុណាមួយ ?

ក. ☐ $Ca(NO_3)_2$　　ខ. ☐ $Ca$

គ. ☐ $CaCl_2$　　ឃ. ☐ $Ca(OH)_2$ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អុកស៊ីសែនជាឧស្ម័ន គ្មានពណ៌ គ្មានក្លិន ធ្ងន់ជាងខ្យល់ មានម៉ាសអាតូម ....... និងម៉ាសម៉ូលេគុល........ ។

ខ. នៅក្នុងតារាងខួបនៃធាតុគីមីគេតម្រៀបធាតុគីមីទៅតាមលំដាប់កើនឡើងនៃចំនួន.......... ឬ .......... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ឧស្ម័នដែលទ្រទ្រង់ចំហេះ | ក. $H_2$ | 1. → |
| 2. ឧស្ម័នដែលចូលរួមក្នុងប្រតិកម្មរស្មីសំយោគ | ខ. $Cl_2$ | 2. → |
| | គ. $CO_2$ | 3. → |
| 3. ឧស្ម័នដែលស្រាលជាងគេ | ឃ. $O_2$ | |
| | ង. $SO_2$ | |

## III. សំណួរត្រិះរិះ

1. គេចាក់ប្រេងឆាទៅក្នុងកែវមួយដែលមានទឹកនៅក្នុងនោះរួចសង្កេត ៖

ក. តើល្បាយដែលទទួលបាននេះជាល្បាយប្រភេទអ្វី ?

ខ. អ្នកសង្កេតឃើញសារធាតុអ្វីដែលនៅបាតកែវ ?

2. ប្រេងសាំងប្រើសម្រាប់ចំហេះក្នុងរថយន្តជាល្បាយនៃអ៊ីដ្រូកាបួផ្សេងៗ ។

ក. តើផលិតផលអ្វីខ្លះដែលទទួលបានក្រោយចំហេះប្រេងសាំង ?

ខ. តើតំណក់វត្ថុរាវដែលស្រក់ពីបំពង់ផ្សែង គឺជាតំណក់អ្វី ? ជាតំណក់ប្រេងសាំងមិនចូលរួមក្នុងចំហេះ ឬជាតំណក់ទឹក ?

## IV. លំហាត់

1. គេបង់ទង់ដែងអុកស៊ីតដែលមានទង់ដែង 12g ទៅក្នុងសូលុយស្យុងអាស៊ីតស៊ុលផួរិច ។ តើគេទទួលបានទង់ដែងស៊ុលផាតប៉ុន្មានក្រាមក្រោយប្រតិកម្ម ?
(Cu = 63.5 , S = 32 , O = 16 , H = 1 )

2. គេបញ្ចូលឧស្ម័ន $CO_2$ 1.568L ទៅក្នុងសូលុយស្យុងមួយដែលមាន NaOH រលាយចំនួន 6.4g គេទទួលបានផលិតផលអំបិល $Na_2CO_3$ ។

ក. ចូរកំណត់ម៉ាសអំបិលដែលទទួលបានពីប្រតិកម្មនេះ

ខ. រកមាឌឧស្ម័នដែលចូលរួមក្នុងប្រតិកម្មខាងលើនេះ ។

(គេឱ្យ ៖ មាឌឧស្ម័ន 22.4L/mol Na = 23 , O = 16 , C = 12 )

# កំណែវិញ្ញាសាទី ៥

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ បីប្រភេទ ។

2. ឃ. ☑ $Ca(OH)_2$ ។

3. ក. 16 , 32 ។

ខ. ប្រូតុង , លេខអាតូម ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

$1 \rightarrow$ ឃ $2 \rightarrow$ គ $3 \rightarrow$ ក ។

## III. ចម្លើយត្រិះរិះ

1. ក. ល្បាយដែលទទួលបាននេះ ជាល្បាយមិនស្មើសាច់ ។

ខ. យើងសង្កេតឃើញប្រេងដែលថិតនៅបាតកែវ ។

2. ក. ផលិតផលដែលទទួលបានក្រោយចំហេះប្រេងសាំងគឺ ឧស្ម័នកាបូនឌីអុកស៊ីតនិងទឹក ។

ខ. តំណក់វត្ថុរាវដែលស្រក់ពីបំពង់ផ្សែង មិនមែនជាតំណក់ប្រេងសាំងដែលមិនចូលរួមក្នុងចំហេះទេ វាគឺជាតំណក់ទឹក ។

## IV. ចម្លើយលំហាត់

1. រកម៉ាសទង់ដែងស៊ុលផាត :

ម៉ាសទង់ដែងអុកស៊ីតដែលត្រូវនឹងម៉ាសទង់ដែង 12g

មាន Cu សុទ្ធ = 63.5g នៅក្នុងទង់ដែងអុកស៊ីត CuO = 79.5g

បើ Cu សុទ្ធ = 12g ក្នុង CuO = m ?

តាមសមាមាត្រកំណត់យើងបាន

$$\frac{63.5}{12} = \frac{79.5}{m} \Rightarrow m_{CuO} = \frac{12 \times 79.5}{63.5} = 15.02g$$

សមីការតាងប្រតិកម្ម

$CuO_{(s)} + H_2SO_{4(aq)} \rightarrow CuSO_{4(aq)} + H_2O_{(l)}$

តាមសមីការ :

បើគេប្រើ CuO 79.5g គេទទួលបាន $CuSO_4 = 159.5g$

តែបើគេប្រើ CuO 15.02g គេទទួលបាន $CuSO_4 = m_g$ ?

តាមសមាមាត្រកំណត់

គេបាន $\frac{79.5}{15.02} = \frac{159.5}{m_g} \Rightarrow m_{CuSO_4} = \frac{159.5 \times 15.02}{79.5} = 30.13g$

ដូច្នេះ $m_{CuSO_4} = 30.13g$ ។

2. ក. កំណត់ម៉ាសអំបិលដែលទទួលបាន

សមីការតាងប្រតិកម្ម

$2NaOH_{(aq)} + CO_{2(g)} \rightarrow Na_2CO_{3(aq)} + H_2O_{(l)}$

តាមបម្រាប់ : មាឌ $CO_2 = 1.568L$ , ម៉ាស $NaOH = 6.4g$

រកចំនួនម៉ូល $CO_2$

$n_{CO_2} = \frac{V_{CO_2}}{V_m} = \frac{1.568}{22.4} = 0.07mol$

រកចំនួនម៉ូល NaOH

$n_{NaOH} = \frac{m_{(NaOH)}}{M_{(NaOH)}}$

$M_{(NaOH)} = 23 + 16 + 1 = 40g/mol$

ដូច្នេះ $n_{NaOH} = \frac{6.4}{40} = 0.16mol$

យើងបាន $n(CO_2) = 0.07mol < nNaOH = 0.16mol$

ដូចនេះនាំឱ្យ $nCO_2$ ចូលរួមអស់ក្នុងប្រតិកម្ម ។

ចំនួនម៉ូល NaOH ចូលរួមប្រតិកម្ម

តាមសមីការ $n(NaOH) = 2 \times nCO_2$

$= 2 \times 0.07 = 0.14mol$

ម៉ាស NaOH ចូលរួមប្រតិកម្ម

$m(NaOH) = 0.14 \times 40g = 5.6g$

ម៉ាសអំបិលទទួលបានពីប្រតិកម្ម

តាមសមីការ $n_{CO_2} = n_{Na_2CO_3} = 0.07mol$

$m_{Na_2CO_3} = (23 \times 2) + 12 + 48 = 106g$

$m_{Na_2CO_3} = 0.07 \times 106g = 7.42g$

ដូច្នេះម៉ាសអំបិលទទួលបាន $m_{Na_2CO_3} = 7.42g$ ។

២. រកមាឌឧស្ម័នចូលរួមក្នុងប្រតិកម្មខាងលើ

ដោយ $n_{CO_2} = 0.07mol$ ចូលរួមអស់ក្នុងប្រតិកម្ម ដូចនេះមាឌឧស្ម័ន ដែលចូលរួមគឺ $V_{CO_2} = 1.568L$ ។

# វិញ្ញាសាទី ៦ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើណាមួយដែលជាសមាសធាតុ ?

ក. ☐ ទង់ដែង　　ខ. ☐ អំបិលសម្ល

គ. ☐ ម៉ាញេស្យូម　　ឃ. ☐ ស្ពាន់ធ័រ ។

2. តើមានអាស៊ីត $H_2SO_4$ ប៉ុន្មានម៉ូលបិតក្នុង $500cm^3$ នៅកំហាប់ $1.0mol/dm^3$ ?

ក. ☐ 0.5mol　ខ. ☐ 1.0mol　គ. ☐ 5.0mol　ឃ. ☐ 50mol ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ចំហេះនៃអ៊ីដ្រូកាបួក្នុង.........បង្កើតបានជា........និងទឹក ។

ខ. បាសជាសមាសធាតុដែលម៉ូលេគុលវាបង្កដោយអាតូម.........ចូលផ្សំជាមួយបង្គុំ...........មួយ ឬច្រើន ហើយមានអំពើជាមួយអាស៊ីតឱ្យផលជាអំបិលនិងទឹក ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. $ZnSO_4$ | ក. ប៉ូតាស្យូមកាបូណាត | 1. → |
| 2. $AgNO_3$ | ខ. ទង់ដែងក្លរួ | 2. → |
| 3. $K_2CO_3$ | គ. ស័ង្កសីស៊ុលផាត | 3. → |
| 4. $Na_2SO_4$ | ឃ. សូដ្យូមស៊ុលផាត | 4. → |
| | ង. អាលុយមីញ៉ូមក្លរួ | |
| | ច. ប្រាក់នីត្រាត | |

## III. ចូរសរសេរនិងថ្លឹងសមីការខាងក្រោម

1. $SO_{2(g)} + H_2O_{(l)} \rightarrow \ldots\ldots\ldots$
2. $Ca(OH)_{2(aq)} + H_2SO_{4(aq)} \rightarrow \ldots\ldots\ldots + \ldots\ldots$
3. $Al_2O_{3(s)} + HCl_{(aq)} \rightarrow \ldots\ldots\ldots + \ldots\ldots$
4. $Fe_2O_{3(s)} + HCl_{(aq)} \rightarrow \ldots\ldots\ldots + \ldots\ldots$ ។

## IV. លំហាត់

1. គេចង់ទង្វើកាល់ស្យូមកាបូណាត 25g ដោយឱ្យសូលុយស្យុង $Ca(OH)_2$ មានប្រតិកម្មជាមួយឧស្ម័នកាបូនឌីអុកស៊ីត ។

   ក. ចូរសរសេរសមីការទង្វើកាល់ស្យូមកាបូណាត ។

   ខ. កំណត់ម៉ាសសូលុយស្យុង $Ca(OH)_2$ ដែលត្រូវប្រើ ។

   គ. គណនាមាឌឧស្ម័នចាំបាច់ត្រូវប្រើនៅលក្ខខណ្ឌធម្មតា ។

   (គេឱ្យ : H = 1 , C = 12 , O = 16 , Ca = 40 មាឌឧស្ម័ន 22.4L/mol )

2. គេមានសូលុយស្យុងអាស៊ីត HCl ចំនួន $200cm^3$ នៅកំហាប់ $2.0mol/dm^3$ គេចង់បន្សាបអាស៊ីតខាងលើនេះដោយប្រើសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ។

   ក. ចូរសរសេរសមីការតាងប្រតិកម្ម ។

   ខ. រកចំនួនម៉ូលអាស៊ីត HCl ដែលត្រូវបន្សាប ។

   គ. រកម៉ាស NaOH ចាំបាច់ត្រូវប្រើដើម្បីបន្សាបអាស៊ីតនេះ ។

   (គេឱ្យ : Na = 23 , O = 16 , H = 1 )

# កំណែវិញ្ញាសាទី ៦

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ អំបិលសម្ល ។
2. ក. ☑ 0.5mol ។
3. ក. អុកស៊ីសែន , ឧស្ម័នកាបូនឌីអុកស៊ីត ។

   ខ. លោហៈ , អ៊ីដ្រុកស៊ីល (OH) ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ គ   $2 \rightarrow$ ច   $3 \rightarrow$ ក   $4 \rightarrow$ ឃ ។

## III. ចម្លើយសមីការ

1. $SO_{2(g)} + H_2O_{(l)} \rightarrow H_2SO_{3(l)}$
2. $Ca(OH)_{2(aq)} + H_2SO_{4(aq)} \rightarrow CaSO_{4(aq)} + 2H_2O_{(l)}$
3. $Al_2O_{3(s)} + 6HCl_{(aq)} \rightarrow 2AlCl_{3(aq)} + 3H_2O_{(l)}$
4. $Fe_2O_{3(s)} + 6HCl_{(aq)} \rightarrow 2FeCl_{3(aq)} + 3H_2O_{(l)}$ ។

## IV. ចម្លើយលំហាត់

1. ក. សមីការតាងប្រតិកម្ម

   $Ca(OH)_{2(aq)} + CO_{2(g)} \rightarrow CaCO_{3(s)} + H_2O_{(l)}$

   ខ. ម៉ាសសូលុយស្យុង $Ca(OH)_2$ ប្រើ

   តាមសមីការ :

   គេប្រើ $Ca(OH)_2 = 74g$ ទទួលបាន $CaCO_3 = 100g$

   បើគេប្រើ $Ca(OH)_2 = m_g$ ទទួលបាន $CaCO_3 = 25g$

   តាមសមាមាត្រកំណត់យើងបាន :

   យើងបាន $\frac{74}{m} = \frac{100}{25} \Rightarrow m_{Ca(OH)_2} = \frac{74 \times 25}{100} = 18.5g$

   ដូចនេះ $m_{Ca(OH)_2} = 18.5g$ ។

គ. រកមាឌឧស្ម័ន $CO_2$ ចាំបាច់ត្រូវប្រើ

ចំនួនម៉ូល $Ca(OH)_2$

$$n_{Ca(OH)_2} = \frac{m\ Ca(OH)_2}{M\ Ca(OH)_2} = \frac{18.5}{74} = 0.25mol$$

តាមសមីការ ៖

$$n_{CO_2} = n_{Ca(OH)_2} = 0.25mol$$

មាឌឧស្ម័ន $CO_2$

$$V_{CO_2} = 0.25 \times 22.4L = 5.6L$$

ដូច្នេះ $V_{CO_2} = 5.6L$ ។

2. ក. សរសេរសមីការតាងប្រតិកម្ម

$$NaOH_{(aq)} + HCl_{(aq)} \rightarrow NaCl_{(aq)} + H_2O_{(l)}$$

ខ. រកចំនួនម៉ូល HCl ដែលត្រូវបន្សាប

តាមរូបមន្ត $C_M = \frac{n_{(HCl)}}{V_{(HCl)}} \Rightarrow n_{(HCl)} = C_M \times V_{(HCl)}$

ដោយ $C_M = 2mol/dm^3$

$$V_{(HCl)} = 200cm^3 = 0.2dm^3$$

$$n_{(HCl)} = 0.2 \times 2 = 0.4mol$$

ដូចនេះ $n_{(HCl)} = 0.4mol$ ។

គ. ម៉ាស NaOH ចាំបាច់ប្រើដើម្បីបន្សាបអាស៊ីត

តាមរូបមន្ត ៖

$$n(NaOH) = \frac{m(NaOH)}{M(NaOH)} \Rightarrow m(NaOH) = M(NaOH) \times n(NaOH)$$

តាមសមីការ $n(NaOH) = n(HCl) = 0.4mol$

នាំឱ្យ $m(NaOH) = 0.4 \times 40g = 16g$

ដូច្នេះ $m(NaOH) = 16g$ ។

# វិញ្ញាសាទី ៧ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ក្នុងក្រុមទាំងបួនខាងក្រោមនេះ តើក្រុមណាមួយដែលមានលោហៈទាំងបី ?

ក. ☐ កាបូន អ៊ីដ្រូសែន សូដ្យូម

ខ. ☐ សូដ្យូម ទង់ដែង អាលុយមីញ៉ូម

គ. ☐ ម៉ាញេស្យូម សូដ្យូម អុកស៊ីសែន

ឃ. ☐ អុកស៊ីសែន ទង់ដែង កាបូន ។

2. តើសមាសធាតុណាមួយ ជាកករពណ៌សដែលកកើតនៅពេលគេឱ្យឧស្ម័នកាបូនឌីអុកស៊ីតឆ្លងកាត់ទឹកកំបោរថ្លា ?

ក. ☐ $Ca(OH)_2$

ខ. ☐ $CaO$

គ. ☐ $CaCO_3$

ឃ. ☐ $Ca(HCO_3)_2$ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. តាមរយៈអគ្គិសនីវិភាគទឹកគេទទួលបានអ៊ីដ្រូសែនភាយនៅខាង....... និងអុកស៊ីសែនភាយនៅខាង......... ។

ខ. គ្លុយកូស + ......... → កាបូនឌីអុកស៊ីត + ......... + ថាមពល ។

គ. ប្រតិកម្ម...................... កើតឡើងពីប្រតិកម្មរវាងអាស៊ីតនិងបាស ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ទឹកខ្មេះ | ក. មានតម្លៃ pH ស្មើ 7 | 1. → |
| 2. ទឹកកំបោរ | ខ. មានតម្លៃ pH ធំជាង 7 | 2. → |
| 3. ទឹកម៉ាស៊ីន | គ. មានតម្លៃ pH តូចជាង 7 | 3. → |

## III. សំណួរត្រិះរិះ

1. ដូចម្តេចដែលហៅថា អុកស៊ីតអំផូទែ ? ចូរពន្យល់និងរកឧទាហរណ៍បញ្ជាក់ផង ។
2. ចូរសរសេរនិងថ្លឹងសមីការតាងប្រតិកម្មចំហេះអុកស៊ីសែន (រាវ) និងអ៊ីដ្រូសែន (រាវ) នៅក្នុងកាំជ្រួច ។ តើចំហេះខាងលើនេះមានគ្រោះថ្នាក់ដល់បរិស្ថានដែរឬទេ ? ចូរពន្យល់ ។

## IV. លំហាត់

1. គេដាក់អាលុយមីញ៉ូម 13.5g ឱ្យមានប្រតិកម្មជាមួយសូលុយស្យុងអាស៊ីតស៊ុលផួរិច ។

   ក. គណនាម៉ាសអាស៊ីតដែលប្រើ ។

   ខ. រកម៉ាសអំបិលដែលទទួលបាន ។

   (គេឱ្យ : O = 16 , Al = 27 , S = 32 )

2. គេដាក់កាបូន 24g ឱ្យមានចំហេះសព្វជាមួយអុកស៊ីសែន ។ គណនា :

   ក. ម៉ាសអុកស៊ីសែនចាំបាច់សម្រាប់ចំហេះកាបូន ។

   ខ. រកម៉ាសនិងមាឌឧស្ម័នកាបូនឌីអុកស៊ីតកកើតក្រោយប្រតិកម្ម ។

   (គេឱ្យ : នៅលក្ខខណ្ឌធម្មតា 44g ឧស្ម័ន $CO_2$ មានមាឌ 22.4L , C = 12 , O = 16 ) ។

# កំណែវិញ្ញាសាទី ៧

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ ស្ពាន់ស្ងួម ទង់ដែង អាលុយមីញ៉ូម ។

2. គ. ☑ $CaCO_3$ ។

3. ក. កាតូត , អាណូត ។

   ខ. អុកស៊ីសែន , ទឹក ។

   គ. បន្សាប ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ   2 → ខ   3 → ក ។

## III. ចម្លើយត្រិះរិះ

1. អុកស៊ីតអំផូទែ គឺជាអុកស៊ីតទាំងឡាយណាដែលមានលក្ខណៈជាអុកស៊ីតបាសផងនិងជាអុកស៊ីតអាស៊ីតផង មានន័យថានៅក្នុងមជ្ឈដ្ឋានបាសវាដើរតួជាអាស៊ីត ហើយនៅក្នុងមជ្ឈដ្ឋានអាស៊ីតវាដើរតួជាបាស ។

   ឧទាហរណ៍ :

   - $\underset{\text{បាស}}{ZnO} + \underset{\text{អាស៊ីត}}{2HCl} \rightarrow ZnCl_2 + H_2O$

   - $\underset{\text{អាស៊ីត}}{ZnO} + \underset{\text{បាស}}{2NaOH} \rightarrow Na_2ZnO_2 + H_2O$ ។

2. សមីការតាងប្រតិកម្ម

   $$2H_{2(g)} + O_{2(g)} \rightarrow 2H_2O_{(l)}$$

   ចំហេះខាងលើនេះមិនមានគ្រោះថ្នាក់ដល់បរិស្ថានទេ ពីព្រោះផលិតផលដែលកកើតពីប្រតិកម្មចំហេះនេះ គឺ "ទឹក" ។

## IV. ចម្លើយលំហាត់

1. ក. រកម៉ាសអាស៊ីតប្រើ

សមីការតាងប្រតិកម្ម

$$2Al_{(s)} + 3H_2SO_{4(aq)} \rightarrow Al_2(SO_4)_{3(aq)} + 3H_{2(g)}$$

តាមសមីការ :

គេប្រើ 54g គេត្រូវការ $H_2SO_4 = 294g$

បើគេប្រើ 13.5g គេត្រូវការ $H_2SO_4 = x_g$ ?

យើងបាន $\frac{54}{13.5} = \frac{294}{m} \Rightarrow m_{H_2SO_4} = \frac{13.5 \times 294}{54} = 73.5g$

ដូច្នេះ $m_{H_2SO_4} = 73.5g$ ។

ខ. ម៉ាសអំបិលដែលទទួលបាន

តាមសមីការ :

គេប្រើ $Al = 54g$ គេទទួលបាន $Al_2(SO_4)_3 = 342g$

បើគេប្រើ $Al = 13.5g$ ទទួលបាន $Al_2(SO_4)_3 = m_g$ ?

យើងបាន $\frac{54}{13.5} = \frac{342}{m} \Rightarrow m_{Al_2(SO_4)_3} = \frac{13.5 \times 342}{54} = 85.5g$

ដូចនេះ $m_{Al_2(SO_4)_3} = 85.5g$ ។

2. សមីការតាងប្រតិកម្ម

$$C_{(S)} + O_{2(g)} \rightarrow CO_{2(g)}$$

ក. ម៉ាសអុកស៊ីសែនចាំបាច់សម្រាប់ចំហេះកាបូន

តាមសមីការ :

គេប្រើ $C = 12g$ ត្រូវការ $O_2 = 32g$

បើគេប្រើ $C = 24g$ ត្រូវការ $O_2 = m_g$ ?

តាមសមាមាត្រ :

យើងបាន $\frac{12}{24} = \frac{32}{m} \Rightarrow m_{O_2} = \frac{24 \times 32}{12} = 64g$ ។

២. រកម៉ាសឧស្ម័នកាបូនឌីអុកស៊ីតទទួលបាន

តាមសមីការ :

ចំនួនម៉ូលកាបូន $n_C = \frac{m_C}{M_C} = \frac{24}{12} = 2mol$

$n_C = n_{CO_2} = 2mol$

$m_{CO_2} = 2 \times 44g = 88g$

ដូចនេះ $m_{CO_2} = 88g$

មានឧស្ម័ន $CO_2$ ដែលទទួលបាន

$V_{CO_2} = 2 \times 22.4L = 44.8L$

ដូចនេះ $V_{CO_2} = 44.8L$ ។

# វិញ្ញាសាទី ៨ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើលំនាំណាមួយដែលមិនមានផលិតផលកាបូនឌីអុកស៊ីត ?

ក. ☐ ដង្ហើម

ខ. ☐ ចំហេះកាបូនក្នុងអុកស៊ីសែន

គ. ☐ ឧស្សាហកម្មទង្វើកំបោររស់ពីថ្មកំបោរ

ឃ. ☐ រស្មីសំយោគ ។

2. ក្នុងចំណោមរូបមន្តខាងក្រោមនេះតើណាមួយជារូបមន្តទង់ដែងអ៊ីដ្រុកស៊ីត ?

ក. ☐ $Fe(OH)_3$　　　ខ. ☐ $Ca(OH)_2$

គ. ☐ $Cu(OH)_2$　　　ឃ. ☐ $Mg(OH)_2$ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អាស៊ីតមានរស់... អាចប្តូរពណ៌ក្រដាសទួណឺសុលខៀវទៅជាពណ៌.... ។

ខ. លោហៈអាល់កាឡាំងមានប្រតិកម្មយ៉ាងខ្លាំងក្លាជាមួយ...........បង្កើតបានជាសូលុយស្យុងបាសអាល់កាលីនិងឧស្ម័ន.......... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ប៉ូតាស្យូមជាធាតុ | ក. ជាឧស្ម័នសកម្ម | 1. → |
| 2. អាឡូសែនមកពីពាក្យក្រិកមានន័យថា : | ខ. ទន់អាចកាត់នឹងកាំបិត ឬឡាមបាន | 2. → |
| 3. ឧស្ម័នកម្រ | គ. ជាឧស្ម័នអសកម្ម | 3. → |
| | ឃ. បង្កើតអំបិល | |

## III. សំណួរត្រិះរិះ

1. គេមានផលិតផលមួយចំនួននឹងតម្លៃ pH របស់វា ៖ ទឹកកូកាកូឡា pH = 2.5 ទឹកម៉ាស៊ីន pH = 7 ស្រាបៀ pH = 3.2 ទឹកសាប៊ូលាងចាន pH = 10.2 ទឹកប៉េងប៉ោះ pH = 3.8 ស៊ុត pH = 7.8 ។ ចូរធ្វើចំណែកថ្នាក់ផលិតផលទាំងនេះទៅតាមក្រុម អាស៊ីត បាស ណឺត ។
2. ហេតុអ្វីបានជាគេប្រើប្រាស់ក្រាភីតធ្វើជាបណ្តូលខ្មៅដៃ ? ចូរពន្យល់ដោយសង្ខេប ។

## IV. លំហាត់

1. គេរំលាយសូដ្យូមអ៊ីដ្រុកស៊ីត NaOH ចំនួន 20g ទៅក្នុងសូលុយស្យុងមួយដែលមានមាឌ 300ml ។ គណនាចំនួនម៉ូលនិងកំហាប់ជាម៉ូលរបស់សូលុយស្យុង NaOH (គេឱ្យ ៖ H = 1 , O = 16 , Na = 23 )
2. គេបង់ដុំកាល់ស្យូម Ca = 32g ទៅក្នុងអាស៊ីតក្លរីឌ្រិច គេសង្កេតឃើញមានពពុះឧស្ម័នអ៊ីដ្រូសែនភាយឡើង ។

   ក. ចូរសរសេរសមីការប្រតិកម្ម ។

   ខ. រកបរិមាណរបស់អាស៊ីតដែលប្រើនិងមាឌឧស្ម័នដែលភាយនៅលក្ខខណ្ឌធម្មតា ។

   (គេឱ្យ ៖ Ca = 40 , Cl = 35.5 , O = 16 , C = 12 , H = 1 )

# កំណែវិញ្ញាសាទី ៨

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ រស្មីសំយោគ ។

2. គ. ☑ $Cu(OH)_2$ ។

3. ក. ជូរ , ក្រហម ។

   ខ. ទឹក , អ៊ីដ្រូសែន ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

1 → ខ   2 → ឃ   3 → ក ។

## III. ចម្លើយត្រិះរិះ

1. ធ្វើបំណែកថ្នាក់ផលិតផលទាំងនេះទៅតាមក្រុម :

   - អាស៊ីត : កូកាកូឡា pH = 2.5 , ស្រាបៀ pH = 3.2 , ទឹកប៉េងប៉ោះ pH = 3.8

   - បាស : ទឹកសាប៊ូលាងចាន pH = 10.2 , ស៊ុត pH = 7.8

   - ណឺត : ទឹកម៉ាស៊ីន pH = 7 ។

2. បានជាគេប្រើក្រាភីតធ្វើជាបណ្តូលខ្មៅដៃ ព្រោះក្រាភីតជាធាតុមានពណ៌ប្រផេះក្រម៉ៅ ទន់ និងរអិល ដែលបណ្តាលមកពីស្រទាប់របស់វាអាចរអិលលើគ្នាបានដោយងាយ ។ ដូច្នេះពេលគេយកខ្មៅដៃទៅគូសលើក្រដាសវាបានបន្សល់ទុកស្នាមគំនូសជាប់នៅលើក្រដាស ។

## IV. ចម្លើយសំណួរ

1. - រកចំនួនម៉ូល និងកំហាប់ជាម៉ូលរបស់សូលុយស្យុងនេះ

   រកចំនួនម៉ូល NaOH ក្នុងសូលុយស្យុង

តាមបម្រាប់ : $m(NaOH) = 20g$ , $V = 300ml$

$$M(NaOH) = 23 + 16 + 1 = 40g/mol$$

តាមរូបមន្ត : $n_{(NaOH)} = \frac{m(NaOH)}{M(NaOH)}$

$= \frac{20}{40} = 0.5mol$ ។

- រកកំហាប់ជាម៉ូលនៃសូលុយស្យុង NaOH

តាមរូបមន្ត : $C_M = \frac{n(NaOH)}{V(NaOH)}$

ដោយ $n(NaOH) = 0.5mol$

$V(NaOH) = 300ml = 0.3L$

$C_M = \frac{0.5}{0.3} = 1.66mol/L$ ឬ $1.66M$

ដូច្នេះ
| | |
|---|---|
| ចំនួនម៉ូលរបស់ | $NaOH = 0.5mol$ |
| កំហាប់ជាម៉ូលរបស់ NaOH គឺ | $C_M = 1.66M$ |

។

2. ក. សមីការតាងប្រតិកម្ម

$$Ca_{(s)} + 2HCl_{(aq)} \rightarrow CaCl_{2(aq)} + H_{2(g)}\nearrow$$

ខ. រកបរិមាណរបស់អាស៊ីតដែលប្រើនិងមាឌឧស្ម័នដែលភាយនៅលក្ខខណ្ឌធម្មតា

តាមសមីការ :

បើគេប្រើ $Ca = 40g$ គេត្រូវការ $HCl = 73g$

បើគេប្រើ $Ca = 32g$ គេត្រូវការ $HCl = m_g$ ?

តាមសមាមាត្រកំណត់ :

គេបាន $\frac{40}{32} = \frac{73}{m} \Rightarrow m = \frac{73 \times 32}{40} = 58.4g$

ដូច្នេះម៉ាស $HCl = 58.4g$ ។

- រកមាឌឧស្ម័នអ៊ីដ្រូសែនដែលភាយ

តាមរូបមន្ត : $V_{(H_2)} = n(H_2) \times V_m$

រកចំនួនម៉ូលរបស់ HCl

តាមរូបមន្ត $n(HCl) = \dfrac{m(HCl)}{M(HCl)}$

យើងមាន : $M(HCl) = 1 + 35.5 = 36.5g$

$m(HCl) = 58.4g$

$V_m = 22.4L/mol$

$\Rightarrow n(HCl) = \dfrac{58.4}{36.5} = 1.6mol$ ។

តាមសមីការ :

គេប្រើ 2mol HCl គេទទួលបាន 1mol $H_2$

បើគេប្រើ 1.6mol HCl គេទទួលបាន x = mol

$\Rightarrow nH_2 = \dfrac{1.6}{2} = 0.8mol$

$V_{(H_2)} = 0.8 \times 22.4 = 17.92L$

ដូច្នេះ យើងបាន $V_{(H_2)} = 17.92L$ ។

# វិញ្ញាសាទី ៩ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. តើមានធាតុគីមីប៉ុន្មានប្រភេទនៅក្នុងថ្មកំបោរ ?

ក. ☐ 1 ប្រភេទ ខ. ☐ 2 ប្រភេទ

គ. ☐ 3 ប្រភេទ ឃ. ☐ 4 ប្រភេទ ។

2. តើសារធាតុណាមួយដែលជាអំបិល ?

ក. ☐ $ZnCl_2$ ខ. ☐ $CO_2$

គ. ☐ $Mg(OH)_2$ ឃ. ☐ Ca ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. នៅពេលអាស៊ីតនឹងបាសលាយចូលគ្នា......... ដែលទទួលបានគឺ អំបិល និងទឹក ។ មានន័យថាប្រតិកម្មនេះជាប្រតិកម្ម........... ។

ខ. គ្លុយកូសនៅក្នុងសារពាង្គកាយ ដែលបានមកពីចំណីអាហារមានអំពើជាមួយ.........បង្កើតបានជាថាមពល ទឹក និង.......... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. $Al_2O_3$ | ក. ស៊ីលីស្យូមឌីអុកស៊ីត | 1. → |
| 2. HgO | ខ. កាបូនឌីអុកស៊ីត | 2. → |
| 3. MgO | គ. អាសូត អុកស៊ីត | 3. → |
| 4. $SiO_2$ | ឃ. អាលុយមីញ៉ូមអុកស៊ីត | 4. → |
| | ង. ម៉ាញេស្យូមអុកស៊ីត | |
| | ច. បារត អុកស៊ីត | |

## III. ចូរសរសេរនិងថ្លឹងសមីការខាងក្រោម

1. $K_{(s)} + H_2O_{(l)} \rightarrow$ ...........
2. $O_{2(g)} + Mg_{(s)} \rightarrow$ ...........
3. $CaO_{(s)} + H_2O_{(l)} \rightarrow$ ...........
4. $H_2SO_{4(aq)} + Cu(OH)_{2(s)} \rightarrow$ ........... ។

## IV. លំហាត់

1. នៅក្នុងប្រតិកម្មចំហេះកាបូនមួយ គេទទួលបានឧស្ម័នកាបូនឌីអុកស៊ីតចំនួន 22g ។ គណនា ៖

   ក. ម៉ាសកាបូនដែលចូលរួមប្រតិកម្ម

   ខ. ម៉ាសអុកស៊ីសែនចាំបាច់ចូលរួមក្នុងប្រតិកម្ម

   (គេឱ្យ ៖ C = 12 , O = 16 )

2. ផើងមួយមានផ្ទុកសូលុយស្យុងអាស៊ីតក្លរីឌ្រិចចំនួន 25g ។ គេចង់បន្សាបសូលុយស្យុងអាស៊ីតនេះដោយប្រើសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត ។ គណនា ៖

   ក. ម៉ាសសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតដែលត្រូវប្រើ

   ខ. ម៉ាសអំបិលដែលកកើត ។

   (គេឱ្យ ៖ H = 1 , O = 16 , Na = 23 , Cl = 35.5 )

# កំណែវិញ្ញាសាទី ៩

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ 3 ប្រភេទ ។

2. ក. ☑ $ZnCl_2$ ។

3. ក. ផលិតផល , បន្សាប ។

   ខ. អុកស៊ីសែន , ឧស្ម័នកាបូនឌីអុកស៊ីត ។

## II. ចម្លើយផ្គូផ្គងផ្នែកA និងផ្នែកB

$1 \rightarrow$ ឃ  $2 \rightarrow$ ច  $3 \rightarrow$ ង  $4 \rightarrow$ ក ។

## III. ចម្លើយសមីការ

1. $2K_{(s)} + 2H_2O_{(l)} \rightarrow 2KOH_{(aq)} + H_{2(g)}\nearrow$

2. $O_{2(g)} + 2Mg_{(s)} \rightarrow 2MgO_{(s)}$

3. $CaO_{(s)} + H_2O_{(l)} \rightarrow Ca(OH)_{2(aq)}$

4. $H_2SO_{4(aq)} + Cu(OH)_{2(s)} \rightarrow CuSO_{4(aq)} + 2H_2O_{(l)}$ ។

## IV. ចម្លើយលំហាត់

1. ក. ម៉ាសកាបូនចូលរួមប្រតិកម្ម

   សមីការតាងប្រតិកម្ម :

   $C_{(s)} + O_{2(g)} \rightarrow CO_{2(g)}$

   តាមសមីការ :

   គេប្រើ $C = 12g$ គេទទួលបាន $CO_2;44g$

   បើគេប្រើ $C;m_g$ គេទទួលបាន $CO_2;22g$

   យើងបាន $\frac{12}{m} = \frac{44}{22} \Rightarrow m = \frac{12 \times 22}{44} = 6g$

   ដូចនេះ $m_{(C)} = 6g$ ។

ខ. រកម៉ាសអុកស៊ីសែន

តាមសមីការ ៖

គេប្រើ $O_2$;32g គេទទួលបាន $CO_2$;44g

បើគេប្រើ $O_2$;$m_g$ គេទទួលបាន $CO_2$;22g

យើងបាន $\frac{32}{m} = \frac{44}{22} \Rightarrow m_{O_2} = \frac{32 \times 22}{44} = 16g$

ដូចនេះ $m_{(O_2)} = 16g$ ។

2. ក. ម៉ាសសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតដែលប្រើ

សមីការតាងប្រតិកម្ម

$$\underset{1mol}{HCl_{(aq)}} + \underset{1mol}{NaOH_{(aq)}} \rightarrow \underset{1mol}{NaCl} + \underset{1mol}{H_2O}$$

តាមសមីការ ៖

គេប្រើ HCl 36.5g គេទទួលបាន NaOH 40g

បើគេប្រើ HCl 25g គេទទួលបាន NaOH $m_g$ ?

យើងបាន $\frac{36.5}{25} = \frac{40}{m} \Rightarrow m = \frac{25 \times 40}{36.5} = 27.39g$

ដូចនេះម៉ាស NaOH $m_{NaOH} = 27.39g$ ។

ខ. ម៉ាសអំបិលកកើត

តាមសមីការ ៖

គេប្រើអាស៊ីត HCl 36.5g គេទទួលបានអំបិល NaCl 58.5g

បើគេប្រើអាស៊ីត HCl 25g គេទទួលបានអំបិល NaCl $m_g$ ?

យើងបាន $\frac{36.5}{25} = \frac{58.5}{m} \Rightarrow m_{NaCl} = \frac{25 \times 58.5}{36.5} = 40.07g$

ដូចនេះម៉ាសអំបិល NaCl គឺ $m_{NaCl} = 40.07g$ ។

# វិញ្ញាសាទី ១ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ទឹក ឧស្ម័នកាបូនិច និងថាមពល ជាផលិតផលរបស់ :

ក. ☐ ដំណុះគ្រាប់ ខ. ☐ រស្មីសំយោគ

គ. ☐ ការលូតលាស់ ឃ. ☐ ដង្ហើមរុក្ខជាតិ ។

2. អង់ទីកររត្រូវបានផលិតដោយ :

ក. ☐ ផាកូស៊ីត ខ. ☐ ឡាំផូស៊ីត T

គ. ☐ ឡាំផូស៊ីត B ឃ. ☐ ភ្នាក់ងារបង្ករោគ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ខួរក្បាលភ្ជាប់ទៅនឹងខួរឆ្អឹងខ្នងដោយ........................... ។

ខ. ដំណើររលួយនៃសារធាតុសរីរាង្គនៅក្នុងគំនរសំរាម ជាប្រភពបញ្ចេញ ឧស្ម័ន................ ដែលភាយចូលក្នុងបរិយាកាស ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ណឺរ៉ូនវិញ្ញាណនាំ<br>2. ណឺរ៉ូនចលករ<br>3. ណឺរ៉ូនភ្ជាប់ | ក. គឺដឹកនាំព័ត៌មានរវាងណឺរ៉ូនវិញ្ញាណនាំនិងចលករ<br>ខ. គឺដឹកនាំព័ត៌មានទៅកាន់មជ្ឈមណ្ឌលប្រសាទ<br>គ. គឺដឹកនាំព័ត៌មានទៅកាន់សាច់ដុំនិងក្រពេញ<br>ឃ. គឺដឹកនាំព័ត៌មានទៅពាសពេញសារពាង្គកាយ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ហេតុអ្វីបានជាយើងត្រូវលាងដៃ ក្រោយពេលចាប់កាន់វត្ថុកខ្វក់ ឬសត្វចិញ្ចឹម និងមុនពេលបរិភោគ ?
2. ដូចម្ដេចហៅថាវេជ្ជិច ? ចូរឱ្យឧទាហរណ៍ ។ តើវេជ្ជិចមានប្រយោជន៍ដូចម្ដេចខ្លះ ?
3. តើជំងឺឆ្លងជាអ្វី ? ចូរប្រាប់ឈ្មោះជំងឺឆ្លងនិងភ្នាក់ងារបង្កជំងឺនោះចំនួនបី ។
4. តើមានអ្វីកើតឡើងនៅពេលតំណបរលាក ? ចូរពន្យល់ ។
5. ក. តើខ្នាត់ទទឹងស្លឹកបង្ហាញឱ្យឃើញប្រភេទជាលិកាអ្វីខ្លះ ?

   ខ. តើជាលិកាប្រភេទនីមួយៗ មាននាទីដូចម្ដេចខ្លះ ?

# កំណែវិញ្ញាសាទី ១

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ ដង្កើមរុក្ខជាតិ ។
2. គ. ☑ ឡាំផូស៊ីត B ។
3. ក. ខួរកញ្ចឹងក

   ខ. មេតាន ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ខ     2 → គ     3 → ក ។

## III. ចម្លើយ

1. ព្រោះសកម្មភាពទាំងនេះ អាចឱ្យភ្នាក់ងារបង្ករោគ (ឬមេរោគ) ជាប់នៅលើដៃរបស់យើង ។ ប្រសិនបើភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងខ្លួនរបស់យើង នោះយើងអាចនឹងមានជំងឺជាមិនខាន ។
2. វេទ្លិចជាតំណបស្វ័យប្រវត្តិនិងអឆន្ទៈទៅនឹងរំញោចអ្វីមួយ ។ ចលនាវេទ្លិចមាននៅក្នុងសកម្មភាពប្រចាំថ្ងៃ ដូចជាព្រិចភ្នែក ការក្អកធ្វើឱ្យបំពង់កស្អាត ការដកដៃចេញពីវត្ថុក្តៅ... ។ វេទ្លិចមានប្រយោជន៍ណាស់ ព្រោះវាអាចការពារសារពាង្គកាយពីគ្រោះថ្នាក់ផ្សេងៗដែលកើតឡើងដោយចៃដន្យ ។
3. ជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ជំងឺនេះបណ្តាលមកពីភ្នាក់ងារបង្ករោគដូចជា វីរុស បាក់តេរី ផ្សិត និងប្រូទីស ។ ជំងឺផ្តាសាយធំបណ្តាលមកពីវីរុស ។ ជំងឺគ្រុនពោះវៀនបណ្តាលមកពីបាក់តេរី ។ ជំងឺជ្រាំងអណ្តាតបណ្តាលមកពីផ្សិត ។
4. នៅពេលតំណបរលាក កោសិកាឆ្លងរោគផលិតធាតុគីមីដែលបណ្តាលឱ្យសរសៃឈាមត្រង់មុខរបួសហើម ។ គោលិកាសជាច្រើន ធ្វើដំណើរតាម

ចរន្តឈាម ហូរទៅកាន់កន្លែងរបួស ។ នៅទីនោះធាតុរាវនិងគោលិកាស ជ្រៀតចេញតាមចន្លោះកោសិកានៃភ្នាសសរសៃឈាមប្លូរ ដែលធ្វើឱ្យកន្លែងមាន មេរោគឆ្លងឡើងក្រហមនិងហើមប៉ោង ។ នៅពេលគោលិកាសងាប់ កោ- សិកាឆ្លងរោគងាប់និងមេរោគងាប់ផ្សំជាមួយគ្នាហើយបង្កើតបានជាខ្ទុះដែល មានពណ៌លឿងភ្លាវ ឬ ស ។ ខ្ទុះធ្វើឱ្យរបួសមានពណ៌ក្រហម ហើម ប៉ោង និងក្តៅជាងពេលធម្មតា ។

5. ក. ខ្នាត់ទទឹងស្លឹកបង្ហាញថា គ្រប់ស្លឹករុក្ខជាតិទាំងអស់បង្កឡើងពីជាលិកា ការពារមាន អេពីឌែម ជាលិកាគ្រឹះមាន មេសូភីលនិងជាលិកានាំ មាន ទ្រនុងស្លឹក ។

ខ. ជាលិកានីមួយៗមានតួនាទី :

- ជាលិកាអេពីឌែមមាននាទីការពារកោសិកាផ្ទៃខាងក្នុងស្លឹកឱ្យផុតពី ភាពស្ងួតពេលពន្លឺព្រះអាទិត្យក្តៅខ្លាំង ។
- ជាលិកាមេសូភីលមាននាទីចាប់ថាមពលពន្លឺព្រះអាទិត្យស្តុកទុកនិងធ្វើ បណ្តូរឧស្ម័នរវាងកោសិកាក្នុងស្លឹកនិងមជ្ឈដ្ឋានខាងក្រៅ ដើម្បីផលិត អាហារសម្រាប់រុក្ខជាតិតាមរស្មីសំយោគ ។
- ជាលិកាទ្រនុងស្លឹកដឹកនាំទឹកនិងអំបិលខនិជពីឫសទៅស្លឹក និងដឹកនាំ អាហារពីស្លឹកទៅគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិ ។

# វិញ្ញាសាទី ២ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. លំហរវាងណឺរ៉ូនពីរជា ៖

ក. ☐ ដង់ឌ្រីត　　ខ. ☐ តួកោសិកា

គ. ☐ ស៊ីណាប់　　ឃ. ☐ អាក់សូន ។

2. ជំងឺដែលបង្កដោយវីរុសមាន ៖

ក. ☐ អុតស្វាយ　　ខ. ☐ របេង

គ. ☐ ស្រែង　　ឃ. ☐ គ្រុនចាញ់ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ស្រទាប់ក្រៅបង្អស់នៃផ្នែកខាងក្រោមនិងខាងលើផ្ទៃស្លឹកមានសារធាតុម្យ៉ាងភ្លឺរលោងដែលមានឈ្មោះថា............ ។

ខ. ផ្នែកសំខាន់ពីរនៃប្រព័ន្ធប្រសាទគឺ............និងបរិមណ្ឌលប្រសាទ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. រស្មីសំយោគ | ក. គឺជាលំនាំនៃការបញ្ចេញថាមពលពីម៉ូលេគុលគ្លុយកូស | 1. → |
| 2. រំភាយចំហាយទឹក | ខ. គឺជាលំនាំនៃការផ្ទេរថាមពលរបស់ភាវៈរស់ | 2. → |
| 3. ដង្ហើមរុក្ខជាតិ | គ. គឺជាលំនាំនៃការផលិតអាហារដោយប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ | 3. → |
| | ឃ. គឺជាលំនាំនៃការបាត់បង់ទឹកតាមស្តូម៉ាត | |

## III. សំណួរ

1. ក. តើរស្មីសំយោគជាអ្វី ? តើវាកើតនៅកន្លែងណា ?
   ខ. ប្រសិនបើគេបេះស្លឹកឈើអស់ពីដើម ដោយមិនឱ្យវាលូតលាស់រយៈពេលមួយឆ្នាំ តើដើមឈើនោះអាចរស់បានដោយគ្មានស្លឹកដែរឬទេ ? ហេតុអ្វី ?
2. ក. តើភ្នាក់ងារបង្ករោគជាអ្វី ? តើវារស់នៅកន្លែងណា ? តើមានភ្នាក់ងារបង្ករោគអ្វីខ្លះ ?
   ខ. តើភ្នាក់ងារបង្ករោគបណ្ដាលឱ្យមានជំងឺរបៀបណា ?
3. ក. ចូររាប់ធនធានធម្មជាតិកើតឡើងវិញនិងមិនកើតឡើងវិញយ៉ាងតិចបីក្នុងមួយបែប ។
   ខ. រវាងធនធានធម្មជាតិទាំងពីរ តើមួយណាដែលមនុស្សប្រើប្រាស់ច្រើនជាងគេ ? ហេតុអ្វី ?
4. តើកោសិកានៃប្រព័ន្ធប្រសាទមានឈ្មោះអ្វី ? ចូររៀបរាប់ពីរូបផ្គុំនិងនាទីរបស់វា ។
5. ក. តើជំងឺមហារីកជាអ្វី ? ហេតុអ្វីបានជាកើតជំងឺមហារីក ?
   ខ. តើផ្សែងបារីបង្កជំងឺមហារីកដែរឬទេ ?
   គ. តើត្រូវធ្វើដូចម្ដេចដើម្បីកាត់បន្ថយជំងឺមហារីក ?

# កំណែវិញ្ញាសាទី ២

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ ស៊ីណាប់ ។

2. ក. ☑ អុតស្វាយ ។

3. ក. គុយទីគុល

   ខ. មជ្ឈមណ្ឌលប្រសាទ ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ　　2 → ឃ　　3 → ក ។

## III. ចម្លើយ

1. ក. រស្មីសំយោគជាដំណើរការចាប់យកថាមពលពន្លឺព្រះអាទិត្យ ហើយប្រើប្រាស់ថាមពលនេះដើម្បីផលិតអាហារ ។ រស្មីសំយោគកើតមាននៅក្នុងស្លឹកនៃរុក្ខជាតិបៃតង ។

   ខ. ដើមឈើនោះមិនអាចរស់បានទេ ព្រោះវាមិនអាចផលិតអាហារសម្រាប់ចិញ្ចឹមផ្នែកផ្សេងៗនៃរុក្ខជាតិ ។

2. ក. សារពាង្គកាយតូចល្អិតដែលបង្កឱ្យមានជំងឺ ហៅថាភ្នាក់ងារបង្ករោគ ។ ភ្នាក់ងារបង្ករោគរស់នៅគ្រប់ទីកន្លែងទាំងអស់ក្នុងធម្មជាតិ ដូចជាក្នុងខ្យល់ លើដី ក្នុងទឹក លើស្បែករបស់យើង... ។ ភ្នាក់ងារបង្ករោគមានវីរុស បាក់តេរី ផ្សិត និងប្រូទីសមួយចំនួន ។

   ខ. ភ្នាក់ងារបង្ករោគជ្រៀតចូលក្នុងសារពាង្គកាយ តាមរយៈខ្យល់ដង្ហើម វត្ថុប្រើប្រាស់របស់អ្នកជំងឺ... ហើយបណ្ដាលឱ្យមានជំងឺ ។

3. ក. ធនធានធម្មជាតិកើតឡើងវិញមាន ពន្លឺ ព្រះអាទិត្យ ខ្យល់ ទឹក ដើមឈើ សត្វ... ។ ធនធានធម្មជាតិមិនកើតឡើងវិញមាន ត្បូងថ្ម ប្រេងកាត លោហៈ ឧស្ម័នធម្មជាតិ... ។

ខ. មនុស្សប្រើប្រាស់ធនធានធម្មជាតិកើតឡើងវិញច្រើនជាងគេ ព្រោះមនុស្សអាចរស់នៅបានដោយគ្មានប្រេង ឬលោហៈ ប៉ុន្តែមនុស្សមិនអាចរស់បានដោយគ្មានទឹកសាបសម្រាប់ផឹក ឬខ្យល់សម្រាប់ដកដង្ហើមទេ ។

4. កោសិកានៃប្រព័ន្ធប្រសាទហៅថា ណឺរ៉ូន ឬកោសិកាប្រសាទ ។ ណឺរ៉ូនដឹកនាំព័ត៌មានទៅពាសពេញសារពាង្គកាយ ។ ណឺរ៉ូននីមួយៗមានបីផ្នែក គឺដង់ឌ្រីត តួកោសិកា និងអាក់សូន ។ តួកោសិកាមានផ្ទុកណ្វៃយ៉ូ និងធាតុកោសិកាមួយចំនួន ។ ចុងម្ខាងនៃតួកោសិកាមានសរសៃឆ្មារៗច្រើន ហើយខ្លីដែលជាដង់ឌ្រីត ។ នៅចុងម្ខាងទៀតនៃតួកោសិកាមានពន្លយធំមួយហើយវែង ហៅថាអាក់សូន ។

5. ក. ជំងឺមហារីកបណ្តាលមកពីការលូតលាស់ខុសធម្មតានៃកោសិកាណាមួយដែលបង្កើតជាដុំមហារីក ។ ជំងឺមហារីកកើតឡើងដោយសារកាំរស្មី X កាំរស្មីស្វាយអ៊ុលត្រា កាកសំណល់គីមី... ។

ខ. ក្នុងផ្សែងបារីមានធាតុពុល (ជ័រថា) ដែលបង្កឱ្យកើតជំងឺមហារីក ។

គ. វិធីតែមួយគត់ដែលកាត់បន្ថយជំងឺមហារីក គឺការបង្ការ ។ យើងអាចបង្ការជំងឺមហារីកបានដោយមិនជក់បារី ចៀសវាងបរិភោគអាហារមានជាតិខ្លាញ់ច្រើន ផឹកស្រា ប្រើកាំរស្មី X ច្រើនហួសក្នុងការព្យាបាលជំងឺ ។

# វិញ្ញាសាទី ៣ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. អាំងភ្លួចប្រសាទធ្វើដំណើរឆ្លងកាត់ស៊ីណាប់តាមរយៈ ៖

ក. ☐ អូស្មូស

ខ. ☐ តួកោសិកា

គ. ☐ ណឺរ៉ូនភ្ជាប់

ឃ. ☐ សារធាតុគីមី ។

2. មេរោគអេដស៍ឆ្លងខ្លាំងជាងគេបំផុតនៅក្នុង ៖

ក. ☐ ដំណាក់តែសឈាមវិជ្ជមាន

ខ. ☐ ដំណាក់ចំហ

គ. ☐ ដំណាក់ជំងឺអេដស៍

ឃ. ☐ ដំណាក់ទាំងបីខាងលើ ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. របាំងការពារទីពីរជា.......................... ។

ខ. ឧស្ម័នស្ពាន់ធ័រឌីអុកស៊ីតនិងអាសូតម៉ូណូអុកស៊ីតត្រូវបានបញ្ចេញពីរោងចក្រទៅក្នុងបរិយាកាស ។ ឧស្ម័នទាំងនេះរលាយនៅក្នុងទឹកភ្លៀងហើយបង្កើតជា.................. ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ភាពស៊ាំសកម្ម<br>2. ភាពស៊ាំអកម្ម<br>3. ភាពស៊ាំសកម្មសិប្បនិមិត្ត | ក. គឺអភិវឌ្ឍតាមរយៈការបរិភោគអាហារមានសារធាតុចិញ្ចឹមគ្រប់គ្រាន់<br>ខ. គឺអភិវឌ្ឍតាមរយៈតំណបទៅនឹងវ៉ាក់សាំង<br>គ. គឺអភិវឌ្ឍតាមរយៈការប៉ះពាល់ទៅនឹងភ្នាក់ងារបង្ករោគ<br>ឃ. គឺទទួលបានតាមរយៈទឹកដោះម្ដាយ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ក. តើជំងឺទឹកនោមផ្អែមជាអ្វី ? តើវាជាជំងឺឆ្លងដែរឬទេ ? ហេតុអ្វី ?
   ខ. តើរោគសញ្ញាជំងឺទឹកនោមផ្អែមជារោគសញ្ញាជំងឺប្រដាប់ទឹកនោមដែរឬទេ ? ហេតុអ្វី ?
2. តើធនធានធម្មជាតិកើតឡើងវិញជាអ្វី ? តើវាអាចហិនហោចដែរឬទេ ? ចូរពន្យល់ ។
3. ក. តើស្លឹករុក្ខជាតិមានពណ៌បៃតងដោយសារអ្វី ? ហើយមាននាទីធ្វើអ្វី ?
   ខ. ហេតុអ្វីផ្ទៃខាងលើស្លឹករុក្ខជាតិមានពណ៌បៃតងចាស់ជាងផ្ទៃខាងក្រោម ?
4. ប្រសិនបើខួរតូចខូចខាត តើនឹងមានបញ្ហាអ្វីកើតឡើង ? ចូរពន្យល់ហើយកំណត់នាទីរបស់ខួរតូច ។
5. ក. តើវីរុសជាអ្វី ? តើវាមានរូបផ្គុំដូចម្ដេច ? ចូរប្រាប់ឈ្មោះជំងឺបង្កដោយវីរុសចំនួន 3 ។
   ខ. តើគេអាចប្រើវីរុសធ្វើអ្វីដែរ ? ចូរពន្យល់ ។

# កំណែវិញ្ញាសាទី ៣

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ សារធាតុគីមី ។
2. ខ. ☑ ដំណាក់ចំហ ។
3. ក. តំណបរលាក

   ខ. ភ្លៀងអាស៊ីត ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ　　2 → ឃ　　3 → ខ ។

## III. ចម្លើយ

1. ក. ជំងឺដែលបរិមាណគ្លុយកូសក្នុងឈាមលើស ហើយត្រូវបញ្ចេញចោលទៅក្នុងទឹកនោម ។ ជំងឺទឹកនោមផ្អែមជាជំងឺមិនឆ្លង ព្រោះជំងឺនេះមិនបណ្តាលមកពីភ្នាក់ងារបង្ករោគទេ ។

   ខ. វាមិនមែនជារោគសញ្ញាជំងឺប្រដាប់ទឹកនោមទេ ព្រោះជំងឺទឹកនោមផ្អែមបណ្តាលមកពីលំពែងផលិតអរម៉ូនអាំងស៊ុយលីនមិនគ្រប់គ្រាន់ ឬមិនផលិត ។

2. ជាធនធានដែលបាតុភូតធម្មជាតិនឹងបង្កើតឡើងវិញនៅពេលប្រើប្រាស់អស់ ។ ធនធានធម្មជាតិកើតឡើងវិញអាចហិនហោចទៅវិញបាន ប្រសិនបើមនុស្សប្រើប្រាស់វាលឿនជាងការកើតឡើងវិញ ។ សកម្មភាពផ្សេងៗរបស់មនុស្សបានបំផ្លាញធនធានទាំងនេះបន្តិចម្តងៗ ។ ឧទាហរណ៍ ៖ ការនេសាទត្រីច្រើនហួសដូចជានេសាទនៅរដូវត្រីពង ប្រើប្រាស់ឧបករណ៍នេសាទហាមឃាត់ ប្រើខ្សែភ្លើងឆក់បណ្តាលឱ្យត្រីតូចៗងាប់ពាយ... ។

3. ក. ស្លឹករុក្ខជាតិមានពណ៌បៃតងដោយសារជាតិពណ៌បៃតង (ក្លរ៉ូភីល) ។ ស្លឹកមាននាទីផលិតអាហារសម្រាប់រុក្ខជាតិលូតលាស់ ។

ខ. ស្រទាប់លើនៃផ្ទៃស្លឹករុក្ខជាតិជាស្រទាប់កោសិកាមេសូភីលប៉ាលីសាត ។ ស្រទាប់នេះមានក្លរ៉ូប្លាសច្រើនជាងស្រទាប់ក្រោមដែលជាកោសិកាមេសូភីលស្ពោត ។ ដោយសារក្លរ៉ូប្លាសផ្ទុកជាតិពណ៌បៃតង ដូចនេះផ្ទៃលើនៃស្លឹកមានពណ៌បៃតងចាស់ជាងផ្ទៃក្រោមនៃស្លឹក ។

4. ដើម្បីចាប់កាន់ខ្មៅដៃមួយបាន សាច់ដុំភ្នែក សាច់ដុំដៃ និងម្រាមដៃត្រូវតែធ្វើសកម្មភាពជាមួយគ្នាដោយរលូន ។ ខួរតូចជាអ្នកបញ្ជាឱ្យសាច់ដុំទាំងនេះធ្វើសកម្មភាពព្រមគ្នានិងដោយរលូន ។ ប្រសិនបើខួរតូចខូចខាត សកម្មភាពទាំងនេះមិនដំណើរការព្រមគ្នាទេ ហើយយើងក៏គ្មានលទ្ធភាពចាប់កាន់ខ្មៅដៃឱ្យបានជាប់ដែរ ។ ដូចនេះខួរតូចមាននាទីបញ្ជាចលនាសាច់ដុំឱ្យធ្វើការព្រមគ្នានិងដោយរលូន ។

5. ក. ជាភាគតូចល្អិតបំផុតដែលគេមិនអាចមើលឃើញដោយមីក្រូទស្សន៍ធម្មតាបានទេ ។ វីរុសបង្កឡើងពីសំបកប្រូតេអ៊ីនរុំព័ទ្ធពីក្រៅសម្រាប់ការពារនិងស្ទួលជាសម្ភារៈតំណពូជសម្រាប់បង្កើតវីរុសថ្មីៗទៀត ។ ជំងឺបង្កឡើងដោយវីរុសមានជំងឺផ្តាសាយ ជំងឺគ្រុនស្វិតដៃជើង ជំងឺកញ្ជ្រឹល ជំងឺអេដស៍... ។

ខ. សព្វថ្ងៃអ្នកស្រាវជ្រាវអាចបំប្លែងលក្ខណៈចម្រៃរបស់វីរុសឱ្យខ្សោយហើយប្រើប្រាស់វាជាវ៉ាក់សាំងសម្រាប់ចាក់បង្ការជំងឺធ្ងន់ៗមួយចំនួន ។ បច្ចុប្បន្ន មានវ៉ាក់សាំងជំងឺកញ្ជ្រឹល វ៉ាក់សាំងជំងឺអុតស្វាយ... ។

# វិញ្ញាសាទី ៤ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ធាតុកោសិកាដែលជាកន្លែងធ្វើរស្មីសំយោគគឺ :

ក. ☐ មីតូកុងឌ្រី

ខ. ☐ ណៃយ៉ូ

គ. ☐ វ៉ាគុយអូល

ឃ. ☐ ក្លរ៉ូប្លាស ។

2. ផ្នែកដែលទាក់ទងនឹងចលនាវេទ្លិចជា :

ក. ☐ ខួរធំ

ខ. ☐ ខួរតូច

គ. ☐ ខួរឆ្អឹងខ្នង

ឃ. ☐ ខួរកញ្ចឹងក ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. អង់ទីសែនបណ្តាលឱ្យសារពាង្គកាយផលិត.......................... ។

ខ. សារធាតុគីមីដែលធ្វើឱ្យស្រទាប់អូស្សូនស្តើងគឺ......................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. អង់ទីករ<br>2. អង់ទីសែន<br>3. អាំងទែផេរ៉ុង | ក. ជាសារធាតុគីមីបង្ការមិនឱ្យវីរុសបន្តពូជលើកោសិកាមិនបានបង្ករោគ<br>ខ. ជាសារធាតុគីមីដែលផលិតឡើងដោយបាក់តេរី<br>គ. ជាសារធាតុគីមីដែលផលិតឡើងក្នុងសារពាង្គកាយ<br>ឃ. ជាសារធាតុគីមីដែលប្រឆាំងដោយសារពាង្គកាយ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. តើកង្វក់ខ្យល់បណ្ដាលមកពីអ្វីខ្លះ ?
2. ក. តើរុក្ខជាតិប្រភេទណាមានដំណើររស្មីសំយោគ ? តើរស្មីសំយោគប្រព្រឹត្តទៅនៅក្នុងផ្នែកណាខ្លះនៃរុក្ខជាតិ ?
   ខ. តើរស្មីសំយោគមានសារៈសំខាន់ចំពោះរុក្ខជាតិដូចម្ដេចខ្លះ ?
3. ដូចម្ដេចហៅថាស៊ីណាប់ ? តើអាំងភ្លុចប្រសាទឆ្លងកាត់ស៊ីណាប់ដូចម្ដេច ?
4. ក. តើជំងឺកាមរោគជាអ្វី ? តើវាជាជំងឺតពូជដែរឬទេ ? ហេតុអ្វី ?
   ខ. តើភ្នាក់ងារបង្កជំងឺកាមរោគមានអ្វីខ្លះ ? ចូររាប់ឈ្មោះជំងឺកាមរោគចំនួន 6 ។
5. តើរបាំងការពារទីមួយក្នុងការសម្លាប់មេរោគមានលក្ខណៈដូចម្ដេចខ្លះ ?

# កំណែវិញ្ញាសាទី ៤

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ ក្លរ៉ូប្លាស ។
2. គ. ☑ ខួរឆ្អឹងខ្នង ។
3. ក. អង់ទីករ

   ខ. ក្លរ៉ូភ្លុយរ៉ូកាបូន ($CFC_5$) ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ខ 3 → ក ។

## III. ចម្លើយ

1. ឧស្ម័នកាបូនិច ឧស្ម័នស្ពាន់ធ័រអុកស៊ីត និងឧស្ម័នផ្សេងៗទៀត ដែលបញ្ចេញដោយយានយន្ត រោងចក្រ...ទៅក្នុងបរិយាកាសបណ្តាលឱ្យមានកង្វក់ខ្យល់ ។ កង្វក់ខ្យល់បង្កគ្រោះថ្នាក់ដល់សុខភាពមនុស្សនិងសត្វ ។
2. ក. គ្រប់រុក្ខជាតិបៃតងទាំងអស់តែងកើតមានដំណើររស្មីសំយោគ ។ រស្មីសំយោគប្រព្រឹត្តទៅជាពិសេសក្នុងស្លឹកពណ៌បៃតង ដើមខ្ចីមានពណ៌បៃតងរបស់រុក្ខជាតិ ។

   ខ. រស្មីសំយោគមានសារៈសំខាន់ចំពោះរុក្ខជាតិ ព្រោះអាហារដែលផលិតបានតាមដំណើររស្មីសំយោគនេះត្រូវបានប្រើប្រាស់សម្រាប់ការលូតលាស់និងធំធាត់របស់រុក្ខជាតិ ។ ដូចនេះប្រសិនបើគ្មានដំណើរការនេះទេ រុក្ខជាតិបៃតងមិនអាចរស់រានមានជីវិតទេ ។

3. ស៊ីណាប់ជាលំហតូចមួយដែលស្ថិតនៅចន្លោះអាក់សូននៃណឺរ៉ូនមួយនិងដង់ឌ្រីតនៃណឺរ៉ូនក្បែរគ្នា ។ នៅពេលអាំងភ្លុចធ្វើដំណើរដល់ស្នាញអាក់សូនកំពកស៊ីណាប់ក៏ផ្ទុះបែក ហើយបញ្ចេញសារធាតុគីមីដែលសាយឆ្លងកាត់ស៊ីណាប់ ។ នៅផ្នែកម្ខាងទៀតសារធាតុគីមីនេះបង្កើតអាំងភ្លុចជាថ្មីក្នុងដង់ឌ្រីតនៃណឺរ៉ូនក្បែរគ្នា ។ តាមវិធីនេះអាំងភ្លុចធ្វើដំណើរឆ្លងកាត់ពីណឺរ៉ូនមួយទៅមួយទៀត ។

4. ក. ជាជំងឺដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈការរួមភេទជាមួយដៃគូដែលមានជំងឺកាមរោគ ។ ជំងឺកាមរោគមិនមែនជាជំងឺតពូជទេ ព្រោះជំងឺនេះមិនបញ្ជូនពីជំនាន់មួយទៅជំនាន់មួយទៀតទេ ហើយវាបង្កឡើងដោយភ្នាក់ងារបង្ករោគ ។

   ខ. ភ្នាក់ងារបង្កជំងឺកាមរោគមាន បាក់តេរី វីរុស និងផ្សិត ។ ជំងឺកាមរោគមានជំងឺ ស្វាយ ប្រមេះ សិរមាន់ សង់ម្វូ ទាមទ្បា និងជំងឺអេដស៍ ។

5. ប្រេងនិងញើសរបស់ស្បែកធ្វើឱ្យផ្ទៃស្បែកមានជាតិអាស៊ីត ដែលបង្អាក់ការលូតលាស់របស់មេរោគ ។ ញើសមានអង់ស៊ីមសម្រាប់សម្លាប់បាក់តេរី ។ ទឹកភ្នែកក៏មានអង់ស៊ីមសម្រាប់សម្លាប់មេរោគដែរ ។ រោមច្រមុះនិងស្លេស្មទាក់យកកម្ទេចធូលីនិងមេរោគ ។ ក្នុងទងសួតនិងកូនទងសួតមានរោមញ័រនិងភ្នាសស្លេស្ម ដែលទាក់ចាប់មេរោគ ហើយបញ្ជូនស្លេស្មនិងមេរោគចេញតាមកំហាកនិងសំបោរ ។ ទឹកមាត់មានអង់ស៊ីមសម្រាប់សម្លាប់មេរោគឯក្រពះមានជាតិអាស៊ីតនិងអង់ស៊ីមសម្រាប់សម្លាប់មេរោគជ្រៀតចូលតាមអាហារ ។

# វិញ្ញាសាទី ៥ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. វ៉ាក់សាំងផ្ដល់នូវ ៖

ក. ☐ ភាពស៊ាំអកម្ម

ខ. ☐ ផាកូស៊ីត

គ. ☐ ភាពស៊ាំសកម្ម

ឃ. ☐ ឡាំផូស៊ីត ។

2. ជំងឺមិនឆ្លងមាន ៖

ក. ☐ លើសឈាម

ខ. ☐ ជំងឺផ្ដៅស្អូត

គ. ☐ ជំងឺគ្រុនស្វិតដៃជើង

ឃ. ☐ ជំងឺកញ្ជ្រឹល ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ស្រទាប់របស់ស្លឹកដែលកើតឡើងពីកោសិកាក្រាស់តែមួយស្រទាប់ ហើយមានលក្ខណៈថ្លា ដោយសារវាមានជាតិពណ៌តិចតួច ឬគ្មាន មានឈ្មោះថា............ ។

ខ. ដង់ឌ្រីតទទួលនិងបញ្ជូន.......... ទៅកាន់តួកោសិកា ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ធនធានធម្មជាតិ<br>2. ធនធានធម្មជាតិកើតឡើងវិញ<br>3. ធនធានធម្មជាតិមិនកើតឡើងវិញ | ក. ជារូបធាតុដែលផលិតចេញពីរោងចក្រ សហគ្រាស...<br>ខ. ជារូបធាតុនៅក្នុងធម្មជាតិដែលភាវៈរស់ប្រើប្រាស់សម្រាប់តម្រូវការក្នុងការរស់នៅ<br>គ. ជារូបធាតុដែលអាចជំនួសឡើងវិញបានដោយធម្មជាតិ<br>ឃ. ជារូបធាតុដែលអាចរកបានក្នុងបរិមាណកំណត់ប៉ុណ្ណោះ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ចូររាប់ធនធានធម្មជាតិក្នុងដី លើដី ក្នុងទឹក និងក្នុងព្រៃ ។
2. ក. ដូចម្តេចហៅថាដង្ហើមរុក្ខជាតិ ? តើរុក្ខជាតិដកដង្ហើមតាមណា ? ហើយនៅពេលណា ?

   ខ. តើក្នុងដំណើរដង្ហើមមានអ្វីកើតឡើង ?
3. ចូររៀបរាប់ពីរោគសញ្ញានៃជំងឺអេដស៍ ។ តើវិធានការបង្ការណាមួយមានប្រសិទ្ធភាពបំផុតសម្រាប់យុវវ័យ ?
4. ក. តើបរិមណ្ឌលប្រសាទមានសរសៃប្រសាទអ្វីខ្លះ ? ហើយមាននាទីធ្វើអ្វី ?

   ខ. តើបរិមណ្ឌលប្រសាទមានប៉ុន្មានផ្នែក ? អ្វីខ្លះ ? ហើយមាននាទីធ្វើអ្វីខ្លះ ?
5. តើភាពស៊ាំជាអ្វី ? តើមានភាពស៊ាំអ្វីខ្លះ ? ចូរពន្យល់ ។

# កំណែវិញ្ញាសាទី ៥

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ ភាពស៊ាំសកម្ម ។
2. ក. ☑ លើសឈាម ។
3. ក. អេពីឌែម

   ខ. ព័ត៌មាន (អាំងភ្លួចប្រសាទ) ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ខ    2 → គ    3 → ឃ ។

## III. ចម្លើយ

1. ធនធានធម្មជាតិក្នុងដីមាន រ៉ែ លើដីមាន ដើមឈើ ដំណាំ ក្នុងទឹកមាន សត្វទឹក ផ្កាថ្ម ក្នុងព្រៃមាន សត្វព្រៃនិងរុក្ខជាតិ ។
2. ក. ដំណើរការដែលរុក្ខជាតិបៃតងទទួលបានថាមពលពីម៉ូលេគុលគ្លុយកូស ។ ឫស ដើម ស្លឹក ផ្កា ផ្លែ គ្រាប់ ចូលរួមក្នុងដំណើរការដង្ហើម ។ រុក្ខជាតិដកដង្ហើមខ្លាំងនៅពេលគ្មានពន្លឺព្រះអាទិត្យ ។

   ខ. ក្នុងដំណើរដង្ហើម កោសិការុក្ខជាតិបំបែកអាហារងាយ (គ្លុយកូស) ហើយបញ្ចេញថាមពលដែលស្តុកទុកក្នុងម៉ូលេគុលអាហារនោះ ។
3. អ្នកជំងឺអេដស៍មានរោគសញ្ញាអស់កម្លាំងល្ហិតល្ហៃជាប្រចាំ គ្រុនក្តៅបែកញើសនៅពេលយប់ ជ្រាំងអណ្តាត រមាស់លើស្បែក រោគស្ងួតញឹកញាប់ ហើមកូនកណ្តុរនៅក្លៀក គ្រលៀន និងក ផ្សិតក្នុងមាត់ ឬបំពង់ក ជ្រុះសក់ ស្រកទម្ងន់ រាគរ៉ាំរ៉ៃ ។ អាការៈទាំងនេះធ្ងន់ធ្ងររហូតដល់ស្លាប់ ។ វិធានការបង្ការជំងឺអេដស៍សម្រាប់យុវវ័យ គឺតមការរួមភេទ ។

4. ក. បរិមណ្ឌលប្រសាទកើតឡើងពីសរសៃប្រសាទលលាដ៍ក្បាល 12 គូដែលចេញពីខួរក្បាលនិងសរសៃប្រសាទឆ្អឹងខ្នង 31 គូដែលចេញពីខួរឆ្អឹងខ្នង ។ បរិមណ្ឌលប្រសាទដឹកនាំព័ត៌មានរវាងមជ្ឈមណ្ឌលប្រសាទនិងផ្នែកផ្សេងៗនៃសារពាង្គកាយ ។

ខ. បរិមណ្ឌលប្រសាទចែកចេញជាពីរផ្នែកគឺ ប្រព័ន្ធប្រសាទសូម៉ាទិច និង ប្រព័ន្ធប្រសាទស្វ័យប្រវត្តិ ។ ប្រព័ន្ធប្រសាទសូម៉ាទិចត្រួតពិនិត្យនិងសម្របសម្រួលចលនាឆន្ទៈនៃសារពាង្គកាយ ។ ប្រព័ន្ធប្រសាទស្វ័យប្រវត្តិតម្រូវចលនាអឆន្ទៈនៃសរីរាង្គក្នុង ។

5. សមត្ថភាពធន់ទៅនឹងជំងឺយថាប្រភេទណាមួយ ។ ភាពស៊ាំមានពីរប្រភេទគឺ ភាពស៊ាំសកម្មនិងភាពស៊ាំអកម្ម ។ ភាពស៊ាំសកម្មជាភាពស៊ាំដែលប្រព័ន្ធស៊ាំនៃសារពាង្គកាយបង្កើតឡើងតាមរយៈការផលិតអង់ទីករសម្រាប់បង្អាក់សកម្មភាពអង់ទីសែននៃមេរោគ ។ អង់ទីករនេះនៅក្នុងឈាមរហូត ហើយក្លាយជាសកម្មវិញ ពេលមេរោគដដែលបង្កជំងឺម្តងទៀត ។ ភាពស៊ាំអកម្មកើតឡើងតាមរយៈការទទួលយកអង់ទីករពីឈាមរបស់សារពាង្គកាយមួយផ្សេងទៀត ។

# វិញ្ញាសាទី ៦ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដង្កើមរុក្ខជាតិកើតមាននៅក្នុង :

ក. ☐ ណែវ្យូ

ខ. ☐ ក្លរ៉ូប្លាស

គ. ☐ មីតូកុងឌ្រី

ឃ. ☐ វ៉ាគុយអូល ។

2. សារធាតុដែលធ្វើឱ្យស្រទាប់អូសូនស្តើងជា :

ក. ☐ ឧស្ម័នកាបូនិច

ខ. ☐ ក្លរ៉ូភ្លុយរ៉ូកាបូន

គ. ☐ អាសូតម៉ូណូកាបុកស៊ីល

ឃ. ☐ ស្ពាន់ធ័រឌីអុកស៊ីត ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ការកន្ត្រាក់នៃជង្គង់ជាឧទាហរណ៍មួយនៃ........... ។

ខ. ប្លាស្មូដ្យូមជាប្រភេទស៊្យូរ៉ូសូអ៊ែដែលបង្កជំងឺ.........ដល់មនុស្សតាមរយៈមូសដែកគោលញី ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. កង្វក់ខ្យល់<br>2. កង្វក់ទឹក<br>3. កង្វក់ដី | ក. ជាសារធាតុគីមីមួយចំនួនដែលបណ្ដាលឱ្យដីមានជាតិពុល<br>ខ. ជាសារធាតុគីមីមួយចំនួនដែលធ្វើឱ្យមជ្ឈដ្ឋានជុំវិញមិនស្អាត ឬគ្មានសុខភាព<br>គ. ជាសារធាតុគីមីមួយចំនួនដែលធ្វើឱ្យបរិយាកាសមិនស្អាត<br>ឃ. ជាសារធាតុគីមីមួយចំនួនដែលធ្វើឱ្យប្រភពទឹកកខ្វក់ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. តើបាក់តេរីជាអ្វី ? តើបាក់តេរីមានប៉ុន្មានប្រភេទ ? អ្វីខ្លះ ?
2. ដូចម្ដេចហៅថាសរសៃប្រសាទ ? តើមានសរសៃប្រសាទអ្វីខ្លះ ? ហើយមាននាទីដូចម្ដេច ?
3. តើយើងត្រូវធ្វើដូចម្ដេច ដើម្បីរក្សាធនធានធម្មជាតិឱ្យមានស្ថិរភាព ?
4. រវាងភាពស៊ាំអកម្មសិប្បនិមិត្តនិងភាពស៊ាំសកម្មសិប្បនិមិត្ត តើមានលក្ខណៈខុសគ្នាដូចម្ដេចខ្លះ ?
5. តើដំណើររស្មីសំយោគនិងដង្ហើមរុក្ខជាតិមានទំនាក់ទំនងគ្នាដូចម្ដេចខ្លះ ?

# កំណែវិញ្ញាសាទី ៦

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ មីតូកុងឌ្រី ។
2. ខ. ☑ ក្លរ៉ូភ្លយរ៉ូកាបូន ។
3. ក. រេផ្លិច

   ខ. គ្រុនចាញ់ ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ឃ 3 → ក ។

## III. ចម្លើយ

1. បាក់តេរីជាសារពាង្គកាយឯកកោសិកា ដែលគ្មានណ្វៃយ៉ូពិតប្រាកដ (ឬណ្វៃយ៉ូគ្មានភ្នាសព័ទ្ធជុំវិញ) ។ បាក់តេរីចែកចេញជាបីប្រភេទ គឺបាក់តេរីមានរាងស្វ៊ែហៅថាកុកស៊ី រាងដំបងហៅថាបាស៊ី និងរាងជាស្ពៀហៅថាស្ពៀរីឡូម ។
2. សរសៃប្រសាទជាបណ្តុំនៃបាច់ប្រសាទ ។ សរសៃប្រសាទចែកជាពីរក្រុម គឺសរសៃប្រសាទវិញ្ញាណនាំនិងសរសៃប្រសាទចលករ ។ សរសៃប្រសាទវិញ្ញាណនាំបញ្ជូនអាំងភ្លូចប្រសាទចេញពីសរីរាង្គវិញ្ញាណទៅកាន់មជ្ឈមណ្ឌលប្រសាទ ។ សរសៃប្រសាទចលករបញ្ជូនអាំងភ្លូចប្រសាទចេញពីមជ្ឈមណ្ឌលប្រសាទទៅកាន់សាច់ដុំ ឬក្រពេញ ។
3. ដើម្បីរក្សាធនធានធម្មជាតិឱ្យមានស្ថិរភាព គឺយើងត្រូវប្រើប្រាស់ដោយសន្សំសំចៃ និងមានប្រសិទ្ធភាពបំផុតចំពោះធនធានធម្មជាតិកើតឡើងវិញ ។

ចំពោះធនធានធម្មជាតិមិនកើតឡើងវិញ យើងត្រូវប្រើប្រាស់មិនឱ្យលឿនជាងអ្វីដែលអាចយកមកបំពេញជំនួសវិញបាន ។

4. ចំពោះភាពស៊ាំអកម្មសិប្បនិមិត្ត រាងកាយទទួលបានអង់ទីករពីសត្វ ឬមនុស្សដែលធ្លាប់មានជំងឺនោះ តាមរយៈការចាក់បញ្ចូល ហើយវត្តមានរបស់ភាពស៊ាំនេះមានរយៈពេលខ្លី ។ ចំពោះភាពស៊ាំសកម្មសិប្បនិមិត្ត រាងកាយបង្កើតអង់ទីករដោយផ្ទាល់ ក្រោយពេលចាក់បញ្ចូលថ្នាំបង្ការោគ ហើយភាពស៊ាំនេះស្ថិតនៅក្នុងរាងកាយពេញមួយជីវិត ។

5. ដំណើររស្មីសំយោគជាលំនាំមួយផ្ទុយពីដំណើរដង្ហើម ។ ប៉ុន្តែវាមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ។ ក្នុងរុក្ខជាតិ គ្លុយកូសត្រូវបានបំបែកតាមដំណើរដង្ហើម ដើម្បីបញ្ចេញថាមពល ។ ផលិតផលដែលទទួលបានពីដង្ហើមគឺឧស្ម័នកាបូនិច ទឹក និងថាមពល ។ ផលិតផលចុងក្រោយនេះត្រូវបានប្រើប្រាស់សារជាថ្មី ដើម្បីបង្កើតគ្លុយកូសតាមដំណើររស្មីសំយោគ ។ ដំណើរការទាំងពីរនេះរួមគ្នាបង្កើតបានជាវដ្តមួយដែលរក្សាស្ថិរភាពនៃកម្រិតអុកស៊ីសែននិងឧស្ម័នកាបូនិច នៅក្នុងបរិយាកាសនៃផែនដីមានន័យថា ភាវៈរស់ទាំងអស់ប្រើប្រាស់ឧស្ម័នទាំងពីរនេះម្តងហើយម្តងទៀត ។

# វិញ្ញាសាទី ៧ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ភ្នាក់ងារបង្កជំងឺបណ្តាលឱ្យប្រព័ន្ធស៊ាំផលិត ៖

ក. ☐ អង់ទីសែន

ខ. ☐ អង់ទីករ

គ. ☐ ប្លាកែត

ឃ. ☐ ប្លាស្មា ។

2. ការបញ្ចេញកាកសំណល់ពីរោងចក្រនិងលូទឹកសំអុយចូលក្នុងជ្រោះ អូរ បឹង ស្ទឹង មហាសមុទ្រនាំឱ្យ ៖

ក. ☐ កង្វក់ដី

ខ. ☐ កង្វក់ខ្យល់

គ. ☐ កង្វក់ទឹក

ឃ. ☐ កង្វក់បរិស្ថាន ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. លំហធំៗនៅក្នុងស្រទាប់មេសូភីលស្ពោតមានមុខងារផ្ទុក............ ។

ខ. ភាពស៊ាំដែលកើតឡើងក្រោយកំណើតជា........................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ជាលិកាគ្រឹះ<br>2. ជាលិកាការពារ<br>3. ជាលិកានាំ | ក. គឺជាក្រុមកោសិកាដែលមាននាទីដឹកនាំនៅក្នុងរុក្ខជាតិ<br>ខ. គឺជាស្រទាប់កោសិកាដែលទទួលរងការធ្វើចំណែកកោសិកាយ៉ាងសកម្ម<br>គ. គឺជាស្រទាប់កោសិការស្មើសំយោគនៅចន្លោះអេពីឌែមលើនិងអេពីឌែមក្រោមនៃស្លឹក<br>ឃ. គឺជាស្រទាប់កោសិកាថ្លាដែលអាចឱ្យពន្លឺជ្រៀតចូលដល់កោសិកាស្រទាប់ក្នុង | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ហេតុអ្វីនៅពេលយប់ យើងមិនគួរដាក់ដើមផ្កា ឬរុក្ខជាតិលំអច្រើនក្នុងបន្ទប់ដេកដោយបិទទ្វារនិងបង្អួចជិតអស់ ?
2. តើសកម្មភាពរបស់មនុស្សអាចធ្វើឱ្យបរិស្ថានប្រែប្រួលដែរឬទេ ? តើមានសកម្មភាពអ្វីខ្លះ ?
3. ក. តើប្រព័ន្ធស៊ាំបង្កឡើងពីអ្វីខ្លះ ?

   ខ. តើប្រព័ន្ធស៊ាំជួយសារពាង្គកាយយ៉ាងដូចម្ដេច ?
4. ក. តើខួរឆ្អឹងខ្នងស្ថិតនៅកន្លែងណា ? ហើយការពារដោយអ្វី ?

   ខ. តើខួរឆ្អឹងខ្នងមានទំនាក់ទំនងជាមួយសារពាង្គកាយយ៉ាងដូចម្ដេច ?
5. ចូរពណ៌នាពី ជំងឺចំនួនបីដែលបង្កឡើងដោយប្រូទីស ។

# កំណែវិញ្ញាសាទី ៧

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ អង់ទីករ ។
2. គ. ☑ កង្វក់ទឹក ។
3. ក. ឧស្ម័នកាបូនិច
   ខ. ភាពស៊ាំអកម្ម ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ឃ 3 → ក ។

## III. ចម្លើយ

1. យើងមិនគួរដាក់ផើងផ្កា ឬរុក្ខជាតិលំអក្នុងបន្ទប់ដេកបិទជិតនោះទេ ព្រោះនៅពេលយប់ដំណើរដង្ហើមរុក្ខជាតិប្រព្រឹត្តទៅយ៉ាងខ្លាំងក្លា ដែលធ្វើឱ្យបរិមាណឧស្ម័ន $CO_2$ កើនឡើង ហើយឧស្ម័ន $O_2$ ថយចុះ ។ លក្ខខណ្ឌបែបនេះធ្វើឱ្យមនុស្សដេកក្នុងបន្ទប់មានការថប់ដង្ហើម ដោយសារខ្វះ $O_2$ ដកដង្ហើម ហើយពុលដោយសារឧស្ម័ន $CO_2$ ដែលមានបរិមាណច្រើន ។
2. សកម្មភាពផ្សេងៗរបស់មនុស្សក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មានឥទ្ធិពលទៅលើការប្រែប្រួលនៃពិភពធម្មជាតិ ។
   សកម្មភាពទាំងនោះមាន ៖
   - ការទាញយកផលពីធម្មជាតិដូចជា ត្រី រ៉ែ...
   - ការបោះចោលកាកសំណល់ក្នុងបរិស្ថានដូចជា កាកសំណល់រឹង រាវ...
   - ការបំផ្លាញជម្រកធម្មជាតិដូចជា ការឆ្ការព្រៃធ្វើផ្លូវ ឬចម្ការ... ។

3. ក. ប្រព័ន្ធស៊ាំបង្កឡើងពីគោលិកាស ជាពិសេសផាកូស៊ីតនិងឡាំផូស៊ីតព្រម ទាំងជាលិកានៃប្រព័ន្ធទឹករងៃ ដូចជាកូនកណ្ដុរទឹករងៃ អាមីដាល ទីមុស និងផាល ។

ខ. ប្រព័ន្ធស៊ាំផ្ដល់ឱ្យសារពាង្គកាយនូវភាពស៊ាំ ដែលជាសមត្ថភាពប្រឆាំង នឹងការបង្កជំងឺតាមរយៈការផលិតអង់ទីករ ដើម្បីបង្អាក់សកម្មភាពរបស់ មេរោគ ។

4. ក. ខួរឆ្អឹងខ្នងស្ថិតនៅក្នុងប្រហោងនៃឆ្អឹងកងនីមួយៗរបស់ឆ្អឹងខ្នង ។ ខួរឆ្អឹង ខ្នងត្រូវបានការពារដោយឆ្អឹងខ្នង ស្រោមខួរនិងទឹកខួរ ។

ខ. ខួរឆ្អឹងខ្នងកើតពីបណ្ដុំនៃណឺរ៉ូន ដែលដឹកនាំអាំងភ្លុចប្រសាទពីគ្រប់ផ្នែក ទាំងអស់នៃសារពាង្គកាយទៅកាន់ខួរក្បាលនិងដឹកនាំអាំងភ្លុចប្រសាទពី ខួរក្បាលទៅកាន់គ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ ។

5. - អាមីបជាប្រូទីសមួយប្រភេទដែលរស់នៅក្នុងទឹកមិនស្អាត ។ វាបង្កជំងឺ រាកមួល កាលណាមនុស្សបរិភោគទឹក ឬអាហារមិនស្អាតដែលមាន អាមីបនេះ ។

- សាឌីយ៉ាជាប្រូទីសមួយប្រភេទដែលរស់នៅក្នុងទឹកសាប ។ កាលណា មនុស្សផឹកទឹកមិនស្អាតដោយមានសាឌីយ៉ា វានឹងចូលទៅក្នុង សារពាង្គកាយ ហើយភ្ជាប់ខ្លួនទៅនឹងពោះវៀន ចិញ្ចឹមជីវិតនិងបន្ត ពូជ ។ សាឌីយ៉ាបង្កជំងឺសាឌីយ៉ូសដែលធ្វើឱ្យការរំលាយអាហារនិងថ្លើម ដំណើរការមិនល្អ ។

- ប្លាស្មូដ្យូមជាប្រូទីសមួយប្រភេទទៀតដែលបង្កជំងឺគ្រុនចាញ់ដល់មនុស្ស ។ បរាសិតនេះឆ្លងមកមនុស្សតាមរយៈមូសដែកគោលញីខាំ ដែលមានផ្ទុក ស្ប៉ូប្លាស្មូដ្យូម ។

# វិញ្ញាសាទី ៨ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ណឺរ៉ូនដែលចាប់រំញោចនៅក្នុងស្បែកនិងភ្នែកជា :

   ក. ☐ ណឺរ៉ូនភ្ជាប់

   ខ. ☐ ណឺរ៉ូនចលករ

   គ. ☐ ស៊ីណាប់

   ឃ. ☐ ណឺរ៉ូនវិញ្ញាណនាំ ។

2. ភ្នាក់ងារបង្ករោគមួយប្រភេទដែលធ្វើឱ្យការរំលាយអាហារប្រព្រឹត្តមិនល្អជា :

   ក. ☐ អាមីប

   ខ. ☐ សាឌីយ៉ា

   គ. ☐ បាក់តេរី

   ឃ. ☐ ប្លាស្មូដ្យូម ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

   ក. សារធាតុគីមីមួយចំនួនជា.......... ដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើតភាពស៊ាំ ។

   ខ. ការបំពុលខ្យល់បណ្តាលឱ្យមានបាតុភូត ភ្លៀងអាស៊ីត...... និងបម្រែបម្រួលអាកាសធាតុ ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. របាំងការពារដំបូង<br>2. តំណបរលាក<br>3. តំណបស៊ាំ | ក. ជាកិច្ចការពារសារពាង្គកាយប្រឆាំងនឹងមេរោគដោយផលិតអង់ទីករ<br>ខ. ជាកិច្ចការពារសារពាង្គកាយប្រឆាំងនឹងមេរោគដោយផលិតអាំងទែផេរ៉ុង<br>គ. ជាកិច្ចការពារសារពាង្គកាយដោយរារាំងភ្នាក់ងារបង្ករោគមិនឱ្យចូលក្នុងសារពាង្គកាយ<br>ឃ. ជាកិច្ចការពារសារពាង្គកាយប្រឆាំងនឹងមេរោគដោយផាកូស៊ីត | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ក. តើរស្មីសំយោគកើតមានក្នុងស្រទាប់ណាក្នុងស្លឹករុក្ខជាតិ ?
   ខ. តើស្រទាប់នោះមានលក្ខណៈពិសេសអ្វីខ្លះ ?
2. ក. តើសំណល់បំបែកធាតុបានជាអ្វី ? ចូរឱ្យឧទាហរណ៍ ។
   ខ. តើសំណល់បំបែកធាតុមិនបានជាអ្វី ? ចូរឱ្យឧទាហរណ៍ ។
3. តើប្រព័ន្ធប្រសាទមនុស្សចែកជាផ្នែកអ្វីខ្លះ ? តើផ្នែកនីមួយៗមាននាទីដូចម្តេច ?
4. តើសារពាង្គកាយមនុស្សមានរបាំងការពារប៉ុន្មាន ? តើរបាំងការពារនីមួយៗមាននាទីដូចម្តេចខ្លះ ?
5. ក. តើបាក់តេរីចែកខ្លួនជាពីរតាមវិធីណា ?
   ខ. តើបាក់តេរីចែកជាពីរក្នុងលក្ខខណ្ឌយ៉ាងដូចម្តេច ?

# កំណែវិញ្ញាសាទី ៨

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ ណឺរ៉ូនវិញ្ញាណនាំ ។
2. ខ. ☑ សាឌីយ៉ា ។
3. ក. វ៉ាក់សាំង

   ខ. ការបំផ្លាញស្រទាប់អូសូន ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ    2 → ឃ    3 → ក ។

## III. ចម្លើយ

1. ក. រស្មីសំយោគកើតឡើងនៅក្នុងស្រទាប់ជាលិកាមេសូភីលផ្ទៃខាងក្នុងស្លឹក ។

   ខ. ស្រទាប់ជាលិកាមេសូភីលស្ថិតនៅចន្លោះអេពីឌែមលើនិងអេពីឌែមក្រោមនៃស្លឹក ។ ជាលិកាមេសូភីលបង្កឡើងពីកោសិកាមានភ្នាសស្តើងពីរប្រភេទគឺ មេសូភីលប៉ាលីសាត និងមេសូភីលស្ពោត ។ ដោយសារកោសិកានៃស្រទាប់មេសូភីលមានក្លរ៉ូប្លាស ដែលអាចចាប់យកថាមពលពន្លឺព្រះអាទិត្យ ដូចនេះរស្មីសំយោគកើតឡើងនៅក្នុងស្រទាប់នេះ ។
2. ក. សំណល់បំបែកធាតុបាន ជាសំណល់ដែលអាចបំបែកបានដោយបាក់តេរី ។ឧទាហរណ៍ : ផលិតផលធ្វើពីឈើ សំណល់អាហារ សត្វ ឬរុក្ខជាតិអាចរលួយបាន ក្រោយពីទុកចោលអស់មួយរយៈ ។

   ខ. សំណល់បំបែកធាតុមិនបានជាសំណល់មិនរលួយ ហើយបាក់តេរីមិនអាចបំបែកជាអាហារបាន ។ ឧទាហរណ៍ : អំបែងកែវ ថង់ ឬដបប្លាស្ទិច ថ្នាំសម្លាប់សត្វល្អិត មិនអាចបំបែកបានដោយបាក់តេរី ។

3. ប្រព័ន្ធប្រសាទមនុស្សចែកជាពីរផ្នែកសំខាន់គឺ មជ្ឈមណ្ឌលប្រសាទនិងបរិមណ្ឌលប្រសាទ ។ មជ្ឈមណ្ឌលប្រសាទជាមជ្ឈមណ្ឌលត្រួតពិនិត្យនៃសារពាង្គកាយ ។ វាភ្ជាប់ប្រព័ន្ធទាំងអស់នៃសារពាង្គកាយនិងដឹកនាំសញ្ញាពីប្រព័ន្ធមួយទៅប្រព័ន្ធមួយផ្សេងទៀត ។ បរិមណ្ឌលប្រសាទដឹកនាំព័ត៌មានរវាងមជ្ឈមណ្ឌលប្រសាទនិងផ្នែកផ្សេងៗនៃសារពាង្គកាយ ។

4. ក្នុងសារពាង្គកាយមនុស្សមានរបាំងការពារសំខាន់ៗចំនួនបី ។ របាំងការពារទីមួយមាននាទីរារាំងភ្នាក់ងារបង្ករោគភាគច្រើនមិនឱ្យជ្រៀតចូលក្នុងសារពាង្គកាយបាន ។ របាំងការពារទីពីរជាតំណបរលាក ។ វាប្រឆាំងនឹងភ្នាក់ងារបង្ករោគដែលចូលក្នុងសារពាង្គកាយតាមរយៈផាកូស៊ីតូស ។ របាំងការពារទីបី ជាប្រព័ន្ធស៊ាំនៃសារពាង្គកាយ ។ វាផលិតអង់ទីករសម្រាប់បំផ្លាញមេរោគដែលចូលក្នុងសារពាង្គកាយ ។

5. ក. ដំបូងសម្ភារៈតំណពូជស្វ័យតម្លើងទ្វេ ហើយចែកខ្លួនជាណ្វៃយ៉ូកូនពីរ ។ បន្ទាប់មកស៊ីតូប្លាសចែកខ្លួនជាពីរ ហើយនៅចុងបញ្ចប់កើតបានកោសិកាកូនពីរ ដែលកោសិកាកូននីមួយៗមានសម្ភារៈតំណពូជដូចគ្នា ហើយដូចទៅនឹងកោសិកាមេ ។

   ខ. នៅក្នុងមជ្ឈដ្ឋានដែលមានអាហារគ្រប់គ្រាន់ សីតុណ្ហភាពត្រឹមត្រូវនិងកត្តាផ្សេងៗទៀតសមស្រប បាក់តេរីកើនចំនួនយ៉ាងរហ័ស ។ បាក់តេរីខ្លះទៀតចែកខ្លួនជាពីររៀងរាល់ 20 នាទីម្ដង ។

# វិញ្ញាសាទី ៩ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. សារធាតុគីមីដែលបង្កើតភាពស៊ាំរបស់សារពាង្គកាយជា ៖

ក. ☐ អង់ទីករ

ខ. ☐ អង់ទីប៊្យូទិច

គ. ☐ វ៉ាក់សាំង

ឃ. ☐ អង់ទីសែន ។

2. សារធាតុគីមីដែលបណ្ដាលឱ្យមានភ្លៀងអាស៊ីតជា ៖

ក. ☐ កាបូនម៉ូណូអុកស៊ីត

ខ. ☐ សមាសធាតុសំណ

គ. ☐ ក្លរ៉ូភ្លុយរ៉ូកាបូន

ឃ. ☐ ស្ពាន់ធ័រឌីអុកស៊ីត ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. តាមធម្មតាអេពីឌែមផ្ទៃក្រោមស្លឹកមាន........... ច្រើនជាងអេពីឌែមផ្ទៃលើស្លឹក ។

ខ. ជំងឺកាមរោគដែលដុះសាច់ពក ហើយរីកកាន់តែធំឡើងៗ ដោយពកខ្លះមានរាងមូល ពកខ្លះរាងដូចផ្កាស្ពៃ ហៅថា......... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ចម្លើយ |
|---|---|---|
| 1. ជំងឺទឹកនោមផ្អែម<br>2. ជំងឺលើសឈាម<br>3. ជំងឺមហារីក | ក. បណ្តាលមកពីការបរិភោគច្រើនហួសក្នុងរយៈពេលយូរ<br>ខ. បណ្តាលមកពីការលូតលាស់ខុសធម្មតានៃកោសិកាណាមួយ<br>គ. បណ្តាលមកពីការលូតលាស់ខ្លាំងនៃខ្លាញ់នៅក្នុងស្រទាប់សរសៃឈាមអាកទែ<br>ឃ. បណ្តាលមកពីអវត្តមានអរម៉ូនអាំងស៊ុយលីន | 1. →<br>2. →<br>3. → |

## III. សំណួរ

1. ហេតុអ្វីបានជាយើងមិនគួរដាំដំណាំញឹកកៀកជិតគ្នា ប្រសិនបើចង់បានផលច្រើន ?
2. តើខួរឆ្អឹងខ្នងបង្កឡើងពីសរសៃប្រសាទអ្វីខ្លះ ? តើសរសៃប្រសាទទាំងនោះមាននាទីអ្វីខ្លះ ?
3. ក. តើវ៉ាក់សាំងជាថ្នាំព្យាបាលជំងឺដែរឬទេ ?

   ខ. តើវ៉ាក់សាំងសម្រាប់ជំងឺមួយប្រភេទអាចបង្ការជំងឺផ្សេងទៀតដែរឬទេ ? ហេតុអ្វី ?
4. ក. តើការបំពុលជាអ្វី ?

   ខ. តើមានការបំពុលអ្វីខ្លះ ? ចូរឱ្យឧទាហរណ៍ការបំពុលនីមួយៗ ។
5. ក. តើជំងឺអេដស៍បង្កឡើងពីមេរោគអ្វី ? តើវានៅកន្លែងណាខ្លះក្នុងខ្លួនមនុស្ស ?

   ខ. ចូររៀបរាប់ពីរបៀបឆ្លងនិងមិនឆ្លងនៃជំងឺអេដស៍ ។

# កំណែវិញ្ញាសាទី ៩

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ អង់ទីសែន ។
2. ឃ. ☑ ស្ពាន់ធ័រឌីអុកស៊ីត ។
3. ក. ស្តូម៉ាត
   ខ. សិរមាន់ ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ឃ 2 → គ 3 → ខ ។

## III. ចម្លើយ

1. ប្រសិនបើយើងចង់បានផលច្រើន យើងមិនគួរដាំដំណាំញឹក កៀកជិតគ្នាពេកទេ ព្រោះពន្លឺព្រះអាទិត្យចាំងចូលមិនដល់ ហើយស្លឹករុក្ខជាតិមិនអាចចាប់ថាមពលពន្លឺព្រះអាទិត្យបាន ដើម្បីផលិតអាហារនិងអុកស៊ីសែនតាមរយៈរស្មីសំយោគ ។ ដោយរុក្ខជាតិមិនអាចផលិតអាហារសម្រាប់ខ្លួនឯងបាន ដូចនេះរុក្ខជាតិមិនអាចលូតលាស់និងផ្តល់ផលល្អបានឡើយ ។
2. ខួរឆ្អឹងខ្នងបង្កឡើងពីសរសៃប្រសាទវិញ្ញាណនាំនិងសរសៃប្រសាទចលករ ។ សរសៃប្រសាទវិញ្ញាណនាំបញ្ជូនអាំងភ្លុចប្រសាទចេញពីសរីរាង្គវិញ្ញាណទៅកាន់មជ្ឈមណ្ឌលប្រសាទ ។ សរសៃប្រសាទចលករបញ្ជូនអាំងភ្លុចប្រសាទចេញពីមជ្ឈមណ្ឌលប្រសាទទៅកាន់សាច់ដុំនិងក្រពេញ ។
3. ក. វ៉ាក់សាំងជាថ្នាំបង្ការរោគ មិនមែនជាថ្នាំព្យាបាលជំងឺទេ ។
   ខ. វ៉ាក់សាំងសម្រាប់ជំងឺមួយប្រភេទ មិនអាចបង្ការជំងឺផ្សេងៗទៀតបានទេ ពីព្រោះអង់ទីករដែលផលិតឡើងត្រូវគ្នានឹងអង់ទីសែនយថាប្រភេទ

របស់វាតែប៉ុណ្ណោះ វាមិនអាចប្រឆាំងនឹងអង់ទីសែនរបស់មេរោគផ្សេងៗ ទៀតបានឡើយ ។

4. ក. ការបំពុលជាការធ្វើឱ្យកខ្វក់ដល់បរិស្ថាន ដោយសារការទុកដាក់សំណល់ មិនត្រឹមត្រូវ ។

ខ. ការបំពុលមានបីប្រភេទគឺ ការបំពុលខ្យល់ ការបំពុលទឹក និងការបំពុល ដី ។

- ការបំពុលខ្យល់ បណ្តាលមកពីធាតុកខ្វក់មួយចំនួនដូចជាឧស្ម័ន $CO_2$ $SO_2$ NO ចេញពីរោងចក្រនិងយានយន្ត ។
- ការបំពុលទឹក បណ្តាលមកពីសំណល់ឧស្សាហកម្ម ទឹកលូសំអុយ សារធាតុចិញ្ចឹមដែលប្រើក្នុងកសិកម្ម ហើយហូរចូលប្រភពទឹក ។
- ការបំពុលដី បណ្តាលមកពីសំណល់រឹង ឬរាវដែលទុកដាក់មិនបាន ត្រឹមត្រូវដូចជា ថ្នាំសម្លាប់សត្វល្អិត សម្ភារៈធ្វើពីប្លាស្ទិច... ។

5. ក. ជំងឺអេដស៍បង្កឡើងពីវីរុសហ៊ីវ (HIV) ។ មេរោគនេះមិនអាចរស់នៅ ក្រៅខ្លួនបានយូរទេ ប៉ុន្តែវាអាចរស់នៅបានយូរអង្វែងនៅក្នុងឈាម ទឹកកាមរបស់បុរស ទឹករំអិលនៃប្រដាប់បន្តពូជនារី ទឹករងៃ ។

ខ. ជំងឺអេដស៍អាចឆ្លងតាមរយៈការរួមភេទជាមួយដៃគូផ្ទុកមេរោគអេដស៍ ពីម្តាយផ្ទុកមេរោគអេដស៍ទៅកូន ការប៉ះពាល់ឈាមអ្នកផ្ទុកមេរោគ អេដស៍ ។ ប៉ុន្តែជំងឺអេដស៍មិនឆ្លងតាមទំនាក់ទំនងគ្នាជាសាធារណៈ ដូច ជា ការកណ្តាស ការកាន់ដៃគ្នា ហូបបាយជាមួយគ្នា... ។ វាក៏មិនអាច ឆ្លងតាមរយៈសត្វមូស ឬសត្វចិញ្ចឹមដែរ ។

# វិញ្ញាសាទី ១០ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. មជ្ឈមណ្ឌលប្រសាទមាន :

ក. ☐ ប្រព័ន្ធប្រសាទសូម៉ាទិចនិងស្វ័យប្រវត្តិ

ខ. ☐ ខួរក្បាលនិងខួរឆ្អឹងខ្នង

គ. ☐ ខួរធំ ខួរតូច និងខួរឆ្អឹងខ្នង

ឃ. ☐ ខួរឆ្អឹងខ្នងនិងបរិមណ្ឌលប្រសាទ ។

2. ជំងឺឆ្លងបណ្ដាលមកពី :

ក. ☐ ភ្នាក់ងារបង្ករោគ

ខ. ☐ ការចម្លង

គ. ☐ ដុំពក

ឃ. ☐ រោគសញ្ញា ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ក្នុងស្រទាប់មេសូភីលមាន.......... ដែលកើតឡើងពីជាលិកានាំ ។

ខ. គោលិកាសដែលប្រឆាំងនឹងមេរោគអេដស៍គឺ.................. ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ភីបប្រសាទ<br>2. បាច់ប្រសាទ<br>3. សរសៃប្រសាទ | ក. គឺជាបណ្ដុំនៃបាច់ប្រសាទ<br>ខ. គឺជាបាច់ដង់ឌ្រីតនៅក្នុងសរសៃប្រសាទ<br>គ. គឺជាអាក់សូននៅក្នុងសរសៃប្រសាទ<br>ឃ. គឺជាបាច់អាក់សូននៅក្នុងសរសៃប្រសាទ | 1. →<br>2. →<br>3. → |

## III. សំណួរ

1. តើផលិតផលរស្មីសំយោគជាអ្វី ? តើផលិតផលទាំងនេះត្រូវបានប្រើប្រាស់ធ្វើអ្វីខ្លះ ?
2. ក. ដូចម្ដេចហៅថាជំងឺឱកាសនិយម ? តើអ្នកជំងឺអេដស៍ច្រើនកើតជំងឺឱកាសនិយមអ្វីខ្លះ ?
   ខ. តើការប្រើស្រោមអនាម័យអាចបង្ការការឆ្លងមេរោគអេដស៍បាន 100% ដែរឬទេ ?
3. ក. ចូរឱ្យឧទាហរណ៍ការបំផ្លាញជម្រកធម្មជាតិ ។
   ខ. ហេតុអ្វីការបំផ្លាញជម្រកធម្មជាតិធ្វើឱ្យបរិស្ថានប្រែប្រួល ?
4. ហេតុអ្វីបានជាអ្នកកើតជំងឺកញ្ជ្រិលតែម្ដងគត់ក្នុងមួយជីវិត ?
5. ក. តើខួរតូចជាអ្វី ? តើវាស្ថិតនៅកន្លែងណា ?
   ខ. តើខួរតូចមានលក្ខណៈនិងនាទីដូចម្ដេចខ្លះ ?

# កំណែវិញ្ញាសាទី ១០

## I. ចម្លើយដែលត្រឹមត្រូវ

1. ខ. ☑ ខួរក្បាលនិងខួរឆ្អឹងខ្នង ។
2. ក. ☑ ភ្នាក់ងារបង្ករោគ ។
3. ក. ទ្រនុងស្លឹក

   ខ. ឡាំផូស៊ីត ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ឃ 3 → ក ។

## III. ចម្លើយ

1. ផលិតផលរស្មីសំយោគមានគ្លុយកូសនិងឧស្ម័នអុកស៊ីសែន ។ រុក្ខជាតិប្រើប្រាស់គ្លុយកូសដើម្បីបង្កើតសមាសធាតុសរីរាង្គសំខាន់ៗដូចជា សែលុយឡូសលីពីត ប្រូតេអ៊ីន សម្រាប់ការលូតលាស់របស់រុក្ខជាតិ ។ គ្លុយកូសលើសពីតម្រូវការបំប្លែងជាអាមីដុង ហើយស្តុកទុកក្នុងឫស ។ ឧស្ម័ន $O_2$ ភាយចេញពីស្លឹកតាមស្តូម៉ាតទៅក្នុងបរិយាកាសសម្រាប់ដង្ហើមរបស់ភាវៈរស់ ។
2. ក. ជំងឺឱកាសនិយមជាជំងឺដែលបង្កឡើងដោយមេរោគផ្សេងៗជ្រៀតចូលក្នុងសារពាង្គកាយនៅពេលប្រព័ន្ធស៊ាំចុះខ្សោយ ។ ជំងឺឱកាសនិយមដែលច្រើនកើតលើអ្នកជំងឺអេដស៍មាន ជំងឺរបេង ជំងឺរលាកស្រោមខួរ ជំងឺរាករ៉ាំរ៉ៃ ជំងឺសើស្បែក ។

   ខ. ប្រសិនបើអ្នកប្រើប្រាស់ស្រោមអនាម័យបានត្រឹមត្រូវ វាពិតជាអាចបង្ការបាន 100% ។
3. ក. ការបំផ្លាញជម្រកធម្មជាតិ មានការកាប់ឆ្ការព្រៃ ឬលុបត្រពាំង ស្រះ ដើម្បីធ្វើផ្លូវថ្នល់ ឬសង់លំនៅដ្ឋាន ។

ខ. កាលណាជម្រកធម្មជាតិត្រូវបានបំផ្លាញ វានឹងធ្វើឱ្យស្ថានប្រព័ន្ធប្រែប្រួល ដូចជាប្រភេទភាវៈរស់មួយចំនួននឹងផុតពូជដោយសារកង្វះអាហារ គ្មានកន្លែងបន្តពូជ គ្មានទឹកជាដើម ។ ការបាត់បង់ព្រៃឈើធ្វើឱ្យអាកាសធាតុប្រែប្រួល ដូចជាមិនសូវមានភ្លៀង ឬទឹកជន់លិចស្រែចម្ការដែលបណ្ដាលឱ្យខូចខាតដំណាំកសិកម្ម ។ ដូចនេះការបំផ្លាញជម្រកធម្មជាតិធ្វើឱ្យស្ថានប្រព័ន្ធបាត់បង់តុល្យភាព ។

4. ក្រោយពេលមេរោគកញ្រ្ជឹលជ្រៀតចូលក្នុងសារពាង្គកាយជាលើកទីមួយ ប្រព័ន្ធស៊ាំបានផលិតអង់ទីករប្រឆាំងនឹងវីរុសកញ្រ្ជឹល ។ បន្ទាប់មកអង់ទីករនោះមិនរលាយបាត់ទេ វាស្ថិតនៅក្នុងឈាមដើម្បីត្រៀមការពារសារពាង្គកាយរហូត ។ នៅពេលមេរោគកញ្រ្ជឹលជ្រៀតចូលក្នុងសារពាង្គកាយម្ដងទៀត អង់ទីករក្លាយជាសកម្ម ហើយបង្អាក់អង់ទីសែនមេរោគមិនឱ្យធ្វើសកម្មភាព ។ ដូចនេះបានជាសារពាង្គកាយពុំមានជំងឺនេះម្ដងទៀត ។

5. ក. ខួរតូចជាផ្នែកទីពីរនៃខួរក្បាល ដែលជាមជ្ឈមណ្ឌលប្រសាទ ។ ខួរតូចស្ថិតនៅខាងក្រោមផ្នែកខាងក្រោយនៃខួរធំ ។

ខ. ខួរតូចចែកជាអឌ្ឍគោលខួរពីរ ដែលផ្ទៃនៃខួរតូចមានចង្អូរជ្រៅៗជាច្រើន ។ ប៉ុន្តែខួរតូចមានទំហំតូចជាងខួរធំ ។ ខួរតូចបញ្ជាចលនាសាច់ដុំឱ្យធ្វើការព្រមគ្នានិងរលូន ។ ខួរតូចក៏ជួយឱ្យសារពាង្គកាយមានលំនឹងផងដែរ ។

# វិញ្ញាសាទី ១ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដែកស្ថិតក្នុងប្រភេទរ៉ែ :

ក. ☐ ស៊ីលីកាត

ខ. ☐ គ្មានស៊ីលីកាត

គ. ☐ ស្ថិតនៅទាំងពីរ

ឃ. ☐ មិនស្ថិតនៅទាំងពីរ ។

2. ល្បះខាងក្រោមណាមួយជាវិធីកាត់បន្ថយការកើនកម្តៅលើភពផែនដី :

ក. ☐ ហាមឃាត់មិនឱ្យសង់ផ្ទះខ្ពស់ៗដាក់កញ្ចក់

ខ. ☐ រក្សាទឹកនៅលើភពផែនដីឱ្យបានច្រើន

គ. ☐ ប្រើប្រាស់ផូស៊ីលឥន្ធនៈឱ្យបានច្រើន

ឃ. ☐ រក្សានិងដាំដើមឈើឱ្យបានច្រើន ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ :

ក. ទឹកសាបដែលមនុស្សប្រើប្រាស់សព្វថ្ងៃមានប្រភពសំខាន់ពីរគឺ........ និង .................. ។

ខ. ម៉ាក់ម៉ាដែលហូរចេញមកលើផ្ទៃដីហៅថា..................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ធ្យូងតួប | ក. លឿង | 1. → |
| 2. ធ្យូងលីញីត | ខ. ត្នោតក្រហម | 2. → |
| 3. ធ្យូងប៊ីទូម | គ. ក្រមៅ | 3. → |
| | ឃ. ត្នោត | |

## III. សំណួរ

1. ចូររៀបរាប់ព្រំដែនបែកចេញពីគ្នា ។
2. ចូររៀបរាប់ពីប្រេងនិងឧស្ម័នធម្មជាតិ ។
3. ចូររៀបរាប់ពីកំណែច្នៃជាថ្មី ។
4. ចូររៀបរាប់ពីផលប៉ះពាល់នៃការបំពុលអាកាសទៅលើសុខភាពមនុស្ស ។

# កំណែវិញ្ញាសាទី ១

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ ស្ថិតនៅទាំងពីរ ។
2. ឃ. ☑ រក្សានិងដាំដើមឈើឱ្យបានច្រើន ។
3. ក. ទឹកលើផ្ទៃដីនិងទឹកក្នុងដី ។
   ខ. កំអែភ្នំភ្លើង ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ឃ 3 → ក ។

## III. ចម្លើយ

1. នៅពេលផ្លាកតិចតូនិចធ្វើចលនាចេញពីគ្នា នោះព្រំដែនរវាងផ្លាកទាំងពីរហៅថា ព្រំដែនបែកចេញ ឬព្រំដែនសំណង់ ។ ព្រំដែនបែកចេញគឺជាកន្លែងដែលមណ្ឌលថ្ម មហាសមុទ្រថ្មីកើតឡើង ។ ទ្រនុងកណ្តាលមហាសមុទ្រគឺជាកន្លែងព្រំដែនបែកចេញកើតឡើង ។ គេប្រទះឃើញព្រំដែនបែកចេញនៅលើទ្វីបផងដែរ ។
2. ប្រេងនិងឧស្ម័នធម្មជាតិបានកើតឡើងតាំងពីរាប់រយលានឆ្នាំមុន ដោយសារពាង្គកាយដែលងាប់ហើយធ្លាក់កប់នៅបាតសមុទ្រ ហើយគ្របដណ្តប់ដោយកម្ទេចកំណ ។ នៅពេលកម្ទេចកំណច្រើនឡើង វាធ្វើប្រតិកម្មនៅក្នុងសិលា ។ សម្ពាធនិងកម្តៅបានបំបែកសំណល់សារពាង្គកាយឱ្យទៅជាប្រេងនិងឧស្ម័នធម្មជាតិ ។ នៅពេលសម្ពាធនិងកម្តៅកាន់តែកើនឡើង ប្រេងនិងឧស្ម័នបានជ្រាបចូលតាមស្នាមប្រេះនិងរន្ធនៃសិលាបង្កើតបានជាអាងប្រេងនៅក្នុងដី ។ អាងប្រេងច្រើនមាននៅក្នុងស្រទាប់ថ្មក្រែនិងថ្មភាជន៍ ។ ឧស្ម័ន

ធម្មជាតិច្រើនស្ថិតនៅជាមួយ ឬក្បែរអាងប្រេងដែរ ។ ឧស្ម័នធម្មជាតិស្រាលជាងប្រេង ដូចនេះវាស្ថិតនៅពីលើប្រេង ។

3. កំណៃច្នៃជាថ្មី គឺយើងត្រូវរកវិធីដើម្បីប្រើប្រាស់ឱ្យអស់លទ្ធភាពលើសម្ភារៈដែលយើងបោះចោលនោះ គឺត្រូវកែច្នៃជាថ្មីឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ កំណៃច្នៃជាថ្មីយើងត្រូវការញែករូបធាតុដែលអាចប្រើប្រាស់ជាថ្មីបានដូចជា លោហៈ កែវ និងក្រដាសដែលចេញពីសំណល់រឹង ។ បន្ទាប់មករូបភាពដែលអាចប្រើប្រាស់ជាថ្មីត្រូវបានគេយកទៅកែច្នៃហើយត្រឡប់ចូលទៅក្នុងវិស័យសេដ្ឋកិច្ចវិញក្នុងរូបភាពជាផលិតផលប្រើប្រាស់ថ្មី ។

4. ការបំពុលអាកាសមានបញ្ហាយ៉ាងធ្ងន់ធ្ងរដល់សុខភាពមនុស្ស ។ កត្តាដែលនាំឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សសំខាន់ៗមានដូចជា លក្ខខណ្ឌនៃបរិយាកាស បរិមាណសារធាតុបំពុលដែលបញ្ចេញចោល រយៈពេលនៃការស្ថិតនៅជាមួយសារធាតុបំពុល ចម្ងាយពីប្រភពសារធាតុបំពុលអាយុនិងស្ថានភាពសុខភាពរបស់មនុស្ស និងធាតុពុលរបស់សារធាតុបំពុល ឬស្រឡាយរបស់វា ។ លទ្ធផលទាំងនេះបានធ្វើឱ្យកុមារ មនុស្សចាស់ ជាពិសេសមនុស្សដែលមានជំងឺបេះដូងនិងសួតសុទ្ធតែងាយរងឥទ្ធិពលពីការបំពុលអាកាសធ្ងន់ធ្ងរដល់សុខភាពជាងគេ ។ តាមការសង្កេតពីសុខភាពមនុស្សដែលរស់នៅក្នុងតំបន់ដែលមានការបំពុលខ្លាំងនិងសុខភាពមនុស្សដែលរស់នៅក្នុងតំបន់ដែលមានការបំពុលតិចតួចមានភាពខុសគ្នា ។ តំបន់ដែលមានការបំពុលខ្លាំង មនុស្សភាគច្រើនកើតជំងឺផ្លូវដង្ហើម ជំងឺមហារីក និងជំងឺខួរក្បាលចំពោះកុមារ ។

# វិញ្ញាសាទី ២ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ផូស៊ីលឥន្ធនៈកើតឡើងពី ៖

ក. ☐ ប្រេងកាត

ខ. ☐ ឧស្ម័នធម្មជាតិ

គ. ☐ សំណល់រុក្ខជាតិនិងសត្វ

ឃ. ☐ ប្រេងកាតនិងឧស្ម័នធម្មជាតិ ។

2. កម្លាំងដែលនាំឱ្យខូចទ្រង់ទ្រាយសំបកផែនដីមាន ៖

ក. ☐ 2 ប្រភេទ

ខ. ☐ 3 ប្រភេទ

គ. ☐ 4 ប្រភេទ

ឃ. ☐ 5 ប្រភេទ ។

3. ចូរបំពេញឈ្មោះភ្នំភ្លើងខាងក្រោមឱ្យបានត្រឹមត្រូវ ៖



......................



......................



......................



......................

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. អាសន្នរោគ | ក. ខ្វះជាតិដែក | 1. → |
| 2. ផ្លូវដង្ហើម | ខ. ការបំពុលអាកាស | 2. → |
| 3. ខ្វាក់មាន់ | គ. ការប្រើប្រាស់ទឹកកខ្វក់ | 3. → |
| 4. តេតាណូស | ឃ. ខ្វះវីតាមីនអា | 4. → |
| | ង. ខ្វះអាហារ | |

## III. សំណួរ

1. ដើម្បីការពារប្រភពទឹកកុំឱ្យរងការបំពុល តើយើងត្រូវធ្វើអ្វីខ្លះ ?
2. ចូររៀបរាប់ពីរលកក្នុងនៃការរញ្ជួយដី ។
3. ដូចម្ដេចដែលហៅថា រ៉ែ កំណប់រ៉ែ និងផូស៊ីលឥន្ធនៈ ?
4. ចូររៀបរាប់ពីការបំពុលអាកាស ។

# កំណែវិញ្ញាសាទី ២

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ សំណល់រុក្ខជាតិនិងសត្វ ។
2. ខ. ☑ 3 ប្រភេទ ។
3. 



*ប្រភេទហាវ៉ៃ*



*ប្រភេទស្ត្រុំបូលី*



*ប្រភេទវុលកាណូ*



*ប្រភេទប៉េលេ*

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ    2 → ខ    3 → ឃ    4 → ក ។

## III. ចម្លើយ

1. ដើម្បីការពារប្រភពទឹកកុំឱ្យរងការបំពុល យើងត្រូវចូលរួមដូចជា :
   - មិនត្រូវសង់បង្គន់ក្បែរប្រភពទឹកនិងលើប្រភពទឹក
   - មិនត្រូវសង់ប្រព័ន្ធបង្ហូរទឹកសំអុយចូលទៅក្នុងប្រភពទឹក
   - មិនត្រូវចោលសំរាមផ្សេងៗចូលទៅក្នុងប្រភពទឹក ជាពិសេសសំបកដប និងកំប៉ុងថ្នាំពុល...
   - មិនត្រូវដាក់សម្រាស់ក្នុងប្រភពទឹកដើម្បីនេសាទត្រីឡើយ
   - មិនត្រូវប្រើប្រាស់ថ្នាំពុលគីមីក្នុងវិស័យកសិកម្ម
   - មិនត្រូវនេសាទត្រីហួសកម្រិត ព្រោះត្រីក៏ជួយធ្វើឱ្យទឹកថ្លាផងដែរ
   - ត្រូវធ្វើរបងព័ទ្ធជុំវិញប្រភពទឹកដែលប្រើប្រាស់ប្រចាំថ្ងៃ
   - ត្រូវចិញ្ចឹមនិងទុកដាក់សត្វឱ្យឆ្ងាយពីប្រភពទឹក

- ត្រូវរក្សាទុករុក្ខជាតិឱ្យដុះនៅតាមមាត់ទឹក ព្រោះវាអាចជួយការពារការហូរច្រោះដី ច្រោះទឹកឱ្យថ្លា និងស្រូបយកសារធាតុពុលផ្សេងៗ
- ត្រូវចូលរួមដាំដើមឈើឱ្យបានច្រើនថែមទៀត ដើម្បីកាត់បន្ថយការហូរច្រោះនិងកាកសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក
- ត្រូវចូលរួមថែរក្សាបរិវេណជុំវិញប្រភពទឹកឱ្យមានអនាម័យល្អ ។

2. រលកក្នុងគឺជារលករញ្ជួយដែលធ្វើចលនាឆ្លងកាត់ផ្នែកខាងក្នុងនៃផែនដីហៅថា រលកក្នុង ។ រលកក្នុងមានពីរប្រភេទគឺ រលកទី 1 ឬរលក P និងរលកទី 2 ឬរលក S ។
   - រលកទី 1 ឬរលក P គឺជារលករញ្ជួយដីលឿនបំផុតដែលធ្វើចលនាឆ្លងកាត់រូបធាតុ រឹង រាវ និងឧស្ម័ន ។ ដោយសារល្បឿនលឿននេះហើយទើបវាអាចធ្វើចលនាឆ្លងកាត់ផ្នែកទាំងអស់នៃផែនដីបាន ។ រលក P តែងតែធ្វើចលនាទៅដល់មុនរលកឯទៀត ។
   - រលកទី 2 ឬរលក S គឺជារលករញ្ជួយដីដែលធ្វើចលនាឆ្លងកាត់ផែនដីយឺតជាងរលក P ។ រលក S មិនធ្វើដំណើរឆ្លងកាត់វត្ថុរាវឡើយ ។ រលក S បង្កើនល្បឿននៅពេលដែលវាធ្វើដំណើរឆ្លងកាត់វត្ថុខាប់ ។ ផ្នែកខាងក្នុងនៃផែនដី គឺជារូបធាតុរាងក្តៅ ។ ដោយសារតែរលក S មិនអាចធ្វើដំណើរឆ្លងកាត់រូបធាតុរាវ ដូចនេះហើយទើបរលក S ធ្វើដំណើរឆ្លងកាត់ផែនដីដោយល្បឿនយឺត ។

3. - **រ៉ែ :** ជាអង្គធាតុរឹង អសរីរាង្គកើតឡើងដោយធម្មជាតិក្នុងសំបកផែនដីមានទម្រង់ជាគ្រាម ។ ផ្នែករឹងរបស់ផែនដីក៏ជាសិលា ។ សិលាផ្សំពីរ៉ែពីរឬច្រើនប្រភេទ ចំណែករ៉ែវិញក៏មិនកើតពីសិលាដែរ ។
   - **កំណប់រ៉ែ :** គឺជាបណ្តុំរូបធាតុរឹងកើតឡើងដោយធម្មជាតិនៅក្នុងនិងលើសំបកផែនដី មានទ្រង់ទ្រាយនិងបរិមាណដែលអាចឱ្យយើងធ្វើ

អាជីវកម្មបាននិងបំប្លែងទៅជាវត្ថុមានប្រយោជន៍ផ្សេងៗទៀត ។

- **ផូស៊ីលឥន្ធនៈ** : ជាការកកើតឡើងពីសំណល់រុក្ខជាតិនិងសត្វដែលងាប់រលួយកប់នៅក្នុងសំបកផែនដីរាប់លានឆ្នាំកន្លងមក ហើយក៏មិនកើតឡើងវិញដែរ ។

4. បរិយាកាសបានការពារផែនដីពីគ្រោះថ្នាក់នៃលំហខាងក្រៅដោយស្រូបយកកាំរស្មីគ្រោះថ្នាក់ និងការពារភាវៈរស់ឱ្យផុតពីឥទ្ធិពលកាំរស្មីទាំងនោះ ។ ប៉ុន្តែបំពុលដែលបង្កគ្រោះថ្នាក់ខ្លាំងបំផុតនោះគឺជាសកម្មភាពរបស់មនុស្សផ្ទាល់បានបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ។ ការបំពុលអាកាសបាននាំឱ្យកើតមានបាតុភូតបីគឺ ភ្លៀងអាស៊ីត ការធ្វើឱ្យស្រទាប់អូសូនស្តើង និងការកើនឡើងនៃកម្តៅលើផែនដីជាដើម ។ ចំណែកឯការបំពុលអាកាសពីធម្មជាតិមានដូចជា ការផ្ទុះភ្នំភ្លើង និងភ្លើងឆេះព្រៃជាដើម ។ បន្ទុះភ្នំភ្លើងបានបញ្ចេញអ័ព្ទអាស៊ីត អ៊ីដ្រូសែនស៊ុលផួ និងឧស្ម័នពុលផ្សេងទៀត ។ រីឯភ្លើងឆេះព្រៃវាក៏បានបញ្ចេញផ្សែងចូលទៅក្នុងបរិយាកាសដែរ ។ សារធាតុពុលបរិយាកាសសំខាន់ៗមានដូចជា :

- ឧស្ម័នកាបូនិច ($CO_2$)
- ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$)
- អាសូតម៉ូណូអុកស៊ីត (NO) អាសូតឌីអុកស៊ីត ($NO_2$) ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$)
- **សមាសធាតុសរីរាង្គហើរ** : មេតាន ($CH_4$) បង់សែន ($C_6H_6$) ក្លរ៉ូភ្លុយអរ៉ូកាបូន (CFCs)
- **ភាគល្អិតអណ្តែតរិលរវល់** : ភាគល្អិតរឹងដូចជា ធូលី សំណ ប្រេង ថ្នាំសម្លាប់សត្វចង្រៃ... ។

# វិញ្ញាសាទី ៣ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ប្រភពបំពុលទឹកមាន ៖

ក. ☐ 2 ប្រភេទ

ខ. ☐ 3 ប្រភេទ

គ. ☐ 4 ប្រភេទ

ឃ. ☐ 5 ប្រភេទ ។

2. ផ្លាកមហាសមុទ្រប៉ាស៊ីភិចមានផ្ទៃ ៖

ក. ☐ 1/2 នៃផ្ទៃផែនដី

ខ. ☐ 1/3 នៃផ្ទៃផែនដី

គ. ☐ 1/4 នៃផ្ទៃផែនដី

ឃ. ☐ 1/5 នៃផ្ទៃផែនដី ។

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. ធនធានទឹកជាបណ្ដាញ.............. មួយយ៉ាងសំខាន់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនៃប្រទេសនីមួយៗនៅលើពិភពលោក ។

ខ. នៅពេលខ្លះកម្លាំងអាចធ្វើឱ្យផ្ទាំងសិលាដែលជាសំបកផែនដីកោងតែមិនអាចបាក់បែកបានឡើយ ផ្ទាំងកោងនោះគេឱ្យឈ្មោះថា......... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. រលកទី 1 | ក. រលកក្នុង | 1. → |
| 2. រលកទី 2 | ខ. រលក S | 2. → |
| 3. រលកផ្ទៃលើ | គ. រលក P | 3. → |
| | ឃ. រលក L | |

## III. សំណួរ

1. ចូររៀបរាប់ពីផលវិបាកនៃការប្រើប្រាស់ទឹករងការបំពុល ។
2. ចូររៀបរាប់ពីដំណាក់ស្រុត ។
3. ចូររៀបរាប់ពីផលប៉ះពាល់នៃការប្រើប្រាស់រ៉ែទៅលើបរិស្ថាន ។
4. តើសំណល់រឹងមានប្រភពមកពីកន្លែងណាខ្លះ ?

# កំណែវិញ្ញាសាទី ៣

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑ 2 ប្រភេទ ។
2. ឃ. ☑ 1/5 នៃផ្ទៃផែនដី ។
3. ក. គមនាគមន៍

   ខ. ពំនើងផុត ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ខ 3 → ឃ ។

## III. ចម្លើយ

1. សព្វថ្ងៃធនធានទឹកសាបកំពុងទទួលរងការបំពុលពីប្រភេទសារធាតុបំពុលនានា ហើយក៏បានជះឥទ្ធិពលដល់មនុស្ស សត្វ និងរុក្ខជាតិដែលត្រូវការទឹកជាពិសេសសារពាង្គកាយដែលរស់នៅក្នុងទឹកតែម្ដង ។ សារធាតុបំពុលទឹកសាបបានបង្កឱ្យមានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះមនុស្ស សត្វ និងរុក្ខជាតិដែលប្រើប្រាស់ទឹកនោះ ។ ឧទាហរណ៍ ៖ ចំពោះមនុស្សបណ្ដាលឱ្យមានជំងឺគ្រុនពោះវៀន អាសន្នរោគ រាកមួល រលាកពោះវៀន និងជំងឺថ្លើមជាដើម ។
2. ភាពរឹងនៃទ្រនទ្វីបមិនអាចឱ្យវាពើង ឬផុតបានទេ ប៉ុន្តែនៅពេលទទួលរងកម្លាំងប្រទាញ ឬកម្លាំងជំរុញផ្ទប់ ពេលនោះវាបែរជាបាក់ហើយបែកចេញពីគ្នាជាផ្នែកៗខណ្ឌដោយបំណាក់ស្រុត ។ បំណាក់ស្រុតគឺជាបំណាក់នៃសំបកផែនដី ។ នៅសងខាងបំណាក់នេះ ជាផ្ទៃដីដែលនៅជាប់គ្នាពីមុន ស្រាប់តែមានម្ខាងផុសឡើង ម្ខាងស្រុតចុះក្រោមបណ្ដាលឱ្យកើតកម្ពស់ធៀបនៅលើសណ្ឋានដីដែលគេហៅថា មុខចំណោត ។ បំណាក់ស្រុតបង្កើតឱ្យមានផ្ទាំង

ផុសនិងអាងសម្រុត ។ ជាទូទៅបំណាក់ស្រុតបង្កើតឱ្យមានសណ្ឋានដីរាងគម្រាំង ឬជាជ្រុង ហើយមានកម្ពស់ផ្សេងៗពីកន្លែងមួយទៅកន្លែងមួយទៀត ។ ឧទាហរណ៍ : សណ្ឋានដីនៅតំបន់ជួរភ្នំដងរែកនៃប្រទេសកម្ពុជាយើងកើតឡើងពីបំណាក់ស្រុតនៃបឹងទន្លេសាប ។

3. ការជីកយករ៉ែបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានសំខាន់ៗរួមមាន :

- **ការបោះបង់ដីចោល** : នៅពេលដែលទាញយករ៉ែអាចធ្វើឱ្យមានការបោះបង់ដីចោលច្រើនកន្លែង ដែលបណ្ដាលមកពីកង្វក់នៃសារធាតុគីមីបំផ្លាញស្រទាប់ដីមានជីជាតិ និងធ្វើឱ្យខូចគុណភាពដីជាអចិន្ត្រៃយ៍នៅតំបន់កំណប់រ៉ែ ។
- **ការស្រុតដី** : អណ្ដូងរ៉ែលែងធ្វើអាជីវកម្មនិងកំពុងធ្វើអាជីវកម្មដែលជ្រៅជាមូលហេតុនៃការបាក់ស្រុតផ្ទៃដីខាងលើតាមខ្សែឈរ ឬដេក ដែលអាចបំផ្លាញអគារ ផ្លូវថ្នល់ ជីកសិកម្ម និងធ្វើឱ្យមានការប្រែប្រួល របបទឹកហូរលើផ្ទៃដីទៀតផង ។
- **ការបំពុល** : ការជីកយករ៉ែបានបំពុលបរិយាកាស ទឹកលើផ្ទៃដី និងទឹកក្នុងដី ។ ទឹកភ្លៀងដែលជ្រាបចូលទៅក្នុងគំនរសំណល់រ៉ែបានធ្វើឱ្យទឹកនោះកខ្វក់ (ជូរ ល្អក់) ហើយហូរចូលទៅបំពុលដល់ប្រភពទឹកទន្លេ ស្ទឹង ព្រែក និងប្រភពផ្សេងៗទៀត ។ ទឹកភ្លៀងដែលហូរចេញពីគំនរសំណល់នោះ បានហូរនាំធាតុគីមីដូចជា កូបាល់ កាត់ម្ញូម ទង់ដែង និងសារធាតុផ្សេងៗទៀតទៅជាមួយ ហើយផ្ដុំគ្នាច្រើនឡើង ជាហេតុធ្វើឱ្យទឹក ដី និងរុក្ខជាតិពុល ហើយអាចខូចសុខភាពចំពោះមនុស្ស សត្វ និងរុក្ខជាតិ ។
- **ស្ងួតស័ព្ទ** : ការដែលធ្វើអាជីវកម្មរ៉ែបានត្រូវដាក់ឱ្យផ្ទុះ និងការដឹកជញ្ជូនដែលនាំឱ្យមានសូរស័ព្ទរំខានដល់ប្រជាជននិងសត្វព្រៃនៅក្នុងតំបន់នោះផងដែរ ។

4. តាមការពិតយើងបានដឹងពីប្រភពនៃសំណល់រឹងដែលចេញមកពីលំនៅដ្ឋាន ទីផ្សារ អគារពាណិជ្ជកម្ម មជ្ឈមណ្ឌលផ្គត់ផ្គង់ស្បៀងអាហារ សណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញ អ្នកលក់ដូរតាមដងផ្លូវសាធារណៈ តំបន់ទេសចរណ៍ និងកន្លែងផ្សេងៗទៀត ។ សំណល់ទាំងនោះគេសង្កេតឃើញមានច្រើនមុខណាស់ដូចជា ក្រដាស ថង់ប្លាស្ទិច សំណល់អាហារ កម្ទេចកម្ទីកំណាត់សំពត់ បន្លែ ផ្លែឈើ កម្ទេចដែក សំបកកំប៉ុង សំបកដប... ។ សំណល់រឹងមួយផ្នែកទៀត មានប្រភពពីរោងចក្រនានាដូចជា រោងចក្រផលិតអាគុយ ស័ង្កសី ថ្នាំសម្លាប់សត្វល្អិត ថ្នាំពណ៌កំប៉ុង និងរោងចក្រផលិតក្រដាស... ។ម្យ៉ាងទៀតសំណល់រឹងក៏មានប្រភពចេញពីមន្ទីរពេទ្យ (សំបកថ្នាំ ប្រដាប់ចាក់ថ្នាំ បង់រុំរបួស) និងសំណល់ដែលនៅតាមទីកន្លែងសត្តឃាតផងដែរ ។ សំណល់រឹងដែលចេញពីប្រភពទាំងនេះមានមួយផ្នែកមិនសូវមានគ្រោះថ្នាក់ និងមួយផ្នែកទៀតមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរបំផុត ។ ជារួមសំណល់ទាំងអស់សុទ្ធតែមានគ្រោះថ្នាក់ដល់បរិស្ថាន ។ ប៉ុន្តែ សំណល់រឹងដែលបង្កគ្រោះថ្នាក់ខ្លាំងដល់បរិស្ថាននោះគឺ សំណល់ដែលមានប្រភពចេញមកពីរោងចក្រឧស្សាហកម្មដែលដើរដោយថាមពលនុយក្លេអ៊ែ ។

# វិញ្ញាសាទី ៤ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. កត្តាដែលនាំឱ្យមានការបំពុលទឹកសំខាន់ ៖
   - ក. ☐ កត្តាធម្មជាតិ
   - ខ. ☐ កត្តាមនុស្ស
   - គ. ☐ កត្តាប្រទេសជិតខាង
   - ឃ. ☐ កត្តាធម្មជាតិនិងកត្តាមនុស្ស ។
2. ទ្រឹស្តីទ្វីបរសាត់ជាសម្មតិកម្មរបស់ ៖
   - ក. ☐ លោកញូតុន
   - ខ. ☐ លោកអាល់ព្រឺដវ៉េសេនឺ
   - គ. ☐ លោកកាលីឡេ
   - ឃ. ☐ លោកហារីហេស ។
3. ចូរបំពេញពាក្យនិងភាគរយនៅក្នុងដ្យាក្រាមខាងក្រោមឱ្យបានត្រឹមត្រូវ ៖




*ដ្យាក្រាមតាងបរិមាណទឹកនៅលើផែនដី* *ដ្យាក្រាមតាងបរិមាណទឹកសាបនៅលើផែនដី*

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ឧស្ម័នកាបូនិច | ក. NO | 1. → |
| 2. ស្ពាន់ធ័រឌីអុកស៊ីត | ខ. $SO_2$ | 2. → |
| 3. អាសូតម៉ូណូអុកស៊ីត | គ. $CO_2$ | 3. → |
| 4. ក្លរ៉ូភ្លុយអរ៉ូកាបូន | ឃ. CFCs | 4. → |
| | ង. $CH_4$ | |

## III. សំណួរ

1. ចូររៀបរាប់ពីប្រភពនៃការបំពុលទឹក ។
2. ចូររៀបរាប់ពីទ្រឹស្តីទ្វីបរសាត់ ។
3. ភពផែនដីចេះតែកើនកម្ដៅឡើង តើបណ្ដាលមកពីកត្តាអ្វីខ្លះ ?
4. តើមូលហេតុអ្វីខ្លះដែលនាំឱ្យមានកង្វះទឹកសាបនាពេលអនាគត ?

# កំណែវិញ្ញាសាទី ៤

## I. ចម្លើយដែលត្រឹមត្រូវ

1. ឃ. ☑ កត្តាធម្មជាតិនិងកត្តាមនុស្ស ។
2. ខ. ☑ លោកអាល់ព្រឹដវ៉េសេនឺ ។
3.




*ដ្យាក្រាមតាងបរិមាណទឹកនៅលើផែនដី* *ដ្យាក្រាមតាងបរិមាណទឹកសាបនៅលើផែនដី*

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → គ 2 → ខ 3 → ក 4 → ឃ ។

## III. ចម្លើយ

1. ប្រភពនៃការបំពុលទឹកចែកចេញជាពីរប្រភេទ គឺប្រភពបំពុលចំណុចនិងប្រភពបំពុលរាយប៉ាយ ។
   - **ប្រភពបំពុលចំណុច** : មានប្រភពចេញពីកន្លែងមួយច្បាស់លាស់តាមរយៈបំពង់បង្ហូរ ឬប្រឡាយពីទីតាំងនៃប្រភពដូចជា រោងចក្រនិងបំពង់បង្ហូរទឹកសំអុយ ។ បំពុលចំណុចនេះ មានលក្ខណៈងាយស្រួលក្នុងការត្រួតពិនិត្យនិងធ្វើប្រព្រឹត្តកម្មសម្អាតទឹកឡើងវិញ ។
   - **ប្រភពបំពុលរាយប៉ាយ** : ជាប្រភពដែលបង្ករឱ្យមានការបំពុលដោយសារធាតុបំពុលពីដីច្រើនកន្លែង ហើយប្រមូលផ្តុំសារធាតុទាំងនោះ រួចហូរ

ចូលទៅក្នុងទឹកដូចជា ស្រះ អូរ ស្ទឹង និងទន្លេ ។ ប្រភពបំពុលរាយប៉ាយ រួមមាន លំហូរកសិកម្ម ការបំផ្លាញព្រៃឈើ ទឹកកខ្វក់ដែលចេញពីការជីកយករ៉ែ ការដ្ឋានសំណង់ និងលំនៅដ្ឋាន ។ ដំណោះស្រាយដែលល្អគឺអាស្រ័យលើការយល់ដឹងក្នុងកម្រិតមួយខ្ពស់របស់បុគ្គល គ្រួសារ និងសហគមន៍ ។

2. នៅឆ្នាំ 1910 អ្នកវិទ្យាសាស្ត្រជនជាតិអាល្លឺម៉ង់ម្នាក់ឈ្មោះ អាល់ព្រីដវ៉េសេនី (Alfred Wegener) បានចាប់អារម្មណ៍ចង់ដឹងអំពីទំនាក់ទំនង រវាងទ្វីបទាំងឡាយ ។ គាត់បានបង្កើតសម្មតិកម្មថា ទ្វីបធ្វើចលនា ។ ទ្វីបទាំងអស់ស្ថិតនៅរួមគ្នាជាផ្ទាំងដីដ៏ធំមួយហៅថា **ប៉ង់សៀ** (Pangea) ។ ប៉ង់សៀកើតឡើងប្រហែល 300 លានឆ្នាំមុន ពេលនោះហើយគឺជាពេលដំបូងដែលល្មូននិងសត្វល្អិតមានស្លាបបានកើតឡើង ។ ក្រោយមក ផ្ទាំងដីនេះក៏រសាត់ដាច់ចេញពីគ្នាបន្តិចម្តងៗ រហូតក្លាយជាទ្វីបផ្សេងៗដូចបច្ចុប្បន្ននេះ ។ លោកអាល់ព្រីដវ៉េសេនី បានប្រមូលភស្តុតាងមកពីតំបន់និងកន្លែងផ្សេងៗគ្នាជាច្រើនដើម្បីគាំទ្រសម្មតិកម្មរបស់គាត់ដែលថាទ្វីបរសាត់នោះ ។ គាត់បានសិក្សាជាពិសេសទៅលើលក្ខណៈដីផូស៊ីលនិងភស្តុតាងនៃការប្រែប្រួលអាកាសធាតុ ។

3. ភពផែនដីចេះតែកើនកម្តៅឡើងបណ្តាលមកពីថាមពលព្រះអាទិត្យដែលចាំងមកលើផែនដី ប្រមាណពាក់កណ្តាលត្រូវបានស្រូបចូលទៅក្នុងផ្ទៃដី ។ បន្ទាប់មកថាមពលនេះ ក៏ត្រឡប់ចូលទៅក្នុងលំហវិញក្នុងទម្រង់ជារស្មីក្រហមអាំប្រាដែលមើលមិនឃើញ ។ ឧស្ម័នផ្ទះកញ្ចក់ដែលមានពីធម្មជាតិនៅក្នុងមណ្ឌលអាកាសរចល់ដូចជា ទឹក ឧស្ម័នកាបូនិច ឌីអាសូតម៉ូណូអុកស៊ីត មេតាន អូសូន និងក្លរ៉ូភ្លុយអរ៉ូកាបូន ។ ឧស្ម័នទាំងនេះស្រូបយករស្មីក្រហមអាំប្រាមួយភាគដែលភាយចេញពីក្នុងដី ហើយបញ្ចេញកម្តៅ

ដែលជាហេតុនាំឱ្យកើនកម្តៅនៅក្នុងមណ្ឌលអាកាសរចល់ ហើយនៅទីបំផុតផ្ទៃដីក៏កើនកម្តៅឡើងដែរ ។

4. មូលហេតុដែលបណ្តាលឱ្យមានកង្វះទឹកសាបនាពេលអនាគតមានពីរដែលជាសំខាន់គឺ :

- **កំណើនកម្តៅ :** ការកាប់បំផ្លាញព្រៃឈើបានធ្វើឱ្យមានការប្រែប្រួលអាកាសធាតុដូចជា កម្តៅនៅលើផែនដីចេះតែកើនឡើង ដែលបង្កើតឱ្យមានរំហួតទឹកនៅលើផ្ទៃផែនដីយ៉ាងខ្លាំង និងនាំឱ្យកាតឹបទឹកកករលាយ រួចហូរចូលទៅក្នុងមហាសមុទ្រ ហើយក្លាយទៅជាទឹកប្រៃទាំងអស់ទៅថ្ងៃអនាគត ។
- **កំណើនប្រជាជន :** សព្វថ្ងៃកំណើនប្រជាជននៅលើពិភពលោកកាន់តែកើនឡើងយ៉ាងឆាប់រហ័ស ប៉ុន្តែបរិមាណទឹកសាបមិនកើនឡើងទេ ។ អ្នកវិទ្យាសាស្ត្របានទស្សន៍ទាយថា នៅឆ្នាំ 2025 ប្រទេសជាច្រើនលើពិភពលោកនឹងខ្វះខាតទឹកសាបប្រើប្រាស់ពិតជាមិនខានឡើយ ។

# វិញ្ញាសាទី ៥ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ពាក្យថាមេឌីទែរ៉ានេជាឈ្មោះ :

ក. ☐ បឹង ខ. ☐ ទន្លេ

គ. ☐ សមុទ្រ ឃ. ☐ មហាសមុទ្រ ។

2. ផ្នែកប៉ោងឡើងនៃពំនើងផ្ទត់ហៅថា :

ក. ☐ ផ្ទាំងផុស ខ. ☐ អាងសម្រុត

គ. ☐ អង់ទីគ្លីណាល់ ឃ. ☐ សាំងគ្លីណាល់ ។

3. ចូរបំពេញពាក្យក្នុងរូបខាងក្រោមឱ្យបានត្រឹមត្រូវ :




វដ្តទឹក

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ប្រភេទហាវ៉ៃ | ក. ខាប់ស្អិតខ្លាំងណាស់ មាត់បំពង់បិទជិត | 1. → |
| 2. ប្រភេទស្ត្រុំបូលី | ខ. ធ្លាក់មកក្រោមវិញជាគ្រាប់បែក | 2. → |
| 3. ប្រភេទវុលកាណូ | គ. ខាប់ស្អិតរកកល់ធ្វើឱ្យស្ទះជិតបំពង់ | 3. → |
| 4. ប្រភេទប៉េលេ | ឃ. មានរំហូរធំទូលាយនិងត្រួតស៊ីគ្នាច្រើនដង | 4. → |
| | ង. មានរំហូតស្តើងហើយហូរជាប់ជានិច្ច | |

## III. សំណួរ

1. ចូររៀបរាប់ពីការគ្រប់គ្រងទឹក ។
2. ចូររៀបរាប់ពីផ្លាកនីតូស៊ែ្វ ឬមណ្ឌលថ្ម ។
3. ចូររៀបរាប់ពីគ្រោះមហន្តរាយនៃការរញ្ជួយដី ។
4. ចូររៀបរាប់ពីប្រភេទផូស៊ីលឥន្ធនៈ ។

# កំណែវិញ្ញាសាទី ៥

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ សមុទ្រ ។

2. គ. ☑ អង់ទីគ្លីណាល់ ។

3.




វដ្តទឹក

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ឃ　　2 → ខ　　3 → គ　　4 → ក ។

## III. ចម្លើយ

1. ដើម្បីគ្រប់គ្រងទឹកយើងត្រូវសិក្សាពីសារធាតុពុលនានាដែលហូរចូលទៅក្នុងទឹកដូចជា :

- **មីក្រុបបង្ករោគ :** ទឹកប្រើប្រាស់ត្រូវពិនិត្យពីកូលីបាស៊ី (ប្រភេទបាក់តេរី) ជាមុន ព្រោះវាជាភ្នាក់ងារចម្លងមេរោគយ៉ាងសំខាន់មួយ ។ នៅក្នុងប្រទេសជាច្រើន ការធ្វើតែសរកចំនួនកូលីបាស៊ីដែលមាននៅក្នុងទឹក

ត្រូវបានគេប្រើសម្រាប់កំណត់គុណភាពទឹក ។ ជាទូទៅនៅក្នុងទឹកសម្រាប់ផឹកមិនអនុញ្ញាតឱ្យមានកូលីបាស៊ីទេ ។

- **ការរក្សាបរិមាណអុកស៊ីសែននៅក្នុងទឹក :** បរិមាណអុកស៊ីសែននៅក្នុងទឹក គឺជាសន្ទស្សន៍បង្ហាញពីគុណភាពទឹក និងប្រភេទនៃជីវិតដែលជាមជ្ឈដ្ឋានទឹកអាចទ្រទ្រង់បាន ។ កាលណាកម្តៅកាន់តែខ្លាំងបរិមាណអុកស៊ីសែនក្នុងទឹកកាន់តែថយចុះ ។ បរិមាណអុកស៊ីសែននៅក្នុងទឹកវាក៏ទាក់ទងទៅនឹងទឹកលូសំអុយសំណល់រោងចក្រ និងសំណល់ផ្សេងៗ ពេលចាក់ចូលទៅក្នុងទឹក ដែលត្រូវការអុកស៊ីសែនដើម្បីបំបែកធាតុនោះបានធ្វើឱ្យអុកស៊ីសែនក្នុងទឹកធ្លាក់ចុះដែរ ។
- **កម្វេចកំណដី :** គឺជាមូលហេតុនៃការបំពុលទឹកភាគច្រើន ។ ប្រភពចម្បងនៃកម្វេចកំណដី គឺកើតឡើងពីសំណឹកដីតំបន់កសិកម្ម ការកាប់បំផ្លាញព្រៃឈើនៅតាមដងទន្លេ តំបន់ជំរាលតាមមាត់បឹង ការធ្វើអាជីវកម្មរ៉ែ និងការលាងខ្សាច់ គ្រួស ។ ទឹកទន្លេនិងស្ទឹងតែងតែដឹកជញ្ជូនកម្វេចកំណចូលទៅបឹង ទន្លេ និងសមុទ្រ ហើយកករងធ្លាក់ទៅផ្ទៃបាតបណ្តាលឱ្យរាក់និងថយចុះទាំងដង់ស៊ីតេ បណ្តាភាវៈនិងប្រភេទសត្វមួយចំនួនដែលរស់នៅក្នុងទឹក ។
- **សំណល់រាវផ្សេងៗ :** ត្រូវគ្រប់គ្រងប្រភពនៃការបំពុលឱ្យបានត្រឹមត្រូវ ការបំពុលមានពីរប្រភេទ គឺប្រភពចំណុចនិងប្រភពរាយប៉ាយ ។ សំណល់រាវចេញពីប្រភពទាំងពីរខាងលើនេះត្រូវឆ្លងកាត់ការធ្វើប្រព្រឹត្តកម្មជាមុនសិន ទើបបង្ហូរចូលទៅក្នុងទឹកបឹង ស្ទឹង ទន្លេ... ។ លទ្ធផលនៃការធ្វើប្រព្រឹត្តកម្មទឹកលូសំអុយគេអាចយកទៅស្រោចស្រពដំណាំផ្សេងៗបានយ៉ាងល្អប្រសើរ ។

2. ផ្លាកលីតូស្វ៊ែ ឬមណ្ឌលថ្ម កើតឡើងពីផ្លាកមួយចំនួនដែលមានស្រទាប់ស្តើងនៃសំបកផែនដី ស្ថិតនៅលើស្រទាប់ក្រាស់នៃសិលាត្រជាក់និងរឹង ។ ជាទូទៅផ្លាកមានសំបកទ្វីបនិងមហាសមុទ្រ ។ ផ្លាកលីតូស្វ៊ែ ឬមណ្ឌលថ្មសំខាន់ៗមាន 7 ត្រូវបានគេដាក់ឈ្មោះទៅតាមលក្ខណៈពិសេសនៃផ្ទៃរបស់វាផងដែរ ។ ផ្លាកទាំងនោះរួមមាន ផ្លាកប៉ាស៊ីភិចដែលមានផ្ទៃធំជាង (1/5 នៃផ្ទៃផែនដី) ផ្លាកអាមេរិកខាងជើង អាមេរិកខាងត្បូង អឺរ៉ាស៊ី អាហ្វ្រិក ឥណ្ឌាអូស្ត្រាលី និងផ្លាកអង់តាក់ទិច ។ ក្រៅពីនេះគេឃើញមានផ្លាកតូចជាច្រើនទៀតដូចជា ផ្លាកការីប៊ីន កូកូ សាកា ស្កុតទី អារ៉ាប៊ី ហ្វីលីពីន ការ៉ូលីន និងភីស៊ី... ។

3. គ្រោះមហន្តរាយនៃការរញ្ជួយដីចាប់ពី 6 ទៅ 8 រិចទ័របណ្តាលឱ្យមានគ្រោះមហន្តរាយយ៉ាងធ្ងន់ធរ ។ កត្តាដែលនាំឱ្យមានការបំផ្លាញទាំងនោះរួមមានការអង្រួនផ្ទៃដី ភក់រាវ រំញ័រ និងរលកស៊ូណាមិ ។ កាលពីឆ្នាំ 1923 មានការរញ្ជួយដីដ៏ធំមួយនៅកាន់តូទីក្រុងតូក្យូនិងកាណាកាវ៉ា ធ្វើឱ្យមនុស្សស្លាប់ជាង 10 000 នាក់ របួសនិងបាត់ខ្លួន 43 000 នាក់ និងមានមនុស្សដែលបាត់បង់ជម្រក 3 400 000 នាក់ ហើយបានបំផ្លាញគេហដ្ឋានអស់ចំនួន 700 000 ខ្នង ។ ចំណែកនៅថ្ងៃទី 26 ខែធ្នូ ឆ្នាំ 2004 មានរលកស៊ូណាមិដែលផ្តើមចេញពីផ្ចិតលើរបស់រញ្ជួយដីកាត់ផ្ទៃមហាសមុទ្រ ។ កម្ពស់រលកទាបៗនៅកណ្តាលមហាសមុទ្រឥណ្ឌា ប៉ុន្តែពេលវាធ្វើដំណើរមកដល់កន្លែងរាក់រលកមានកម្ពស់រហូតដល់ 30 ម៉ែត្រ ដែលកើតឡើងពីរញ្ជួយដីក្រោមទឹក ដែលមានចាប់ពី 9.1 ទៅ 9.3 រិចទ័រ ហើយមានផ្ចិតលើស្ថិតនៅក្បែរឆ្នេរនៃកោះស៊ូម៉ាត្រាក្នុងប្រទេសឥណ្ឌូណេស៊ី ។ រលកនេះបានធ្វើឱ្យមនុស្សស្លាប់ជាង 225 000 នាក់ដែលរស់នៅក្នុងប្រទេសចំនួន 11 ។ ប៉ុន្តែប្រទេសដែលទទួលរងគ្រោះខ្លាំងជាងគេមាន ប្រទេសឥណ្ឌូណេស៊ី ស្រីលង្កា ឥណ្ឌា និងថៃ ។

4. ផូស៊ីលឥន្ធនៈមានពីរប្រភេទគឺ :

- **ធ្យូងថ្ម** : ជាផូស៊ីលឥន្ធនៈរឹងកកើតឡើងរាប់លានឆ្នាំមកហើយនៅក្នុងស្រទាប់ដី ។ ធ្យូងថ្មមានច្រើនប្រភេទដូចជា ធ្យូងតួប លីញីត ប៊ីទូម និងអង់ត្រាស៊ីត ។ ប្រភេទនីមួយៗបង្ហាញពីដំណាក់មួយនៃកំណកំណើតធ្យូងថ្ម និងអាចយកមកប្រើប្រាស់បានជាឥន្ធនៈ ។
  + **ធ្យូងតួប** : ជាសារធាតុទន់កើតឡើងពីការពុកផុយនៃរុក្ខជាតិសរសៃ មានពណ៌ត្នោតក្រមៅ ។
  + **ធ្យូងលីញីត** : កើតឡើងពីសម្ពាធនៃកម្ទេចកំណដែលចាក់បង្គរពីលើធ្យូងតួប ។ ធ្យូងលីញីតមានពណ៌ត្នោតទន់និងមានវាយភាពឈើ ។
  + **ធ្យូងប៊ីទូម** : នៅពេលដែលសម្ពាធចេះតែបន្តទៅលើធ្យូងលីញីតធ្វើឱ្យវាក្លាយទៅជាធ្យូងប៊ីទូម ។ ធ្យូងនេះស្ថិតនៅជ្រៅក្នុងផែនដី មានពណ៌ត្នោតក្រមៅ ឬខ្មៅ ហើយទន់សម្បូរជាងគេក្នុងប្រភេទធ្យូងថ្ម ។
  + **ធ្យូងអង់ត្រាស៊ីត** : នៅពេលដែលសម្ពាធកាន់តែខ្ពស់បង្កើតបានជាប្រភេទធ្យូងអង់ត្រាស៊ីត ។ ប្រភេទធ្យូងអង់ត្រាស៊ីតមានលក្ខណៈរឹងហើយស្រួយនិងស្ទើរតែជាកាបូនសុទ្ធ ។
- **ប្រេងនិងឧស្ម័នធម្មជាតិ** : បានកើតឡើងតាំងពីរាប់លានឆ្នាំមុន ដោយសារពាង្គកាយដែលងាប់ហើយធ្លាក់កប់នៅបាតសមុទ្រ ហើយគ្របដណ្ដប់ដោយកម្ទេចកំណ ។ នៅពេលកម្ទេចកំណច្រើនឡើងវាធ្វើប្រតិកម្មនៅក្នុងសិលា ។ សម្ពាធនិងកម្ដៅបានបំបែកសំណល់សារពាង្គកាយឱ្យទៅជាប្រេងនិងឧស្ម័នធម្មជាតិ ។ នៅពេលសម្ពាធនិងកម្ដៅកាន់តែកើនឡើង ប្រេងនិងឧស្ម័នបានជ្រាបចូលតាមស្នាមប្រេះនិងរន្ធនៃសិលាបង្កើតបានជាអាងប្រេងនៅក្នុងដី ។ អាងប្រេងច្រើនមាននៅក្នុងស្រទាប់ថ្មក្រៃនិងថ្មភាជន៍ ។ ឧស្ម័នធម្មជាតិច្រើនស្ថិតនៅជាមួយ ឬក្បែរអាងប្រេងដែរ ។

# វិញ្ញាសាទី ៦ (រយៈពេល 45នាទី 35ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ធនធាននៅលើភពផែនដី ៖

ក. ☐ មិនកើតឡើងវិញ

ខ. ☐ កើតឡើងវិញ

គ. ☐ មិនកើតឡើងវិញនិងកើតឡើងវិញ

ឃ. ☐ មិនកើតឡើងវិញភាគច្រើន ។

2. រូបខាងក្រោមមួយណាជាកម្លាំងប្រទាញ ៖

ក. ☐ 

ខ. ☐ 

គ. ☐ 

ឃ. ☐ 

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. មានទ្រឹស្តីថ្មីមួយទៀតត្រូវបានបង្កើតឡើងដើម្បីពន្យល់ទៅលើទ្រឹស្តីទ្វីបរសាត់ និងទ្រឹស្តីគម្លាតបាតមហាសមុទ្រនោះគឺ................... ។

ខ. កាំរស្មីដែលភាយចេញពីផែនដីមានឈ្មោះថា........................... ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. ពំនើងផ្នត់ធម្មតា | ក. ផ្នែកប៉ោងឡើងនៃពំនើងផ្នត់ | 1. → |
| 2. ពំនើងផ្នត់សាំញ៉ាំ | ខ. ដែលមានទម្រង់បត់បែនខ្លាំង | 2. → |
| 3. អង់ទីគ្លីណាល់ | គ. ផ្នែកជតចុះនៃពំនើងផ្នត់ | 3. → |
| 4. សាំងគ្លីណាល់ | ឃ. ដែលមានទម្រង់ងាយៗ | 4. → |
| | ង. ផ្នែកដែលស្រុតចុះនៃពំនើងផ្នត់ | |

## III. សំណួរ

1. ចូររៀបរាប់ពីដំណើរការនៃវដ្តទឹក ។
2. ចូររៀបរាប់ពីប្រភេទរលករញ្ជួយដី ។
3. ចូររៀបរាប់ពីបំណែកសិលាភ្នំភ្លើង ។
4. ចូររៀបរាប់ពីសំណល់រឹង ។

# កំណែវិញ្ញាសាទី ៦

## I. ចម្លើយដែលត្រឹមត្រូវ

1. ក. ☑ កើតឡើងវិញ ។

2. ខ. ☑  ។

3. ក. ទ្រឹស្តីផ្លាកតិចតូនិច

   ខ. កាំរស្មីក្រហមអាំងប្រា ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ឃ  2 → ខ  3 → ក  4 → គ ។

## III. ចម្លើយ

1. ដំណើរការនៃវដ្តទឹក គឺជាចលនានៃទឹកពីប្រភពទឹកនានាដូចជា ស្រះ ត្រពាំង បឹង អូរ ព្រែក ស្ទឹង ទន្លេ សមុទ្រ មហាសមុទ្រ និងទឹកនៅក្នុងដីទៅក្នុងបរិយាកាសមានទម្រង់ជារំហួត កំណក និងកំណកអាកាស រួចត្រឡប់មកប្រភពដើមវិញ ។ វដ្តទឹកកើតឡើងទៅតាមបីដំណាក់កាលដូចជា រំហួត កំណក និងកំណកអាកាស ៖
   - **រំហួត** ៖ ជាដំណើរនៃទឹកដែលទទួលរងថាមពលកម្តៅពីព្រះអាទិត្យ ហើយប្រែក្លាយទៅជាចំហាយទឹកនិងឧស្ម័ន ។
   - **កំណក** ៖ ជាលំនាំខ្យល់ក្តៅក្បែរផ្ទៃដី ស្ទុះឡើងលើនាំយកចំហាយទឹកទៅដល់រយៈកម្ពស់ខ្ពស់ដែលមានសីតុណ្ហភាពទាបធ្វើឱ្យចំហាយទឹកប្តូរទៅជាតំណក់ទឹក ហើយបង្កើតបានជាពពក ។
   - **កំណកអាកាស** ៖ តំណក់ទឹកដែលបង្កើតជាពពកប្រមូលផ្តុំគ្នាកាន់តែច្រើនធ្វើឱ្យមាឌរបស់វាកាន់តែរីកធំ ហើយធ្ងន់ក៏ធ្លាក់ត្រឡប់មកផែនដីវិញក្នុងទម្រង់ជាភ្លៀងលាយព្រិល ព្រិល... ។

2. រលករញ្ជួយដីមានពីរប្រភេទគឺ :

- **រលកក្នុង :** គឺជារលករញ្ជួយដែលធ្វើចលនាឆ្លងកាត់ផ្នែកខាងក្នុងនៃផែនដីហៅថារលកក្នុង ។ រលកក្នុងមានពីរប្រភេទគឺ រលកទី 1 ឬរលក P និងរលកទី 2 ឬរលក S ។

  + រលកទី 1 ឬរលក P គឺជារលករញ្ជួយដីលឿនបំផុតដែលធ្វើចលនាឆ្លងកាត់រូបធាតុ រឹង រាវ និងឧស្ម័ន ។ ដោយសារល្បឿនលឿននេះហើយទើបវាអាចធ្វើចលនាឆ្លងកាត់ផ្នែកទាំងអស់នៃផែនដីបាន ។ រលក P តែងតែធ្វើចលនាទៅដល់មុនរលកឯទៀត ។

  + ទី 2 ឬរលក S គឺជារលករញ្ជួយដីដែលធ្វើចលនាឆ្លងកាត់ផែនដីយឺតជាងរលក P ។ រលក S មិនធ្វើដំណើរឆ្លងកាត់វត្ថុរាវឡើយ ។ រលក S បង្កើនល្បឿននៅពេលដែលវាធ្វើដំណើរឆ្លងកាត់វត្ថុខាប់ ។ ផ្នែកខាងក្នុងនៃផែនដី គឺជារូបធាតុរាងក្ដៅ ។ ដោយសារតែរលក S មិនអាចធ្វើដំណើរឆ្លងកាត់រូបធាតុរាវ ដូចនេះហើយទើបរលក S ធ្វើដំណើរឆ្លងកាត់ផែនដីដោយល្បឿនយឺត ។

- **រលកផ្ទៃលើ ឬរលក L :** គឺជារលករញ្ជួយដីដែលយឺតជាងគេ ហើយធ្វើឱ្យផ្ទៃដីលើផ្លាស់ទីចុះឡើង ជារង្វង់នៅពេលដែលវាធ្វើចលនាតាមផ្ទៃដីលើ ។ គេអាចដឹងថាមានរលកផ្ទៃដីលើបានដោយមនុស្សជាច្រើនបានដឹងពីអារម្មណ៍របស់ពួកគេហាក់ដូចជាស្ថិតនៅលើរថភ្លើងរអិលចុះឡើងនៅលើផ្លូវដែកក្នុងសួនកម្សាន្ត ។ រលករញ្ជួយផ្ទៃដីលើមានការបំផ្លាញខ្លាំងជាងរលករញ្ជួយផ្សេងៗទៀតក៏ព្រោះរលករញ្ជួយនេះអង្រួនផ្ទៃដីតាមទិសបញ្ឈរ ។

3. បំណែកសិលាភ្នំភ្លើងកើតឡើងនៅពេលដែលម៉ាក់ម៉ាផ្ទុះចេញពីភ្នំភ្លើង ហើយកករឹងនៅក្នុងអាកាស ។ បំណែកសិលាកកើតឡើងនៅពេលសិលាដែលមានស្រាប់ត្រូវបំបែក ដោយការផ្ទុះដែលមានកម្លាំងខ្លាំង ។ បំណែកសិលានេះមានទំហំច្រើនបែបចាប់ពីភាគល្អិតតូចៗ រហូតដល់ទំហំធំៗប៉ុនអគារ ហើយអាចវិលវល់ក្នុងបរិយាកាសជាច្រើនឆ្នាំ ។ សិលាភ្នំភ្លើងរួមមាន 4ប្រភេទសំខាន់ៗ គឺដុំសិលាភ្នំភ្លើង គ្រាប់បែកភ្នំភ្លើង ធូលីភ្នំភ្លើង និងផេះភ្នំភ្លើង ។

4. សំណល់រឹងត្រូវបានគេបោះបង់ចោលនៅកន្លែងចាក់សំរាម ដោយសារតែគេលែងត្រូវការវាទៀត ។ ប៉ុន្តែបណ្តាប្រទេសនៅលើពិភពលោកបច្ចុប្បន្នសំណល់ជាច្រើនត្រូវបានគេប្រមូលកែច្នៃ ហើយប្រើប្រាស់ឡើងវិញ ឬប្រើប្រាស់ក្នុងគោលបំណងថ្មីផ្សេងទៀត ។ គេបានឱ្យឈ្មោះគោលការណ៍នេះថា **កំណែច្នៃជាថ្មី** ។ សំណល់រឹង ជាសារធាតុបំពុលប្រកបដោយគ្រោះថ្នាក់បំផុត ហើយវាមានច្រើនប្រភេទ ដូចនេះគេត្រូវបែងចែកសំណល់រឹងជាប្រភេទខុសៗគ្នាសម្រាប់ធ្វើផែនការគ្រប់គ្រងឱ្យមានគុណភាព និងប្រសិទ្ធភាព ។ នៅពេលប្រទេសជាតិមានការអភិវឌ្ឍនិងស្ថានភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង តម្រូវការរបស់ប្រជាជនក្នុងការប្រើប្រាស់ប្រចាំថ្ងៃកាន់តែកើនឡើង បង្កឱ្យមានបញ្ហាក្នុងការគ្រប់គ្រងសំណល់រឹង ។ នៅតំបន់ទីប្រជុំជនក្នុងគ្រួសារដែលមានសមាជិកជាមធ្យមចំនួន 5 នាក់ គេសង្កេតឃើញថាម្នាក់ៗអាចបង្កើតសំរាមពី 0.38 ទៅ 0.56 គីឡូក្រាមក្នុងមួយថ្ងៃ (នៅប្រទេសកម្ពុជា) ។

# វិញ្ញាសាទី ៧ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. វដ្តទឹកកើតឡើងតាមបីដំណាក់គឺ ៖

ក. ☐ រំហួត រំភាយ និងកំណកអាកាស

ខ. ☐ សម្ពាធ រំហួត និងកំណកអាកាស

គ. ☐ រំហួត កំណក និងកំណកអាកាស

ឃ. ☐ រំភាយ កំណក និងកំណកអាកាស ។

2. រូបខាងក្រោមមួយណាជាពុំនើងផ្កត់ទ្រេល ៖

ក. ☐ 

ខ. ☐ 

គ. ☐ 

ឃ. ☐ 

3. ចូរបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖

ក. មហាសមុទ្រធំៗមានដូចជា មហាសមុទ្រប៉ាស៊ីភិច អាត្លង់ទិច ឥណ្ឌា និង មហាសមុទ្រទឹកកកអាក់ទិច និងសមុទ្រជាច្រើនទៀតដូចជា ............. ទាំងអស់នេះសុទ្ធសឹងជាប្រភពនៃធនធានទឹកប្រៃ ។

ខ. សំណល់ជាច្រើនត្រូវបានគេប្រមូលយកទៅកែច្នៃ ហើយប្រើប្រាស់ក្នុងគោលបំណងថ្មីផ្សេងទៀត ដូច្នេះគេក៏បានឱ្យឈ្មោះគោលការណ៍ថ្មីនេះថា............. ។

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. លំនៅដ្ឋាន | ក. អគ្គិសនី | 1. → |
| 2. ឧស្សាហកម្ម | ខ. រូបធាតុដើម | 2. → |
| 3. កសិកម្ម | គ. ស្រោចស្រព | 3. → |
| 4. ថាមពល | ឃ. មធ្យោបាយធ្វើដំណើរ | 4. → |
| | ង. បោកគក់ | |

## III. សំណួរ

1. ចូររៀបរាប់ពីបរិមាណទឹកសាបនៅលើភពផែនដី ។
2. ចូររៀបរាប់ពីបន្ទុះភ្នំភ្លើង ។
3. ចូររៀបរាប់ពីរង្វាស់ការរញ្ជួយដី ។
4. ចូររៀបរាប់ពីការកើនឡើងនៃផលផ្ទះកញ្ចក់ ។

# កំណែវិញ្ញាសាទី ៧

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ រំហួត កំណក និងកំណកអាកាស ។

2. ឃ. ☑  ។

3. ក. សមុទ្រចិន មេឌីទែរ៉ាណេ ខ្មៅ ក្រហម កាស់ព្យែន

   ខ. កំណែច្នៃជាថ្មី ។

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ង　　2 → ខ　　3 → គ　　4 → ក ។

## III. ចម្លើយ

1. នៅលើផែនដី ទឹកសាបមានបរិមាណតែ 3% ប៉ុណ្ណោះ ហើយក្នុងបរិមាណ 3% នេះមិនអាចបរិភោគទាំងអស់បានឡើយ ព្រោះបរិមាណនេះបានរាប់បញ្ចូលទាំងទឹកកកនៅក្នុងតំបន់ប៉ូលខាងជើងនិងប៉ូលខាងត្បូងដែលមិនអាចយកមកប្រើប្រាស់បានឡើយ ។ ក្នុងចំណោមទឹកសាប 3% មានតែ 15% ទេ ដែលអាចប្រើប្រាស់សម្រាប់ប្រជាជនទូទាំងពិភពលោក ។ ប្រភពទឹកសាបដែលមនុស្សយកមកប្រើប្រាស់សព្វថ្ងៃមានប្រភពសំខាន់ៗពីរគឺ ទឹកនៅលើផ្ទៃដីនិងទឹកក្នុងដី ។

2. ការផ្ទុះភ្នំភ្លើងវាស្រដៀងគ្នាទៅនឹងដបសូដាពេលយើងក្រឡុក ឬត្រូវកម្ដៅធ្វើឱ្យវាបង្កើតសម្ពាធដ៏ខ្លាំង ។ សម្ពាធក្នុងដបបានរុញច្រានទឹកសូដានិងឧស្ម័នឱ្យចេញមកក្រៅនៅពេលយើងបើកគម្របដប ។ ចំណែកការផ្ទុះភ្នំភ្លើងយើងឃើញម៉ាក់ម៉ាចេញមកលើផ្ទៃផែនដីក្លាយទៅជាសិលាកករឹង ។ បន្ទុះភ្នំភ្លើងគេសង្កេតឃើញមានពីរគឺ បន្ទុះស្ងប់និងបន្ទុះខ្លាំង ។

- **បន្ទុះស្ងប់ :** បន្ទុះមួយដែលបង្កើតជាទន្លេកំអែភ្នំភ្លើងក្តៅពណ៌ក្រហម ដែលហូរចេញមកពីបន្ទុះភ្នំភ្លើងហូរចេញមកក្រៅស្ងប់ស្ងាត់បញ្ចេញនូវបរិមាណសិលារលាយជាច្រើន ។ បន្ទុះស្ងប់បង្កើតបានភ្នំធំៗមួយចំនួននៅលើពិភពលោកដែលកើតពីភ្នំភ្លើងដែលគរលើគ្នាជាច្រើនដងអស់រយៈពេលរាប់ពាន់ឆ្នាំបន្តបន្ទាប់ ។
- **បន្ទុះខ្លាំង :** បន្ទុះខ្លាំងបង្ហាញឱ្យឃើញពំនូកនៃកម្ទេចនិងឧស្ម័នក្តៅព្រួសចេញពីភ្នំភ្លើងល្បឿនលឿនជាងសម្លេងទៅទៀត ។ បន្ទុះខ្លាំងធ្វើឱ្យសិលាដែលរលាយបាចសាចជាបំណែកតូចៗរាប់លានកករឹងក្នុងបរិយាកាស ។ ភាគល្អិតដែលមានជាធូលីហោះវិលចុះឡើងៗនៅក្នុងបរិយាកាសជាន់ខ្ពស់របស់ផែនដី ចំណែកឯកម្ទេចបំណែកធំៗធ្លាក់នៅជិតៗភ្នំភ្លើង ។

3. រញ្ជួយដីជាដំណើរមួយដែលមានភាពស្មុគស្មាញ ប៉ុន្តែរញ្ជួយដីវិទូបានព្យាយាមកំណត់ពេលវេលានិងទីកន្លែងដែលវាបានកើតឡើង ។ ពួកគេបានរកឧបករណ៍វាស់រញ្ជួយដី អាចជួយក្នុងការកត់ត្រានិងវាស់រលករញ្ជួយដីនេះ ។ រង្វាស់នេះបង្ហាញពីចម្ងាយរលករញ្ជួយដីនិងការធ្វើចលនារបស់ផ្ទៃដី ។ ពួកគេបានប្រើប្រាស់ព័ត៌មានទាំងនេះ ដើម្បីបង្ហាញកន្លែងជាក់លាក់ដែលរញ្ជួយដីចាប់ផ្តើមនិងកម្លាំងរញ្ជួយ ។ រង្វាស់រញ្ជួយដីមានមាត្រដ្ឋានម៉្យាងឈ្មោះថា រិចទ័រ (Richtre) សម្រាប់វាស់ទំហំថាមពល ឬកម្លាំងនៃការរញ្ជួយដីដោយបានកំណត់ចំនួនលេខពី 1 រហូតដល់ទៅ 10 ។ ចំនួនលេខចង្អុលបង្ហាញពីកម្រិតកម្លាំងរញ្ជួយដែលកើតឡើងនៅលើមាត្រដ្ឋានរិចទ័រតាមកម្លាំង 1 ឯកតា បរិមាណនៃថាមពលដែលវាបញ្ចេញខ្លាំងជាងគ្នារហូតដល់ទៅ 31.7 ដង ។ តួលេខរលករញ្ជួយលើសពី 6 រិចទ័របញ្ជាក់ថាកម្រិតនៃការបំផ្លាញមានគ្រោះមហន្តរាយខ្លាំងក្លាបំផុត ។

4. ប្រសិនបើកំហាប់នៃឧស្ម័នផលផ្ទះកញ្ចក់ក្នុងមណ្ឌលអាកាសរចល់កើនឡើង នោះកាំរស្មីក្រហមអាំងប្រាដែលភាយចេញពីក្នុងដីចូលទៅក្នុងបរិយាកាសវិញមានចំនួនតិចតួចជាងមុន ។ បាតុភូតនេះ ធ្វើឱ្យមានកំណើនសីតុណ្ហភាពនៅក្នុងមណ្ឌលអាកាសរចល់ជាហេតុនាំឱ្យសីតុណ្ហភាពផ្ទៃផែនដីកើនឡើងដែរ ។ បាតុភូតនេះគេឱ្យឈ្មោះថា "កំណើនផលផ្ទះកញ្ចក់" (The Enhanced Greenhouse Effect) ។ ការបំពុលកើនឡើងនៅគ្រប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅលើពិភពលោក ។ កំណើនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍទីប្រជុំជននិងទីក្រុង ចរាចរណ៍កាន់តែមមាញឹក ការប្រើប្រាស់ឥន្ធនៈមានសារធាតុបំពុល កំណើននៃការប្រើប្រាស់ថាមពលរួមនឹងច្បាប់បរិស្ថានពុំទាន់មាន និងខ្លះទៀតអនុវត្តនៅមានកម្រិតទាប កត្តាទាំងនេះដែលរួមចំណែកធ្វើឱ្យអត្រាឧស្ម័នផ្ទះកញ្ចក់កើនឡើងនៅក្នុងមណ្ឌលអាកាសរចល់លើសពីកម្រិតធម្មជាតិ ។ បញ្ហានេះបង្កឱ្យមានការថយចុះនៃរំភាយរស្មីក្រហមអាំងប្រាជាហេតុនាំឱ្យកើនកម្តៅនៅលើពិភពលោកប្រមាណពី 0.3 ទៅ 0.6°C ក្នុងអំឡុងពេលទសវត្សកន្លងទៅ ។ ប្រសិនបើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្សនៅតែបន្តទៀត កំណើនកម្តៅលើពិភពលោកនឹងរឹតតែមានអត្រាខ្ពស់ថែមទៀត ហើយនឹងឈានទៅដល់កម្រិតកម្តៅមួយដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រមនុស្សជាតិពីមុនមក ។ ភស្តុតាងនៃវិទ្យាសាស្ត្រជាច្រើនបានបង្ហាញថាកំហាប់ឧស្ម័នផ្ទះកញ្ចក់នៅក្នុងមណ្ឌលអាកាសរចល់បានកើនឡើងយ៉ាងច្រើននៅពេលមានកំណើនឧស្សាហកម្មនិងការកាប់ឆ្ការព្រៃយកដីសម្រាប់សង់លំនៅស្ថាននិងធ្វើកសិកម្ម ។ បច្ចុប្បន្នគេបានសម្គាល់ឃើញថា មានកំហាប់ឧស្ម័នផ្ទះកញ្ចក់ពីរបែបបានកើនឡើងលើសកម្រិតដែលមិនធ្លាប់មានពីមុន គឺកាបូនម៉ូណូអុកស៊ីតនិងមេតាន ។

# វិញ្ញាសាទី ៨ (រយៈពេល 45 នាទី 35 ពិន្ទុ)

## I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ដែលមានចម្លើយត្រូវតែមួយគត់

1. ដីដែលបណ្ដាលមកពីបំពុលទឹក ៖

ក. ☐ វលាកទងសួត ខ. ☐ មហារីក

គ. ☐ អាសន្នរោគ ឃ. ☐ អេដស៍ ។

2. រង្វាស់រញ្ញួយជីតិតជា ៖

ក. ☐ គីឡូក្រាម ខ. ☐ ញូតុន

គ. ☐ តោន ឃ. ☐ វិចផ្ទ័រ ។

3. ចូរបំពេញពាក្យនៅក្នុងរូបខាងក្រោមឱ្យបានត្រឹមត្រូវ ៖




ទម្រង់ពំនើងផ្នត់

## II. ចូរផ្គូផ្គងផ្នែក A និងផ្នែក B ឱ្យបានត្រឹមត្រូវរួចសរសេរចម្លើយនៅផ្នែក C

| ផ្នែក A | ផ្នែក B | ផ្នែក C ជាចម្លើយ |
|---|---|---|
| 1. មេឌីទែរ៉ានេ | ក. សមុទ្រ | 1. → |
| 2. ហាវ៉ៃ | ខ. មហាសមុទ្រ | 2. → |
| 3. ឥណ្ឌា | គ. ខ្ពង់រាប | 3. → |
| 4. អង់ | ឃ. ភ្នំភ្លើង | 4. → |
| | ង. ជួរភ្នំ | |

## III. សំណួរ

1. ដើម្បីការពារប្រភពទឹកកុំឱ្យរងការបំពុល តើយើងត្រូវធ្វើអ្វីខ្លះ ?
2. ចូររៀបរាប់ពីរលកក្នុងនៃការរញ្ជួយដី ។
3. ដូចម្ដេចដែលហៅថា រ៉ែ កំណប់រ៉ែ និងផូស៊ីលឥន្ធនៈ?
4. ចូររៀបរាប់ពីការបំពុលអាកាស ។

# កំណែវិញ្ញាសាទី ៨

## I. ចម្លើយដែលត្រឹមត្រូវ

1. គ. ☑ អាសន្នរោគ ។

2. ឃ. ☑ វិចផ្ទ័រ ។

3. បំពេញពាក្យនៅក្នុងរូប




*ទម្រង់ពំនើងផ្នត់*

## II. ចម្លើយផ្គូផ្គងផ្នែក A និងផ្នែក B

1 → ក    2 → ឃ    3 → ខ    4 → ង ។

## III. ចម្លើយ

1. ដើម្បីការពារប្រភពទឹកកុំឱ្យរងការបំពុល យើងត្រូវចូលរួមដូចជា :
   - មិនត្រូវសង់បង្គន់ក្បែរប្រភពទឹកនិងលើប្រភពទឹក
   - មិនត្រូវសង់ប្រព័ន្ធបង្ហូរទឹកសំអុយចូលទៅក្នុងប្រភពទឹក
   - មិនត្រូវចោលសំរាមផ្សេងៗចូលទៅក្នុងប្រភពទឹក ជាពិសេសសំបកដប និងកំប៉ុងថ្នាំពុល...
   - មិនត្រូវដាក់សម្រាស់ក្នុងប្រភពទឹកដើម្បីនេសាទត្រីឡើយ
   - មិនត្រូវប្រើប្រាស់ថ្នាំពុលគីមីក្នុងវិស័យកសិកម្ម
   - មិនត្រូវនេសាទត្រីហួសកម្រិត ព្រោះត្រីក៏ជួយធ្វើឱ្យទឹកថ្លាផងដែរ

- ត្រូវធ្វើរបងព័ទ្ធជុំវិញប្រភពទឹកដែលប្រើប្រាស់ប្រចាំថ្ងៃ
- ត្រូវចិញ្ចឹមនិងទុកដាក់សត្វឱ្យឆ្ងាយពីប្រភពទឹក
- ត្រូវរក្សាទុករុក្ខជាតិឱ្យដុះនៅតាមមាត់ទឹក ព្រោះវាអាចជួយការពារការហូរច្រោះដី ច្រោះទឹកឱ្យថ្លា និងស្រូបយកសារធាតុពុលផ្សេងៗ
- ត្រូវចូលរួមដាំដើមឈើឱ្យបានច្រើនថែមទៀត ដើម្បីកាត់បន្ថយការហូរច្រោះនិងកាកសំណល់ផ្សេងៗចូលទៅក្នុងប្រភពទឹក
- ត្រូវចូលរួមថែរក្សាបរិវេណជុំវិញប្រភពទឹកឱ្យមានអនាម័យល្អ ។

2. រលកក្នុងគឺជារលករញ្ជួយដែលធ្វើចលនាឆ្លងកាត់ផ្នែកខាងក្នុងនៃផែនដីហៅថា រលកក្នុង ។ រលកក្នុងមានពីរប្រភេទគឺ រលកទី 1 ឬរលក P និងរលកទី 2 ឬរលក S ។
   - រលកទី 1 ឬរលក P គឺជារលករញ្ជួយដីលឿនបំផុតដែលធ្វើចលនាឆ្លងកាត់រូបធាតុ រឹង រាវ និងឧស្ម័ន ។ ដោយសារល្បឿនលឿននេះហើយទើបវាអាចធ្វើចលនាឆ្លងកាត់ផ្នែកទាំងអស់នៃផែនដីបាន ។ រលក P តែងតែធ្វើចលនាទៅដល់មុនរលកឯទៀត ។
   - ទី 2 ឬរលក S គឺជារលករញ្ជួយដីដែលធ្វើចលនាឆ្លងកាត់ផែនដីយឺតជាងរលក P ។ រលក S មិនធ្វើដំណើរឆ្លងកាត់វត្ថុរាវឡើយ ។ រលក S បង្កើនល្បឿននៅពេលដែលវាធ្វើដំណើរឆ្លងកាត់វត្ថុខាប់ ។ ផ្នែកខាងក្នុងនៃផែនដី គឺជារូបធាតុរាងក្តៅ ។ ដោយសារតែរលក S មិនអាចធ្វើដំណើរឆ្លងកាត់រូបធាតុរាវ ដូចនេះហើយទើបរលក S ធ្វើដំណើរឆ្លងកាត់ផែនដីដោយល្បឿនយឺត ។

3. - **រ៉ែ** : ជាអង្គធាតុរឹង អសរីរាង្គកើតឡើងដោយធម្មជាតិក្នុងសំបកផែនដីមានទម្រង់ជាគ្រាម ។ ផ្នែករឹងរបស់ផែនដីក៏ជាសិលា ។ សិលាផ្សំពីរ៉ែពីរឬច្រើនប្រភេទ ចំណែករ៉ែវិញក៏មិនកើតពីសិលាដែរ ។
   - **កំណប់រ៉ែ** : គឺជាបណ្តុំរូបធាតុរឹងកើតឡើងដោយធម្មជាតិនៅក្នុងនិងលើ

សំបកផែនដី មានទ្រង់ទ្រាយនិងបរិមាណដែលអាចឱ្យយើងធ្វើអាជីវកម្ម បាននិងបំប្លែងទៅជាវត្ថុមានប្រយោជន៍ផ្សេងៗទៀត ។

- **ផូស៊ីលឥន្ធនៈ** : ជាការកកើតឡើងពីសំណល់រុក្ខជាតិនិងសត្វដែលងាប់រលួយកប់នៅក្នុងសំបកផែនដីរាប់លានឆ្នាំកន្លងមក ហើយក៏មិនកើតឡើងវិញដែរ ។

4. បរិយាកាសបានការពារផែនដីពីគ្រោះថ្នាក់នៃលំហខាងក្រៅដោយស្រូបយកកាំរស្មីគ្រោះថ្នាក់ និងការពារភាវៈរស់ឱ្យផុតពីឥទ្ធិពលកាំរស្មីទាំងនោះ ។ ប៉ុន្តែបំពុលដែលបង្កគ្រោះថ្នាក់ខ្លាំងបំផុតនោះគឺជាសមត្ថភាពរបស់មនុស្សផ្ទាល់បានបញ្ចេញសារធាតុបំពុលទៅក្នុងបរិយាកាស ។ ការបំពុលអាកាសបាននាំឱ្យកើតមានបាតុភូតបីគឺ ភ្លៀងអាស៊ីត ការធ្វើឱ្យស្រទាប់អូសូនស្តើង និងការកើនឡើងនៃកម្តៅលើផែនដីជាដើម ។ ចំណែកឯការបំពុលអាកាសពីធម្មជាតិមានដូចជា ការផ្ទុះភ្នំភ្លើង និងភ្លើងឆេះព្រៃជាដើម ។ បន្ទុះភ្នំភ្លើងបានបញ្ចេញអ័ព្ទអាស៊ីត អ៊ីដ្រូសែនស៊ុលផួ និងឧស្ម័នពុលផ្សេងទៀត ។ រីឯភ្លើងឆេះព្រៃវាក៏បានបញ្ចេញផ្សែងចូលទៅក្នុងបរិយាកាសដែរ ។ សារធាតុពុលបរិយាកាសសំខាន់ៗមានដូចជា :

- ឧស្ម័នកាបូនិច ($CO_2$)
- ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$)
- អាសូតម៉ូណូអុកស៊ីត (NO) អាសូតឌីអុកស៊ីត ($NO_2$) ឌីអាសូតម៉ូណូអុកស៊ីត ($N_2O$)
- **សមាសធាតុសរីរាង្គហើរ** : មេតាន ($CH_4$) បង់សែន ($C_6H_6$) ក្លរ៉ូភ្លុយអូរ៉ូកាបូន (CFCs)
- **ភាគល្អិតអណ្តែតវិលវល់** : ភាគល្អិតរឹងដូចជា ធូលី សំណ ប្រេង ថ្នាំសម្លាប់សត្វចង្រៃ... ។

## យើងបម្រើសេវាកម្ម ៖

- អភិវឌ្ឍសៀវភៅនិងសម្ភារឧបទេស
- បោះពុម្ព
- ចែកផ្សាយដល់សាលារៀន

## WE SERVE :

- book and teaching-aid development
- printing
- distribution to schools




## មានលក់ ៖

សៀវភៅសិក្សាគោលសម្រាប់សិស្ស សម្រាប់គ្រូ សៀវភៅហ្វឹកហាត់ សៀវភៅអំណានបន្ថែម និង សម្ភារឧបទេស ព្រមទាំងសម្ភារការិយាល័យគ្រប់មុខ !

## SELLING :

textbooks , teacher’s manuals , workbooks , supplementary readers , teaching-aids and stationary !


facebook.com/moeys.gov.kh elearning.moeys.gov.kh youtube.com/moeys

9 789924 505099